**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៣/០៨-១០-២០២១-អវតក/អជតក(០៥) |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 14-Oct-2021, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក**

---

**<u>អ្នកដាក់ឯកសារ:</u>**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**<u>ចម្លងជូន:</u>**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**<u>អ្នកទទួលឯកសារ:</u>**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រ៊ីម, ប្រធាន
ចៅក្រម Chandra. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហមេធាវី មាស មុត:**
លោក អាង ឧត្តម
លោក Michael KARNAVAS

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុង**
**សំណុំរឿង ០០៣**

# មាតិកា

**មាតិកា** ........ 1

I. **សេចក្ដីផ្ដើម** ........ 2

II. **ប្រវត្តិនីតិវិធី** ........ 4

ក. កិច្ចស៊ើបសួរ និងការចេញដីកាដំណោះស្រាយ ........ 4

ខ. បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបណ្ដឹងវិវាទជាបន្តបន្ទាប់ មុនការជំនុំជម្រះ ........ 7

III. **ច្បាប់ជាធរមាន** ........ 10

ក. ភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ ........ 10

*យុត្តាធិការដែលមានជាប់មកជាមួយ* ........ 10

*ការរួចផុតពីលក្ខខណ្ឌតម្រូវស្ដីពីការប្រើប្រាស់ដំណោះស្រាយអស់លទ្ធភាព* ........ 14

ខ. បទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ ........ 15

គ. ចរិតលក្ខណៈនៃយន្តការដោះស្រាយវិវាទ អ.វ.ត.ក ដែលអនុញ្ញាត ........ 16

ឃ. ផលប៉ះពាល់នៃកំហុសនីតិវិធីលើកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ........ 17

ង. "គោលជំហរស្វ័យប្រវត្តិ" ជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ........ 22

IV. **ភាពអាចទទួលយកបាន** ........ 24

V. **អង្គសេចក្ដី** ........ 28

ក. ដីកាដំណោះស្រាយផ្ទុយគ្នាមិនត្រូវបានចេញដោយខុសច្បាប់ឡើយ - រឿងក្ដីបន្តទៅជំនុំជម្រះ ........ 28

ខ. ដីកាដំណោះស្រាយផ្ទុយគ្នាមិនមោឃៈ និងគ្មានសុពលភាពទេ ទោះបីជាការចេញក្នុងពេលដំណាលគ្នារបស់វាខុសច្បាប់ក៏ដោយ - រឿងក្ដីត្រូវបន្តទៅជំនុំជម្រះ ........ 34

*កំហុសផ្នែកនីតិវិធីរបស់ ស.ច.ស មិនបណ្ដាលឲ្យមានភាពអយុត្តិធម៌ទាំងស្រុង ផលប៉ះពាល់សំខាន់ ឬការរំលោភដំណើរការនីតិវិធីឡើយ* ........ 35

*ដំណោះស្រាយណាដែលរារាំងរឿងក្ដីនេះមិនឲ្យបន្តទៅមុខបាន គឺមិនសមាមាត្រទៅនឹងព្យសនកម្មដែលបានចោទប្រកាន់* ........ 38

គ. ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានសម្រេចជាឯកច្ឆន្ទថាមានសុពលភាព - រឿងក្ដីត្រូវបន្តទៅជំនុំជម្រះ ........ 41

ឃ. ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុប - រឿងក្ដីត្រូវបន្តទៅជំនុំជម្រះ ........ 44

VI. **សេចក្ដីសន្និដ្ឋាន** ........ 50

VII. **ដំណោះស្រាយដែលស្នើសុំ** ........ 51

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ប្តឹងសាទុក្ខចំពោះការខកខានរបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ក្នុងការបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃសំណុំរឿង ០០៣ និងបញ្ជូនរឿងក្តីទៅអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ដើម្បីជំនុំជម្រះតាមអាណត្តិនៃក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក។ ឥឡូវវាស្ថិតក្នុងអំណាចរបស់អង្គជំនុំជម្រះនេះ ដែលជាតុលាការកំពូល ដើម្បីកែតម្រូវកំហុសអង្គច្បាប់នេះ និងដើម្បីធានាឲ្យបាននូវរដ្ឋបាលតុលាការត្រឹមត្រូវនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះ។

2. ស.ព.អ សូមសន្និដ្ឋានថា ច្បាប់ តក្កវិជ្ជា និងយុត្តិធម៌ តម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ទទួលយកបណ្តឹងសាទុក្ខនេះ និងអនុវត្តសិទ្ធិអំណាចជាប់មកជាមួយរបស់ខ្លួនដើម្បីបង្គាប់ឲ្យបញ្ជូនរឿងក្តីនេះទៅ អ.ជ.ស.ដ ដើម្បីជំនុំជម្រះ។

3. បណ្តឹងសាទុក្ខនេះមានភាពចាំបាច់ក្នុងផលប្រយោជន៍យុត្តិធម៌សម្រាប់ភាគី *ទាំងអស់* និងដើម្បីធានាភាពប្រាកដប្រជា និងសច្ចភាពផ្លូវច្បាប់ ដែលតម្រូវដោយគ្រប់ប្រព័ន្ធតុលាការ។ ការបដិសេធមិនទទួលយកបណ្តឹងនេះអាចនឹងដាក់រឿងក្តីនេះក្នុងភាពមិនច្បាស់លាស់ផ្នែកតុលាការជារៀងរហូត។ វាអាចដកសិទ្ធិជនរងគ្រោះ ទាំងជនរងគ្រោះរស់រានមានជីវិត និងជនរងគ្រោះដែលទទួលមរណកាលពីការទទួលបានការសម្រេចផ្នែកតុលាការដ៏ត្រឹមត្រូវយុត្តិធម៌ និងមិនលម្អៀង ចំពោះការទទួលខុសត្រូវរបស់ មាស មុត លើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើគាត់ ផ្អែកលើច្បាប់និងអង្គហេតុ។

4. ស.ព.អ សូមសន្និដ្ឋានថា អង្គជំនុំជម្រះនេះគួរបង្គាប់ឲ្យរឿងក្តីនេះបន្តទៅជំនុំជម្រះដោយមូលហេតុមួយចំនួន។ មូលហេតុសំខាន់បំផុតគឺ សេចក្តីសម្រេចរបស់ចៅក្រម អ.ប.ជ ទាំងប្រាំរូបដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ឬម្យ៉ាងវិញទៀត គឺអានុភាពនៃគោលជំហរស្វ័យប្រវត្តិដែលផ្តល់អាណត្តិថារឿងក្តីត្រូវបញ្ជូនបន្តទៅជំនុំជម្រះ។ ដោយហេតុថា ការចេញដីកាដំណោះស្រាយចំនួនពីរគឺមិនខុសច្បាប់នោះ ការចេញបែបនេះមិនជាឧបសគ្គផ្នែកច្បាប់ចំពោះការជំនុំជម្រះឡើយ។ ក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនត្រឹមតែអនុញ្ញាតនោះទេ ប៉ុន្តែប្រមើលឃើញថាដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរអាចនឹងត្រូវចេញផ្អែកលើការតែងតាំងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ចំនួនពីររូបដែលមានសិទ្ធិស្មើគ្នា និងមានឯករាជ្យភាព និងការបង្កើតយន្តការដំណោះស្រាយវិវាទដែលមានការអនុញ្ញាត។ ផ្អែកលើលក្ខណៈទាំងនេះ និងដោយពុំមានការហាមឃាត់ជាក់លាក់មិនឲ្យចេញដីកាដំណោះស្រាយពីរផ្ទុយគ្នានោះ ការសន្មតថាត្រូវតែមានដីកាដំណោះ

ស្រាយតែមួយ គឺជាការខកខានមិនបានផ្តល់តម្លៃពេញលេញទៅលើលក្ខណៈពិសេសមានតែមួយគត់របស់ក្របខណ្ឌ អ.វ.ត.ក។

5. ជាងនេះទៀត ប្រសិនបើ *សម្រាប់គោលបំណងវែកញែក* ការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរ *ពិតជា* បង្កើតបានជាការរំលោភក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក មែននោះ វាគឺជាកំហុសផ្នែកនីតិវិធី ដែលមិនធ្វើឱ្យអសុពលភាពដីកាដំណោះស្រាយ ឬធ្វើឱ្យខូចខាតដល់ដំណើរការនីតិវិធីច្បាប់ទាំងមូលនោះឡើយ។ ប្រសិនបើចាំបាច់ត្រូវមានដំណោះស្រាយណាមួយនោះ ដំណោះស្រាយនោះត្រូវបានផ្តល់ជូនដោយសេចក្តីពិចារណារបស់ អ.ប.ជ លើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយៗ។ ដំណោះស្រាយសមស្របសម្រាប់កំហុសផ្នែកនីតិវិធីបែបនេះ ត្រូវតែពិចារណាផ្អែកលើកត្តាមួយចំនួន ក្នុងនោះរួមមាន ថាតើការចេញនេះបានបណ្តាលឱ្យមានលទ្ធលអយុត្តិធម៌ជាក់ស្តែងផលប៉ះពាល់សំខាន់ចំពោះ មាស មុត ឬការរំលោភលើដំណើរការ ក៏ដូចជាភាពធ្ងន់ធ្ងរនៃបទចោទតម្លៃសង្គមក្នុងការរារាំងរឿងក្តីមិនឱ្យបន្តទៅជំនុំជម្រះ ផលប្រយោជន៍ និងសិទ្ធិរបស់ភាគី *ទាំងអស់* និងភាពសមាមាត្រនៃដំណោះស្រាយនេះទៅនឹងព្យសនកម្មដែលបានចោទប្រកាន់ ឬយ៉ាងណា។

6. ដូចដែលអង្គជំនុំជម្រះនេះបានអនុវត្តពីមុននូវសិទ្ធិអំណាចរបស់ខ្លួន ក្នុងការលើកលែងការចោទប្រកាន់ដែរ អង្គជំនុំជម្រះមានសិទ្ធិអំណាចដូចគ្នាដើម្បីបង្គាប់ថា សំណុំរឿង០០៣ត្រូវបន្តទៅជំនុំជម្រះ។ ការអះអាងផ្ទុយពីនេះ គឺជាការលើកឡើងថា អង្គការសហប្រជាជាតិ (“អសប”) និងរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតរចនាសម្ព័ន្ធតុលាការមួយដែលអសមត្ថភាព ដែលក្នុងនោះអង្គជំនុំជម្រះតុលាការកំពូលគ្មានសិទ្ធិអំណាច កែតម្រូវកំហុសអង្គច្បាប់ដែលប្រព្រឹត្តដោយអង្គជំនុំជម្រះជាន់ទាប ឬក្នុងការអនុវត្តវិធានការកែតម្រូវត្រឹមត្រូវតាមច្បាប់។ ស.ព.អ សន្និដ្ឋានថា អសប និងរាជរដ្ឋាភិបាលកម្ពុជាមិនបានបង្កើតប្រព័ន្ធបែបនេះទេ ហើយវាក៏មិនគួរត្រូវបានបកស្រាយតាមវិធីបែបនេះដោយចៅក្រមនៃតុលាការនេះដែរ។

## II. ប្រវត្តិនីតិវិធី[1]

## ក. កិច្ចស៊ើបសួរ និងការចេញដីកាដំណោះស្រាយ[2]

7. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ស.ព.អ ស្ដីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ទៅ ស.ច.ស[3] ដោយស្នើឱ្យបំពេញកិច្ចស៊ើបសួរចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែលមានឈ្មោះ មាស មុត និង ស៊ូ ម៉េត ជាជនសង្ស័យ[4]។

---

[1] ដើម្បីជួយដល់ អ.ជ.ត.ក ឯកសារសំអាងផ្លូវច្បាប់ទាំងអស់ សារណា និងឯកសារផ្សេងទៀត ដែលបានយោងនៅក្នុងបណ្ដឹងសាទុក្ខនេះ រួមមានឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង ០០៣ ត្រូវបានដាក់ជាឯកសារភ្ជាប់ (ក្នុង សំណុំរឿង ០០៤/២-**E004/2/6** សេចក្ដីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការចាំបាច់ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ២១ បានកត់សម្គាល់ថា "សំណុំរឿង [...] ពុំមានអត្ថិភាពនៅចំពោះមុខអង្គជំនុំជ្រះតុលាការកំពូលដែរ" ដោយសហេតុថាសំណុំរឿងនេះមិនត្រូវបានបញ្ជូនចេញពី អ.ប.ជ)។ បន្ថែមលើនេះទៀត ស.ព.អ សន្និដ្ឋានថា ការចូលមើលរបស់ អ.ជ.ត.ក ទៅក្នុងសម្ភារសំណុំរឿងផ្សេងទៀតទាំងអស់ គឺជាសមាសភាគសំខាន់នៃលទ្ធភាព និងការទទួលខុសត្រូវរបស់អង្គជនុំជម្រះនេះ ដើម្បីអនុវត្តយុត្តាធិការជាប់មកជាមួយរបស់ខ្លួន និងត្រូវបានតម្រូវឱ្យអង្គជំនុំជម្រះអនុវត្តតាមអាណត្តិរបស់ខ្លួន ក្នុងការធ្វើសេចក្ដីសម្រេចមួយដែលមានសំអាងហេតុមានព័ត៌មានគ្រប់ជ្រុងជ្រោយ លើបញ្ហានានានៅចំពោះមុខខ្លួន។ ច្បាប់មិនបានចែងហាមឃាត់ការចូលមើលបែបនេះទេ ហើយដូច្នេះ អង្គជំនុំជម្រះគួរបង្គាប់ឱ្យបញ្ជូនសំណុំរឿង ០០៣ មកកាន់អង្គជំនុំជម្រះ សម្រាប់គោលបំណងនៃបណ្ដឹងសាទុក្ខនេះ។ការចូលមើលនេះមិនរំលោភចំណាត់ថ្នាក់សម្ងាត់របស់ឯកសារទេ ដោយហេតុថា ឯកសារទាំងនោះនៅតែសម្ងាត់ និងគ្រាន់តែត្រូវបានពិចារណាដោយអង្គជំនុំជម្រះមួយនៃតុលាការដូចគ្នានឹងអាជ្ញាធរ ដែលបានផ្ដល់ចំណាត់ថ្នាក់ពីដើមដែរ។ ការសម្រេចថា អ.ជ.ត.ក មិនអាចចូលមើលឯកសារទាំងអស់នេះបាន ដរាបណាអង្គជំនុំជម្រះផ្សេងមួយទៀតមិនអនុញ្ញាតនោះ នឹងដកហូតសិទ្ធិអំណាចដែលជាប់មកជាមួយ និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងនាមជាតុលាការកំពូល។ និយាយម្យ៉ាងទៀត វានឹងធ្វើឱ្យអង្គជំនុំជម្រះនេះអសមត្ថភាពក្នុងការបំពេញកិច្ចក្នុងផលប្រយោជន៍យុត្តិធម៌ ដើម្បីធានាបាននូវសច្ចភាព និងភាពប្រាកដប្រជាផ្នែកច្បាប់។ (កត់សម្គាល់ថា ស.ព.អ មិនបានដឹងអំពីការសន្និដ្ឋានណាមួយរបស់ មាស មុត ទាក់ទងនឹងការចូលមើលរបស់ អ.ជ.ត.ក ក្នុងសំណុំរឿងនេះទេ។ ប៉ុន្តែ សំណើសុំថ្មីៗរបស់គាត់ទៅកាន់ អ.ជ.ត.ក សុំឱ្យបញ្ចប់រឿងក្ដី និងតារាងឯកសារសំអាងផ្លូវច្បាប់ដែលភ្ជាប់ជាមួយបង្ហាញថា គាត់យល់ថា អ.ជ.ត.ក អាចចូលមើលឯកសារសម្ងាត់បំផុត និងឯកសារសម្ងាត់ក្នុងសំណុំរឿង ០០៣។ ឬថា ប្រសិនបើអត់ទេ អ.ជ.ត.ក គួរអាចចូលមើលដើម្បីអនុវត្តយុត្តាធិការដែលជាប់មកជាមួយរបស់ខ្លួន។)

[2] នេះជាសេចក្ដីសង្ខេបយ៉ាងខ្លីនៃប្រវត្តិនីតិវិធីដែលពាក់ព័ន្ធបំផុត។ សម្រាប់សេចក្ដីលម្អិតជាច្រើនទៀតទាក់ទងនឹងដំណាក់កាលនៃកិច្ចស៊ើបសួរ សូមយោងទៅរកឯកសារ **D266/2.2** ឧបសម្ព័ន្ធ I: ប្រវត្តិនីតិវិធី (នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

[3] ឯកសារ **D1/1** សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី អំពីការដាក់ឯកសារស្ដីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ គ្រប់ទំព័រ។

8. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") យូ ប៊ុនឡេង និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") Siegfried Blunk បានជូនដំណឹងមកសហព្រះរាជអាជ្ញាថា ពួកគាត់បានពិចារណាថា កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ បានបិទបញ្ចប់ហើយ ("សេចក្តីជូនដំណឹងខែមេសា ឆ្នាំ២០១១")[5]។ បន្ទាប់ពីពេលនោះមក ស.ច.ស.ជ នៅតែប្រកាន់ជំហរថាកិច្ចស៊ើបសួរត្រូវបានបបិទញ្ចប់ ដោយបដិសេធមិនពិនិត្យរាល់ឯកសារដែលបានដាក់ទៅក្នុងសំណុំរឿងនេះក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[6] បើទោះបីជាកិច្ចស៊ើបសួរបានបន្តឡើងវិញដោយ ស.ច.ស.អ បម្រុង Laurent Kasper-Ansermet នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១[7] និងការធ្វើបន្តមកទៀតដោយ ស.ច.ស.អ Mark Harmon[8] និង Michael Bohlander[9] ជាបន្តបន្ទាប់ក៏ដោយ។

---

[4] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១០២។ ក្រោយមក ស៊ូ ម៉េត បានស្លាប់ ហើយការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងគាត់ត្រូវបានលើកលែង (*សូមមើល* ឯកសារ **D86/3** ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥)។

[5] ឯកសារ **D13** សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

[6] *សូមមើល* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ២ ("ឯកសារដែលបានប្រើនៅក្នុងដីកាដំណោះស្រាយនេះ មានសម្ភារដែលបានដាក់ទៅក្នុងសំណុំរឿងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នៅពេលសហចៅក្រមស៊ើបអង្កេតទាំងពីររូបបានឯកភាពគ្នាបញ្ចប់កិច្ចស៊ើបសួរ។ ដើម្បីធានាចំពោះតម្លាភាព និងសិទ្ធិរបស់ជនត្រូវចោទ យើងនឹងមិនប្រើឯកសារណាដែលបានដាក់ទៅក្នុងសំណុំរឿងក្រោយកាលបរិច្ឆេទនៃការបិទបញ្ចប់កិច្ចស៊ើបសួរទេ")។ *សូមមើលផងដែរ* ជើងទំព័រ១៧ *យោងខាងលើ* ពិភាក្សាអំពីផលប៉ះពាល់ដែលការធ្វើបែបនេះមានលើការវាយតម្លៃរបស់ ស.ច.ស.អ លើយុត្តាធិការបុគ្គល។

[7] ឯកសារ **D28** ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ៨ ផ្នែកសម្រេចសេចក្តី។ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស.ច.ស.អ បម្រុងបានចាប់ផ្តើមការងាររបស់ខ្លួនបន្ទាប់ពីការលាលែងរបស់ ស.ច.ស.អ Blunk ក្នុងខែតុលា ឆ្នាំ២០១១ (*សូមមើល* ឯកសារ **D266/2.1.150** *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។ ឯកសារ **D266/2.1.151** *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ* ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១)។

[8] *សូមមើល* ឯកសារ **D54** ដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣។ ឯកសារ **D55** ដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ (ដីកាទាំងពីរអនុញ្ញាតឲ្យបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣)។ *សូមមើលផងដែរ* ឯកសារ **D266/2.1.153** *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ* ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។ ឯកសារ **D266/2.1.148** *Mark Harmon ស្បថចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២។

[9] ជាឧទាហរណ៍ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ចៅក្រម Bohlander បានចេញអនុស្សរណៈអន្តរការិយាល័យចំនួនបីពង្រីកដីកាចាត់ឲ្យស៊ើបសួរជំនួសក្នុងសំណុំរឿង០០៣ អនុញ្ញាតឲ្យបំពេញកិច្ចស៊ើបសួរ (ឯកសារ **D59.13**, **D89.11**, **D114.4**) ភ្លាមៗបន្ទាប់ពីការតែងតាំងរូបគាត់ (*សូមមើល* ឯកសារ **D266/2.1.145** *ការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិថ្មី* ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥)។

9. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ស.ច.ស.អ បម្រុង Kasper-Ansermet បានជូនដំណឹងដល់ មាស មុត ថា គាត់ជាជនសង្ស័យនៅក្នុងកិច្ចស៊ើបសួរដែលកំពុងធ្វើ[10]។

10. ក្រោយការចុះបញ្ជីការខ្វែងយោបល់គ្នារវាង ស.ច.ស នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ ស.ច.ស.ជ បានបញ្ជូនសំណុំរឿងមកសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦(៤)នៃវិធានផ្ទៃក្នុង[11]។ ស.ព.អ បានបង្វិលឯកសារនេះត្រឡប់ទៅវិញដោយថ្លែងថា សេចក្តីជូនដំណឹងខែមេសា ឆ្នាំ២០១១ បានអស់សុពលភាពនៅពេល ស.ច.ស.អ បានចាប់ផ្តើមបំពេញកិច្ចស៊ើបសួរសាជាថ្មី ហើយកិច្ចស៊ើបសួរនោះនៅតែបើកចំហរ និង "ជាក់ស្តែងមិនទាន់ចប់សព្វគ្រប់នៅឡើយ"[12]។

11. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយ ដោយបានបំភ្លឺអំពីវិសាលភាពនៃកិច្ចស៊ើបសួរ និងបានប្តឹងបន្ថែមទៅ ស.ច.ស អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ (រួមទាំងអំពើរំលោភសេពសន្ថវៈ)[13]។

12. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ មាស មុត ត្រូវបានចោទប្រកាន់នៅចំពោះមុខ ដោយ ស.ច.ស.អ Michael Bohlander[14]។

13. នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស.ច.ស.អ បានបញ្ជូនសំណុំរឿងមកសហព្រះរាជអាជ្ញា បន្ទាប់ពីបានប្រកាសថា កិច្ចស៊ើបសួរបានបិទបញ្ចប់[15]។ បន្ទាប់មក សហព្រះរាជអាជ្ញាក៏បានដាក់ដីកាសន្និដ្ឋានស្ថាពរ[16]។

---

[10] ឯកសារ **D30** ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។

[11] ឯកសារ **D52** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") ឬ ("វិធាន")។

[12] ឯកសារ **D52/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៣-៧។

[13] ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤។

[14] ឯកសារ **D174** កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

[15] ឯកសារ **D256** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។ ឯកសារ **D225** សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ៦។ ឯកសារ **D252** សេចក្តីជូនដំណឹងលើកទី២ស្តីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ១៨-១៩។

[16] ឯកសារ **D256/6** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ គ្របទំព័រ។ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា

14. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស.ច.ស បានចេញដីកាដំណោះស្រាយដាច់ដោយឡែកនិងផ្ទុយគ្នា។ ខណៈដែល ស.ច.ស.ជ បានច្រានចោលបទចោទទាំងអស់ប្រឆាំង មាស មុត[17] ស.ច.ស.អ បានចោទប្រកាន់គាត់ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦[18]។

## ខ. បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបណ្ដឹងវិវាទជាបន្តបន្ទាប់មុនការជំនុំជម្រះ

15. បន្ទាប់ពីបណ្ដឹងឧទ្ធរណ៍របស់ភាគីនានាប្រឆាំងនឹងដីកាដំណោះស្រាយ[19] អ.ប.ជ បានចេញសេចក្ដីពិចារណារបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ទាំងអស់នោះនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១[20]។ ខណៈដែល

---

អន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ គ្រប់ទំព័រ។ *សូមមើលផងដែរ* ឯកសារ **D256/11** ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ (“ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពរ”) គ្រប់ទំព័រ។

[17] ការដកខ្លួនរបស់ ស.ច.ស.ជ ចេញពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ បាននាំឲ្យគាត់បដិសេធឯកសារណាដែលបានដាក់ក្នុងសំណុំរឿង ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលមិនអើពើនឹងភ័ស្តុតាងស៊ើបអង្កេតរយៈពេលប្រាំពីរឆ្នាំ ដែលបានប្រមូលជាពិសេសសម្រាប់រឿងក្ដីនេះ។ ដូចបានឆ្លុះបញ្ចាំងនៅក្នុងដីកាដំណោះស្រាយ ស.ច.ស.ជ ខកខានមិនបានពិចារណាព្រឹត្តិការណ៍ឧក្រិដ្ឋ និងទីតាំងឧក្រិដ្ឋកម្មនានាដែលបានប្ដឹងទៅគាត់ រួមទាំងការចោទប្រកាន់នានាទាក់ទងនឹងមន្ទីរសន្តិសុខទឹកសាប ការដ្ឋាននិងសហករណ៍តំបន់រាម ការបោសសម្អាតក្នុងកងពល ១១៧ និងកម្មាភិបាលតំបន់ ៥០៥ ក្នុងខេត្តក្រចេះ ការបោសសម្អាតនៅសេនាធិការ និងកងពលយោធាជាច្រើនទៀត ដែលបានបញ្ជូនមក ស-២១ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាលទ្ធផល ការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ អំពីទំហំ ភាពធ្ងន់ធ្ងរ វិសាលភាព និងផលប៉ះពាល់នៃឧក្រិដ្ឋកម្ម ដែល មាស មុត អាចត្រូវដាក់ឲ្យទទួលខុសត្រូវ ត្រូវបានប៉ះពាល់យ៉ាងខ្លាំង ហើយគាត់បានទម្លាក់ចោលការចោទប្រកាន់ទាំងអស់។ *សូមមើល* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២, ៤២៧-៤៣០។ ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ (“បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់”) កថាខណ្ឌ ៦៣-៨២។ ឯកសារ **D266/16.1 & D267/21.1** ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោង 13.38.34-13.43.43 (សេចក្ដីសន្និដ្ឋានបណ្ដឹងឧទ្ធរណ៍របស់អយ្យការនៅចំពោះមុខ អ.ប.ជ)។ ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ (“សេចក្ដីពិចារណា”) យោបល់ចៅក្រម Olivier Beauvallet និង Kang Jin Baik (“យោបល់របស់ចៅក្រមអន្តរជាតិ”) កថាខណ្ឌ ២៤៧-២៤៨។

[18] ឯកសារ **D267** ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) កថាខណ្ឌ ២៥៦-២៦៤។

[19] *សូមមើល* ឧទាហរណ៍ ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ គ្រប់ទំព័រ។ ឯកសារ **D267/3** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រម

អ.ប.ជ "មិនអាចរកសំឡេងគាំទ្រពីចៅក្រម (បួន) រូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តី ដោយផ្អែកលើសំអាងហេតុរួមមួយបាន"[21] ចៅក្រម អ.ប.ជ ទាំងប្រាំរូបបានតម្កល់សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[22] ដែលពួកគាត់បានបញ្ជាក់ឡើងវិញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១[23]។ លើសពីនេះទៀត ចៅក្រមពីររូបបានសន្និដ្ឋានថាដីកាសម្រេចលើកលែងចោទប្រកាន់មិនពេញលេញ និង "ផិតតាមដោយអនីត្យានុកូលភាព" ហើយហេតុដូច្នេះ គ្មានសុពលភាព និងទុកជាមោឃៈ[24] ខណៈដែលចៅក្រមដែលនៅសល់បីរូបទៀតបានសម្រេចថា វាមានសុពលភាព[25]។

16. ផ្អែកជាចំបងលើទស្សនៈជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ស.ព.អ បានរៀបចំដាក់សម្ភារមុនពេលជំនុំជម្រះរបស់ខ្លួន ដូចដែលបានតម្រូវដោយវិធានផ្ទៃក្នុង។ ប៉ុន្តែ អ.ជ.ស.ដ បានថ្លែងថាខ្លួននឹង "មិនទទួលយកសំណើសុំនានាពីភាគីឡើយ"

---

ស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ គ្រប់ទំព័រ។ ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ") គ្រប់ទំព័រ។ ឯកសារ **D266/16.1 & D267/21.1** ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ គ្រប់ទំព័រ។ ឯកសារ **D266/17.1 & D267/22.1** ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ គ្រប់ទំព័រ។ ឯកសារ **D266/18.1 & D267/23.1** ប្រតិចារឹក ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ គ្រប់ទំព័រ។

[20] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា។

[21] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១១០។

[22] **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, នៃ ធុល, និង ហួត វុទ្ធី ("យោបល់របស់ចៅក្រមជាតិ") កថាខណ្ឌ ១១៥ ("ន័យដូចមានចែងក្នុងវិធាន ៧៧(១៣) ខាងលើ ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា *មានសុពលភាពដូចគ្នា*" (គូសបញ្ជាក់បន្ថែម))។ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១៩, ២៦២, ២៨៤ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាព ដោយសារតែដីកានេះមានសុពលភាពជាសារធាតុ ហើយមានអនុលោមភាពជាមួយក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក") ៣៤២-៣៤៣ (សន្និដ្ឋានថាមានការសម្រេចជាឯកច្ឆន្ទ*តាមព្រឹត្តន័យ*៖ ទោះបីជាមានសំអាងហេតុខុសគ្នា ចៅក្រមជាតិ និងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសម្រេចស្របគ្នាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និងបានតម្កល់វាជាឯកច្ឆន្ទ) ផ្នែកសម្រេចសេចក្តី ត្រង់ទំព័រ ២០៧ (ភាសាខ្មែរ)។

[23] ឯកសារ **D269/4** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ កថាខណ្ឌ ៣០។

[24] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១៩ (បានសន្និដ្ឋានថាដីកាសម្រេចលើកលែងចោទប្រកាន់មិនពេញលេញ និងគ្មានសុពលភាព ដោយហេតុថា មិនបានអើពើចំពោះភស្តុតាងរយៈពេលប្រាំពីរឆ្នាំ និងការចោទប្រកាន់ព្រហ្មទណ្ឌដែលប្តឹងមក ស.ច.ស.ជ យ៉ាងត្រឹមត្រូវ។) ២៥០ ("ដីកាសម្រេចលើកលែងចោទប្រកាន់ ជាដីកាសម្រេចមិនពេញលក្ខណៈ ផិតដាមដោយអនីត្យានុកូលភាព ដែលត្រូវចាត់ទុកជាមោឃៈ") កថាខណ្ឌ ២៥១, ២៦២, ២៨៤, ៣៤២, ផ្នែកសម្រេចសេចក្តី ទំព័រ ២០៧ (ភាសាខ្មែរ)។

[25] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ១១៥។

ដោយហេតុថា ខ្លួនមិនត្រូវបានជូនដំណឹងអំពីសេចក្តីពិចារណារបស់ អ.ប.ជ និងមិនបានទទួលសំណុំរឿង[26]។

17. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស.ព.អ បានស្នើសុំជាផ្លូវការទៅ ស.ច.ស ឲ្យបញ្ជូនសំណុំរឿងទៅកាន់ អ.ជ.ស.ដ ស្របតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង[27] ដែល ស.ច.ស បានបដិសេធនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ដោយបានលើកឡើងថាខ្លួនមិនមានយុត្តាធិការក្នុងការពិចារណាលើសំណើនេះទេ និងថា សេចក្តីពិចារណា "មិនមានគោលដៅច្បាស់លាស់" សម្រាប់ដំណោះស្រាយត្រឹមត្រូវអំពីរឿងក្តីនេះឡើយ[28]។ ស.ច.ស បានលើកឡើងបន្ថែមទៀតថា ប្រសិនបើមិនមានមធ្យោបាយណាផ្សេង ដើម្បីជម្រុញដល់សំណុំរឿងនេះឲ្យទៅជំនុំជម្រះ ឬទៅដល់ការបញ្ចប់ ប្រសិនបើត្រូវបានស្នើសុំឲ្យពិចារណាលើបញ្ហានេះនៅពេលអនាគត ពួកគាត់នឹងមិនបញ្ជូនរួមគ្នា ឬដាច់ដោយឡែកពីគ្នានូវរឿងក្តីនេះទៅកាន់ អ.ជ.ស.ដ ឡើយ[29]។

18. នៅខែមិថុនា ឆ្នាំ២០២១ ទាំង ស.ព.អ និង មាស មុត បានដាក់សំណើសុំឲ្យ អ.ប.ជ ប្រកាសការកំណត់ចុងក្រោយ ដែលនឹងបិទបញ្ចប់ជាស្ថាពរនូវដំណាក់កាលមុនការជំនុំជម្រះនៃសំណុំរឿង ០០៣ ដោយមានភាពប្រាកដប្រជា និងសច្ចភាពផ្នែកច្បាប់[30]។ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១

---

[26] ឯកសារ **D271/1.1.41** សារអេឡិចត្រូនិកពីក្រឡាបញ្ជីរបស់ អ.ជ.ស.ដ លឹម ស៊ុយហុង មានចំណងជើងថា "កម្មវត្ថុ៖ សំណើសុំពន្យារពេលដាក់បញ្ជីឈ្មោះសាក្សីនិងអ្នកជំនាញអនុលោមតាមវិធាន ៨០" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ នៅម៉ោង ៧:២៧ ល្ងាច ដែលត្រូវបានចេញដើម្បីឆ្លើយតបទៅនឹងសំណើរបស់ ស.ព.អ សុំពន្យារពេលវេលាដាក់បញ្ជីឈ្មោះសាក្សីនិងអ្នកជំនាញអនុលោមតាមវិធាន ៨០។

[27] ឯកសារ **D270** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឲ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

[28] ឯកសារ **D270/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ("សេចក្តីសម្រេចបដិសេធរបស់ ស.ច.ស") កថាខណ្ឌ ២៥, ៤០។

[29] ឯកសារ **D270/7** សេចក្តីសម្រេចបដិសេធរបស់ ស.ច.ស កថាខណ្ឌ ៣៥-៣៧, ៤២ ថ្លែងថា "ជាចម្រើសចុងក្រោយបំផុត (*ultima ratio*) និងបន្ទាប់ពីដំណើរការអស់នូវយុត្តាធិការទាំងឡាយ" ពួកគាត់នឹងពិចារណា "ថាតើពួកយើងមានយុត្តាធិការដែលនៅសេសសល់ពិសេសណាមួយដែលជាមធ្យោបាយចុងក្រោយបំផុត ក្នុងការបិទបញ្ចប់សំណុំរឿងដោយខ្លួនឯង" ប៉ុន្តែ "ពិតជាមិនចង់ស្ថិតក្នុងស្ថានភាពបែបនោះឡើយ"។ *សូមមើលផងដែរ* កថាខណ្ឌ ១៩។

[30] **D271/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ("សំណើរបស់ ស.ព.អ សុំឲ្យ អ.ប.ជ បិទបញ្ចប់")។ ឯកសារ **D272** សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ("សំណើរបស់ មាស មុត សុំឲ្យបញ្ចប់")។

អ.ប.ជ បានសម្រេចថា សំណើទាំងពីរនេះមិនអាចទទួលយកបាន[31]។ អ.ប.ជ បានបញ្ជាក់សេចក្តីពិចារណារបស់ខ្លួនឡើងវិញ និងបានប្រកាសថា អ.ប.ជ បានបំពេញតួនាទីរបស់ខ្លួនទាំងអស់ស្រប តាមក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ហើយ[32]។

19. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ស.ច.ស បានជូនដំណឹងដល់ភាគីនានាថា ប្រសិនបើ ស.ព.អ មិនមានបំណងប្តឹងរឿងក្តីនេះទៅ អ.ជ.ត.ក ទេ "បញ្ហាតែមួយគត់" ដែលត្រូវកំណត់គឺថាតើ ស.ច.ស មានយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់រឿក្តីងនេះដែរឬអត់[33]។ ស.ព.អ បានជូនដំណឹងទៅ ស.ច.ស អំពីបំណងរបស់គាត់ក្នុងការប្តឹងសាទុក្ខ[34]។

## III. ច្បាប់ជាធរមាន

### ក. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

*យុត្តាធិការដែលមានជាប់មកជាមួយ*

20. កិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជា គឺជាភាគីហត្ថលេខី[35]។

---

[31] **D271/5 & D272/3** សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ("សេចក្តីសម្រេចរួមរបស់ អ.ប.ជ") កថាខណ្ឌ ៧៨ ផ្នែកសម្រេចសេចក្តី។

[32] **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧៦។ ទាក់ទងនឹងភារកិច្ចរបស់ខ្លួន *សូមមើល* កថាខណ្ឌ ៦៤, ៦៨។

[33] **D273** ដីកាបង្គាប់ឲ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ("ដីកាបង្គាប់របស់ ស.ច.ស ឲ្យដាក់សេចក្តីសន្និដ្ឋានដើម្បីបញ្ចប់សំណុំរឿង") កថាខណ្ឌ ៥-៧ KH 01676520។

[34] **D273/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេត សុំឲ្យប្រកាសថាតើសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងប្តឹងទៅអង្គជំនុំជម្រះតុលាការកំពូលដែរឬទេ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១។

[35] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង

21. វិធាន ២១(១) នៃវិធានផ្ទៃក្នុង ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី *ទាំងអស់* ដូចមានចែងក្នុងផ្នែកពាក់ព័ន្ធ ដូចខាងក្រោម៖

> ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលជាធរមានទាំងអស់ ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក។ ក្នុងបរិបទនេះ ៖
>
> ក- ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែត្រឹមត្រូវយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...]

22. នៅក្នុងសំណុំរឿង ០០៤/២ អង្គជំនុំជម្រះនេះ បានប្រើយុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួនជាប្រយោជន៍នៃយុត្តិធម៌ និងភាពត្រឹមត្រូវ ដោយសម្រេចថា៖

> ផ្អែកតាមនីតិរដ្ឋទូទៅថា ជាការមិនសមស្របដែលបញ្ហាផ្លូវច្បាប់ត្រូវបានបន្សល់ទុកមិនដោះស្រាយ។ តុលាការចុងក្រោយ គឺអង្គជំនុំជម្រះតុលាការកំពូល ដែលមានកាតព្វកិច្ចស្រាយបំភ្លឺ និងបញ្ជាក់អំពីភាពស្ថាពរនៃស្ថានការណ៍បែបនេះ។ ការជាប់គាំងផ្នែកច្បាប់ សឱ្យឃើញពីភាពបរាជ័យនៃប្រព័ន្ធតុលាការក្នុងការផ្ដល់ឧបាស្រ័យ។ [...] អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា នេះគឺជាកាតព្វកិច្ចក្នុងនាមជាអង្គជំនុំជម្រះឧទ្ធរណ៍ និងតុលាការជាន់ខ្ពស់ចុងក្រោយក្នុងការផ្ដល់ឧបាស្រ័យផ្លូវច្បាប់ និងធ្វើការកំណត់ចុងក្រោយក្នុងរឿងក្ដី ដែលលក្ខន្តិកៈ ឬច្បាប់ពុំមានចែង ឬមិនច្បាស់លាស់។ នេះគឺជាមុខងាររបស់តុលាការចុងក្រោយក្នុងការផ្ដល់ភាពប្រាកដប្រជាផ្លូវច្បាប់ដល់ភាគី។

---

អ.វ.ត.ក") មាត្រា ១២(២)។ *សូមមើលផងដែរ* ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី ដែលមានបទប្បញ្ញត្តិស្រដៀងគ្នាមួយ និងអនុវត្ត*តាមការកែប្រែចាំបាច់* ចំពោះ អ.ជ.ត.ក ដូចមានចែងក្នុងមាត្រា ៣៧ថ្មី។

> ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកជាការចាំបាច់ក្នុងការផ្តល់ភាពប្រាកដប្រជា និងភាពច្បាស់លាស់លើបញ្ហាច្បាប់ដែលសំខាន់បំផុត ដែលបានបង្ហាញក្នុងបណ្តឹងសាទុក្ខភ្លាមៗនេះថាកម្រងឯកសារច្បាប់ អ.វ.ត.ក ពុំបានដោះស្រាយជាក់លាក់ឡើយ។ [...] អង្គជំនុំជម្រះពិចារណាឃើញថាដំណោះស្រាយគឺជាភាពចាំបាច់លើសលុប ដូច្នេះអង្គជំនុំជម្រះនឹងត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវ ព្រមទាំងទទួលយកបណ្តឹងសាទុក្ខភ្លាមៗនេះក្នុងគោលបំណងតែមួយគត់គឺដើម្បីធានាថា សច្ចភាពផ្លូវច្បាប់និងភាពស្ថាពរត្រូវទទួលបាន នៅក្នុងការកំណត់សម្រេចលើរឿងក្តីនេះ និងដើម្បីលើកកម្ពស់សុចរិតភាពនៃស្ថាប័ន អ.វ.ត.ក[36]។

23. អ.ប.ជ ធ្លាប់បានសម្រេចថា នៅពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់តាមវិធាន ២១៖

> ភាគីប្តឹងឧទ្ធរណ៍ ត្រូវបង្ហាញថា កាលៈទេសៈជាក់លាក់នៃសំណុំរឿងរបស់ខ្លួនតម្រូវឱ្យមានការជួយអន្តរាគមន៍ពីអង្គជំនុំជម្រះ នៅដំណាក់កាលដែលដាក់បណ្តឹងឧទ្ធរណ៍ ដើម្បីចៀសវាងពីព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[37]។

24. តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ក៏បានទទួលស្គាល់អំណាចរបស់អង្គជំនុំជម្រះក្នុងការប្រើប្រាស់យុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួន ក្នុងការសម្រេចលើបញ្ហាណាមួយដែលពុំមានបទប្បញ្ញត្តិលក្ខន្តិកៈចែងជាក់លាក់។ ចំណុចនេះ រួមទាំងកាលៈទេសៈនានាដែលពុំមានតុលាការ

---

[36] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង (“សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ អ.ជ.ត.ក”) កថាខណ្ឌ ៦៤-៦៥។

[37] *សូមមើល ឧទាហរណ៍* ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៧១ (ឯកច្ឆន្ទ)។ ឯកសារ **D128/1/9** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ២០ (ឯកច្ឆន្ទ)។ សំណុំរឿង ០០៤-ឯកសារ **D205/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ ៧។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **D345/5/11** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចលើសំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១១។

ណាមួយមានអំណាចប្រកាសលើបញ្ហានោះដោយសារ "ការរារាំងផ្លូវច្បាប់ ឬឧបសគ្គផ្នែកអនុវត្ត" និងក្នុងពេលចាំបាច់ដែលត្រូវដោះស្រាយនូវចន្លោះប្រហោងដែលអាចមាន ក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ឬដើម្បីធានាថា យុត្តិធម៌មិនត្រឹមតែធ្វើបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវ*បានគេមើលឃើញ*ថា សម្រេចបានផងដែរ[38]។

---

[38] **<u>STL</u>**: *ចំពោះបញ្ហារបស់ El Sayed*, CH/AC/2010/02 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះទាក់ទងនឹងយុត្តាធិការ និងសិទ្ធិប្តឹង អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៤៥ ("[យុត្តាធិការជាប់មកជាមួយ] និយាយឲ្យចំ អាចអនុវត្តបាននៅពេលដែលគ្មានតុលាការណាផ្សេងមានអំណាចប្រកាសលើបញ្ហាច្បាប់ដែលកើតឡើងដោយចៃដន្យ ដែលបណ្តាលមកពីការរារាំងផ្នែកច្បាប់ ឬឧបសគ្គផ្នែកអនុវត្ត។ ហេតុនេះ យុត្តាធិការជាប់មកជាមួយ គឺជាយុត្តាធិការបំពេញបង្គ្រប់ ឬយុត្តាធិការដែលកើតមានដោយចៃដន្យដែលបំពេញឲ្យយុត្តាធិការចំបង និងចំបាច់ទៅតាមតម្រូវការបែបអាជ្ញាបញ្ញាក្នុងការធានាដល់ការគ្រប់គ្រងរដ្ឋបាលតុលាការឲ្យបានល្អ និងត្រឹមត្រូវយុត្តិធម៌ រួមទាំងការគោរពយ៉ាងពេញលេញចំពោះសិទ្ធិមនុស្សផង តាមដែលអាចអនុវត្តបាន ចំពោះអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធីអន្តរជាតិដែលតុលាការនេះមានយុត្តាធិការយ៉ាងច្បាស់លាស់") ៤៦, ៤៨។ **<u>ICTY</u>**: *រដ្ឋអាជ្ញា ទល់នឹង Blagojević & Jokić*, IT-02-60-T សេចក្តីសម្រេចលើញត្តិមេធាវីការពារក្តីឯករាជ្យរបស់ Vidoje Blagojević ស្នើឲ្យបង្គាប់ទៅក្រឡាបញ្ជីឲ្យតែងតាំងសហមេធាវីការពារក្តី និងសហមេធាវីការពារក្តីនាំមុខថ្មី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ១១២, ១១៤ (បញ្ជាក់អះអាងថា ខណៈដែលអង្គជំនុំជម្រះសាលាដំបូង មិនតម្រូវឲ្យចាត់វិធានការបន្ថែម អង្គជំនុំជម្រះនេះមានផលប្រយោជន៍ជាច្រើន និងការប្តេជ្ញាក្នុងការធានាថា "យុត្តិធម៌មិនត្រឹមតែធ្វើបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវ*បានគេមើលឃើញ*ថា សម្រេចបានផងដែរ" អាស្រ័យហេតុនេះ ក៏បានបង្គាប់ឲ្យមានវិធានការពិសេសនានាដែលត្រូវធ្វើដើម្បីតំណាងឲ្យផលប្រយោជន៍ពេញលេញរបស់ជនជាប់ចោទ)។ *រដ្ឋអាជ្ញា ទល់នឹង Beqaj*, IT-03-66-T-R77 សាលក្រមលើការចោទប្រកាន់អំពីការប្រមាថ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៩ ("អង្គជំនុំជម្រះនានារបស់តុលាការនេះបានបញ្ជាក់អះអាងស្របគ្នាចំពោះអំណាចជាប់មកជាមួយរបស់តុលាការនេះ ដែលកើតមានឡើងដោយឯករាជ្យពីសេចក្តីយោងលក្ខន្តិកៈណាមួយ [...] គឺជាការចាំបាច់ដើម្បីធានាថា ការប្រើប្រាស់យុត្តាធិការរបស់តុលាការមិនត្រូវបានរារាំង ហើយមុខងារជាមូលដ្ឋានរបស់តុលាការត្រូវបានការពារ") ១០-១២ (និងយុត្តិសាស្ត្រដែលបានយោង) ១៣ ("ចៅក្រមរបស់តុលាការនេះប្រើអំណាចជាប់មកជាមួយដើម្បីចាត់វិធានការចាំបាច់នានា ដើម្បីធានាចំពោះសុចរឹតភាពនៃកិច្ចដំណើរការនីតិវិធីដែលជាចុងក្រោយរក្សាបាននូវការគោរពចំពោះយុត្តិធម៌")។ **<u>ICTR</u>**: *Barayagwiza ទល់នឹងរដ្ឋអាជ្ញា* ICTR-97-19-AR72 សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ("សាលដីកាខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្នុងរឿងក្តី *Barayagwiza*") កថាខណ្ឌ ៧៦ ("វាត្រូវបានទទួលស្គាល់ជាទូទៅថា តុលាការនានាមានអំណាចគ្រប់គ្រងដែលអាចប្រើប្រាស់ក្នុងផលប្រយោជន៍នៃយុត្តិធម៌ [...]។ ការប្រើប្រាស់អំណាចគ្រប់គ្រងដូច្នេះ បំរើឲ្យមុខងារបី៖ គឺផ្តល់ដំណោះស្រាយមួយចំពោះការរំលោភសិទ្ធិជនជាប់ចោទ គឺដើម្បីធ្វើឲ្យរាងចាលកុំឲ្យមានការប្រព្រឹត្តខុសនៅពេលអនាគត និងដើម្បីលើកកម្ពស់សុចរឹតភាពនៃដំណើរការតុលាការ")។ *រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន* ICTR-98-44-PT សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់ André Rwamakuba និងវិសោធនកម្មដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ ("សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Karemera*") កថាខណ្ឌ ២២។

*ការរួចផុតពីលក្ខខណ្ឌតម្រូវស្តីពីការប្រើប្រាស់ដំណោះស្រាយអស់លទ្ធភាព*

25. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា ទោះបីជាអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបចែងថា បញ្ហាមួយអាចត្រូវបញ្ជូនទៅតុលាការតែនៅពេលណាក្រោយពីដំណោះស្រាយក្នុងស្រុកត្រូវបានប្រើប្រាស់អស់លទ្ធភាពក៏ដោយ នៅពេលដែលវាអនុវត្តចំពោះការការពារសិទ្ធិមនុស្ស វិធានស្តីពីការប្រើប្រាស់អស់លទ្ធភាព "ត្រូវអនុវត្តក្នុងកម្រិតនៃភាពបត់បែនណាមួយ និងដោយមិនមានទម្រង់និយមហួសហេតុ" ដោយហេតុថាកាលៈទេសៈពិសេសនានាអាចឱ្យអ្នកដាក់ពាក្យប្តឹងរួចផុតពីកាតព្វកិច្ចនេះ[39]។

26. តុលាការសិទ្ធិមនុស្សអន្តរ-អាមេរិកាំងបានសម្រេចថា ក្នុងរឿងក្តីទាក់ទងនឹងការរំលោភណាមួយដែលអាចមានលើសិទ្ធិដែលត្រូវការពារជាក់លាក់ វិធានស្តីពីការប្រើប្រាស់អស់លទ្ធភាពជាមុន មិនត្រូវបានតម្រូវឡើយ នៅពេលដែលការពឹងផ្អែកលើដំណោះស្រាយដែលអាចមានទាំងនោះ អាចមិនមានប្រសិទ្ធភាព ឬមិនប្រាកដប្រជា[40]។

---

[39] *សូមមើល ឧទាហរណ៍* Sejdovic *ទល់នឹង ប្រទេសអ៊ីតាលី* No. 56581/00 សាលក្រម (អង្គជំនុំជម្រះតុលាការកំពូល) ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៤៤-៤៥, ៥៥ (តុលាការមានកាតព្វកិច្ចស្វែងរកដំណោះស្រាយ កាសន្និដ្ឋានដែលថាដំណោះស្រាយ "ត្រូវបរាជ័យ និងថាមានឧបសគ្គជាសត្យានុម័ត ក្នុងការប្រើប្រាស់ដំណោះស្រាយនោះដោយអ្នកដាក់ពាក្យប្តឹង") បង្កើតបានជា "កាលៈទេសៈពិសេស")។ *Akdivar និង អ្នកផ្សេងទៀត ទល់នឹង ប្រទេសតួគី* លេខ. 21893/93 សាលក្រម (អង្គជំនុំជម្រះតុលាការកំពូល) ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៦ កថាខណ្ឌ ៦៦-៦៧ ("មិនមានកាតព្វកិច្ចត្រូវស្វែងរកដំណោះស្រាយដែលមិនពេញលេញ ឬមិនមានប្រសិទ្ធភាពនោះទេ") រួមទាំងការអនុវត្តផ្នែករដ្ឋបាល ដែល "មានលក្ខណៈធ្វើឱ្យកិច្ចដំណើរការនីតិវិធីក្លាយទៅជាឥតប្រយោជន៍ ឬមិនមានប្រសិទ្ធភាព")។ *Vaney ទល់នឹង ប្រទេសបារាំង* លេខ. 53946/00 សាលក្រម ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ៥៣ (លក្ខខណ្ឌតម្រូវនៃការប្រើប្រាស់អស់លទ្ធភាពត្រូវបានដកចេញដោយហេតុថាវាបានធ្វើឱ្យអ្នកដាក់ពាក្យប្តឹងជាប់ក្នុង "រង្វង់ដ៏អាក្រក់") ដែលការបរាជ័យនៃដំណោះស្រាយមួយ បានបង្ខំគាត់ឱ្យស្វែងរកដំណោះស្រាយមួយទៀត) អនុវត្តតាមដោយ *Kaić និងអ្នកផ្សេងទៀត ទល់នឹង ប្រទេសក្រូអាត* លេខ. 22014/04 សាលក្រម ចុះថ្ងៃទី១៧ កក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣២ និង *Simaldone ទល់នឹង ប្រទេសអ៊ីតាលី* លេខ. 22644/03 សាលក្រម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ៤៤។

[40] *Las Palmeras ទល់នឹងប្រទេសកូឡុំប៊ៀ សាលក្រម* (អង្គសេចក្តី) ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០១ កថាខណ្ឌ ៥៧-៥៨ (មន្ត្រីប៉ូលីសជាតិដែលត្រូវឆ្លើយដាក់នៅក្នុងព្រឹត្តិការណ៍បានរារាំង ឬបដិសេធមិនព្រមសហការឱ្យបានត្រឹមត្រូវជាមួយនឹងការស៊ើបអង្កេត។ តុលាការលើកឡើងថា "វាមិនគ្រប់គ្រាន់ទេដែលថា ដំណោះស្រាយបែបទាំងនោះមានអត្ថិភាពជាផ្លូវការ វាត្រូវតែជាដំណោះស្រាយមានប្រសិទ្ធភាព [...] ដែល ផ្អែកលើ [...] កាលៈទេសៈពិសេសនៃរឿងក្តីណាមួយនោះ បញ្ជាក់ថាមិនមានភាពច្បាស់លាស់ មិនអាចត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពឡើយ"។ *Velásquez-Rodríguez ទល់នឹង* *Honduras*, សាលក្រម (អង្គសេចក្តី) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ កថាខណ្ឌ ៦៨ ("នៅពេលគេបង្ហាញថា ដំណោះស្រាយត្រូវបានបដិសេធដោយមូលហេតុតិចតួច ឬដោយមិនមានការពិនិត្យលើអង្គសេចក្តី [...] ការស្វែងរកដំណោះស្រាយទាំងអស់នោះ ក្លាយជាទម្រង់ការគ្មានអត្ថន័យ") ៨០ (សន្និដ្ឋានថា "ទោះបីជាអាចជាដំណោះស្រាយផ្អែកច្បាប់នៅក្នុងរឿងក្តី Honduras ដែលជាទ្រឹស្តី

27. តុលាការកំពូលសហរដ្ឋអាមេរិក និងតុលាការសហព័ន្ធផ្សេងទៀតបានទទួលស្គាល់ករណីលើកលែងនានាចំពោះ "ទ្រឹស្តីនៃការប្រើប្រាស់អស់លទ្ធភាព"[41] រួមបញ្ចូលស្ថានភាពដែលក្នុងនោះដំណោះស្រាយអាចមិនគ្រប់គ្រាន់ ដោយសារតែ (i) ទីភ្នាក់ងារដែលជាកន្លែងស្វែងរកដំណោះស្រាយបានបង្ហាញឲ្យឃើញថាមានលក្ខណៈលម្អៀង ឬថាម្យ៉ាងវិញទៀតនោះ បានកំណត់រួចហើយលើបញ្ហានៅចំពោះមុខខ្លួន[42] (ii) ការស្វែងរកដំណោះស្រាយគឺជាការឥតប្រយោជន៍[43] ឬ (iii) ការប្រើប្រាស់អស់លទ្ធភាពអាចបណ្ដាលឲ្យមានព្យសនកម្មមិនអាចជួសជុលបាន[44]។

## ខ. បទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ

28. អ.ប.ជ បានសន្និដ្ឋានថា "គេបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិថាចំពោះបណ្ដឹងឧទ្ធរណ៍ ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេចថាតើសេចក្ដីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ"[45]។ អ.ជ.ត.ក បានសម្រេច

---

បានអនុញ្ញាតឲ្យបុគ្គលម្នាក់ត្រូវបានឃុំឃាំងដោយអាជ្ញាធរត្រូវបានរកឃើញក្ដី ក៏ដំណោះស្រាយទាំងនោះមិនមានប្រសិទ្ធភាពក្នុងករណីនៃការបាត់ខ្លួន ដោយហេតុថា [...] អាជ្ញាធរដែលពួកគេត្រូវបាននាំមកតទល់នោះ មិនអើពើនឹងពួកគេ")។ *Velásquez-Rodríguez ទល់នឹង Honduras*, សាលក្រម (អញ្ញត្តិកម្ម) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ កថាខណ្ឌ ៩៣ ("វិធាននៃការប្រើប្រាស់អស់លទ្ធភាពជាមុន មិនត្រូវនាំទៅរកភាពជាប់គាំង ឬការពន្យារពេល ដែលនឹងធ្វើឲ្យសកម្មភាពអន្តរជាតិគាំទ្រដល់ជនរងគ្រោះដែលគ្មានការការពារខ្លួនទៅជាគ្មានប្រសិទ្ធភាពនោះទេ។")។

[41] លទ្ធិច្បាប់ដែលរារាំងដើមបណ្ដឹងមិនឲ្យដាក់សំណើសុំការពិនិត្យតាមផ្លូវតុលាការ មុនពេលឆ្លងកាត់ដំណើរការរដ្ឋបាលត្រឹមត្រូវ។ *សូមមើល* McKart *ទល់នឹង U.S.*, 395 U.S. ១៨៥, ១៩៣ (១៩៦៩)។

[42] *McCarthy ទល់នឹង Madigan និងគូកន*, 503 U.S. ១៤០, ១៤៨ (១៩៩២)។ *Gibson និងគូកន ទល់នឹង Berryhill និងគូកន*, 411 U.S. ៥៦៤, ៥៧៥ n. ១៤, ៥៧៨-៥៧៩ (១៩៧៣)។

[43] *Mullins Coal Co. ទល់នឹង Clark,* 759 F.2d ១១៩២, ១១៩៦ (4th Cir. ១៩៨៥) ("បណ្ដឹងវិវាទមិនចាំបាច់ត្រូវការដំណោះស្រាយរដ្ឋបាលឲ្យអស់លទ្ធភាពនោះទេ នៅក្នុងករណីដែលការស្វែងរករបស់ខ្លួននឹងទៅជាកាយវិការឥតប្រយោជន៍។")។

[44] Robert Power, "ជំនួយពេលខ្លះនៅប្រកៀកនឹងដៃ (Help is Sometimes Close at Hand): បញ្ហានៃការប្រើប្រាស់អស់លទ្ធភាព និងដំណោះស្រាយទំនោរ (The Exhaustion Problem and the Ripeness Solution)" ឆ្នាំ១៩៨៧ ព្រឹត្តិប័ត្រច្បាប់សាកលវិទ្យាល័យ Illinois ៥៤៧, ៥៩០-៥៩២ ("ប្រហែលជាមានតែព្យសនកម្មទាំងឡាយណាដែលពិសេសប៉ុណ្ណោះ ប្រសិនបើមិនមែនជាឯកលក្ខណៈ និងមិនអាចជួសជុលនៅពេលក្រោយ ស្ថិតនៅក្នុងករណីលើកលែងនេះ។ [...] ព្យសនកម្មនោះត្រូវតែទាំងមានលក្ខណៈមិនធម្មតា និងមិនអាចជួសជុលបាន ក្នុងអត្ថន័យទូទៅជាងនេះ ដែលវាមិនអាចកែតម្រូវតាមរយៈការបដិសេធសកម្មភាពបណ្ដោះអាសន្នមួយនាពេលក្រោយ។ បន្ទាប់មក ព្យសនកម្មមិនអាចជួសជុលបានបើកឲ្យមានភាពជាក់លាក់ និងភាពស្ថាពរនៃព្យសនកម្ម។ ខណៈដែលទំហំនៃព្យសនកម្មអាចពាក់ព័ន្ធ អចិន្ត្រៃយ៍ភាពរបស់វាមានសារសំខាន់ខ្លាំងជាង")។

[45] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២-**D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សាលដីកាលើដីកាដំណោះស្រាយក្នុងរឿងក្ដី អៀង សារី") កថាខណ្ឌ ១១៣។

ថា "និយាមក្នុងការសម្រេចពីភាពត្រឹមត្រូវ" នេះ មានន័យថា ខ្លួនត្រូវសម្រេចថាតើអង្គជំនុំជម្រះ "បានអនុវត្តតាមខ្លឹមសារនៃនិយាមគតិយុត្តជាធរមាន ដោយផ្អែកតាមប្រភពដ៏សមស្របនៃច្បាប់ និងតាមរយៈការអនុវត្តនូវវិធាននៃការបកស្រាយទាក់ទងទៅនឹងប្រភពនៃច្បាប់នោះដែរ ឬយ៉ាងណា"[46]។ អង្គជំនុំជម្រះត្រូវសម្រេចវាយតម្លៃផងដែរថាតើ លទ្ធផលដែលបានឈានទៅដល់នោះ "មានលក្ខណៈច្បាស់លាស់ និងជាក់លាក់" ឬយ៉ាងណា[47]។ មានតែកំហុសអង្គច្បាប់ដែលធ្វើឱ្យអស់សុពលភាពសេចក្តីសម្រេចតែប៉ុណ្ណោះ នឹងផ្តល់យុត្តិកម្មដល់ការបដិសេធ ឬការកែប្រែសេចក្តីសម្រេច[48]។

## គ. ចរិតលក្ខណៈនៃយន្តការដោះស្រាយវិវាទ អ.វ.ត.ក ដែលអនុញ្ញាត

29. មាត្រា ៥(៤) និង ៧(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត *លើកលែងតែ* ចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧[49]។
>
> *ក្នុងករណី* ដែលសហចៅក្រមស៊ើបអង្កេត [...] បានធ្វើសំណើស្របតាមមាត្រា ៥ វាក្យខណ្ឌ ៤ [...] សហចៅក្រមស៊ើបអង្កេតត្រូវធ្វើឯកសារវាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និង ហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួន ដាក់ជូនប្រធានការិយាល័យរដ្ឋបាល[50]។

30. ច្បាប់ អ.វ.ត.ក ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> ចៅក្រមទាំងអស់ត្រូវ*ព្យាយាម* សម្រេចឱ្យបានភាពឯកច្ឆន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន[51]។

---

[46] សំណុំរឿង ០០១-F28 សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា *ឌុច*") កថាខណ្ឌ ១៤។

[47] សំណុំរឿង ០០១-F28 សាលដីកា *ឌុច* កថាខណ្ឌ ១៤។

[48] សំណុំរឿង ០០១-F28 សាលដីកា *ឌុច* កថាខណ្ឌ ១៦។

[49] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤) គូសបញ្ជាក់បន្ថែម។

[50] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(១) គូសបញ្ជាក់បន្ថែម។

[51] ច្បាប់ អ.វ.ត.ក មាត្រា ១៤ថ្មី(១) គូសបញ្ជាក់បន្ថែម។

> ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រម [...] ការស៊ើបអង្កេតត្រូវធ្វើបន្ត *ដរាបណា*សហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូបក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម[52]។

31. វិធាន ៧២ នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> ១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រម ស៊ើបអង្កេតណាម្នាក់ ឬទាំងពីរ *អាច* ធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។
>
> ២. ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់*អាច* នាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល [...][53]។

## ឃ. ផលប៉ះពាល់នៃកំហុសនីតិវិធីលើកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ

32. មានការកំណត់ច្បាស់លាស់ នៅក្នុងច្បាប់ អ.វ.ត.ក និងច្បាប់អន្តរជាតិដែលថា កំហុសផ្នែកនីតិវិធីមិនបណ្តាលឲ្យសកម្មភាពជាលទ្ធផលទៅជាមោឃៈដោយស្វ័យប្រវត្តិនោះទេ[54]។ ហើយវាក៏មិនបាន

---

[52] ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី គូសបញ្ជាក់បន្ថែម។

[53] វិធាន ៧២(១)-(២) គូសបញ្ជាក់បន្ថែម។

[54] *សូមមើល ឧទាហរណ៍* វិធាន ៤៨ ("កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។")។ សំណុំរឿង០០២-**D55/I/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ៣៣-៤២ (ក្រៅពីករណីលើកលែងដ៏តឹងរឹងដែលបញ្ជាក់ក្នុងវិធាន ៥៣(៣) និង ៦៧(២) ការស៊ើបអង្កេត ឬកិច្ចរបស់តុលាការ នឹងត្រូវទុកជាមោឃៈដោយវិការៈនីតិវិធី តែក្នុងករណីដែលវិការៈនោះបាននាំឲ្យមានព្យសនកម្ម ហើយវាត្រូវបានកំណត់ថា មោឃភាពគឺជាដំណោះស្រាយសមស្របនៅក្នុងកាលៈទេសៈនៃរឿងក្តី)។ សំណុំរឿង ០០២-**D263/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

ធ្វើឱ្យខូចខាតដល់កិច្ចដំណើរការនីតិវិធីឡើយ លើកលែងតែត្រូវបានបង្ហាញថា បានបង្កឱ្យមានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង ដែលបណ្តាលឱ្យមានភាពអយុត្តិធម៌[55]។ អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ពីការអនុវត្តនេះ នៅក្នុងសំណុំរឿង ០០២/១ ដោយបញ្ជាក់ថា៖

---

កថាខណ្ឌ ២៤-២៦ (វាអាស្រ័យលើអង្គជំនុំជម្រះក្នុងការកំណត់ពីផលវិបាកនានា ប្រសិនបើមាន នៃកំហុសនីតិវិធីតាមមូលដ្ឋានមួយករណីម្តងៗ)។ ឯកសារ **D20/4/4** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង សេចក្តីសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ នឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ ("សេចក្តីពិចារណាលើសំណើទាក់ទងនឹងកិច្ចស៊ើបសួរ") យោបល់របស់ចៅក្រម Lahuis និង Downing កថាខណ្ឌ ៩-១១។ វិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការ IRMCT ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០ វិធាន ៥(ក)៖ ("នៅពេលដែលការជំទាស់លើមូលដ្ឋាន នៃការមិនគោរពតាមវិធាន ឬបទបញ្ជា ត្រូវបានភាគីលើកឡើង នៅពេលវេលាឆាប់បំផុតនោះ អង្គជំនុំជម្រះត្រូវផ្តល់តាមសំណូមពរ *ប្រសិនបើ*អង្គជំនុំជម្រះរកឃើញថា ការចោទពីការមិនគោរពតាម *ត្រូវបានបង្ហាញភ័ស្តុតាង* ហើយការណ៍នេះ *បណ្តាលឱ្យមានផលប៉ះពាល់សំខាន់* ទៅលើភាគីនោះ"។ (គូសបញ្ជាក់បន្ថែម))។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Brdjanin*, IT-99-36 សេចក្តីសម្រេចលើ "ការជំទាស់របស់មេធាវីការពារក្តីចំពោះភ័ស្តុតាងដែលទទួលបានដោយការលួចថតសំឡេង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ៦៣ (បានពិភាក្សាលើកត្តាចំនួន១០ ដែលប្រយុទ្ធប្រឆាំងទៅនឹងការទទួលយកភ័ស្តុតាង ទោះបីជា សម្រាប់គោលបំណងវែកញែក វាត្រូវបានទទួលដោយខុសច្បាប់។ *សូមមើលជាពិសេស* កត្តាទី ៧)។ *រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន* SCSL-04-16-PT, Brima - សេចក្តីសម្រេចលើញត្តិស្នើសុំឱ្យដកចេញនូវចម្លើយសាក្សីរបស់អយ្យការ និងសុំឱ្យផ្អាកការដាក់ចម្លើយរបស់អយ្យការ អង្គជំនុំជម្រះសាលាដំបូង (ចៅក្រម Boutet) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៤ កថាខណ្ឌ ១៩-២៤ (បានបដិសេធញត្តិស្នើសុំឱ្យដកចម្លើយសាក្សី ដោយផ្អែកលើមូលដ្ឋាននៃការខកខានរបស់អយ្យការ ក្នុងការដាក់បង្ហាញចម្លើយទាំងនោះស្របតាមវិធានជាធរមាន)។ *រដ្ឋអាជ្ញា ទល់នឹង Furundžija*, IT-95-17/1, សេចក្តីសម្រេចលើញត្តិរបស់ចុងចោទ Anto Furundžija សុំឱ្យដកចេញនូវសក្ខីកម្មរបស់សាក្សីជាក់លាក់របស់អយ្យការ អង្គជំនុំជម្រះសាលាដំបូង (ចៅក្រម Mumba) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៨ (ដោយបានបដិសេធញត្តិសុំឱ្យដកចេញសក្ខីកម្មរបស់សាក្សីជាក់លាក់ ទោះបីជាការខកខានរបស់អយ្យការក្នុងការអនុវត្តតាមកាតព្វកិច្ចដាក់បង្ហាញរបស់ខ្លួនក្តី)។ រឿងក្តីទាក់ទងនឹងការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍ (*Bosnia-Herzegovina ទល់នឹង Yugoslavia*) សេចក្តីសម្រេចលើអញ្ញត្តិកម្ម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ កថាខណ្ឌ ២៦។

[55] *សូមមើលជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Fofana & Kondewa* SCSL-04-14-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥ (មានតែកំហុសនីតិវិធីប៉ុណ្ណោះដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ ដែលធ្វើឱ្យខូចខាតដល់កិច្ចដំណើរការនីតិវិធី។ កំហុសណាដែលអាចកែប្រែបាន ឬលះបង់បាន ឬមើលរំលងបាន (ដែលមិនសំខាន់ ឬមិនមានផលវិបាក) ដោយមិនបង្កភាពអយុត្តិធម៌ដល់ភាគី កំហុសទាំងនោះមិនត្រូវចាត់ទុកថាជាកំហុសនីតិវិធី ដែលបង្កឱ្យមានភាពអយុត្តិធម៌ទេ) ៤៤៣ (ច្បាប់យុត្តិសាស្ត្រនៅតុលាការចំពោះកិច្ច ទទួលស្គាល់កំហុសដូចជាវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះអាំចត្រូវបាន "កែតម្រូវ" ប្រសិនបើអយ្យការអាចបង្ហាញថា លទ្ធភាពរបស់ជនជាប់ចោទក្នុងការរៀបចំការការពារក្តីរបស់ខ្លួនមិនត្រូវបានប៉ះពាល់ជាសារវន្ត)។ *រឿងក្តី Bagosora & Nsengiyumva ទល់នឹង រដ្ឋអាជ្ញា* ICTR-98-41-A សាលក្រម អង្គជំនុំជម្រះសាលឧទ្ធរណ៍ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ២១៤-២១៧ (បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាមួយចំនួន ដើម្បីកំណត់ថា វិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានធ្វើឱ្យការ

ទាក់ទងទៅនឹងកំហុសអំពី ចរិតលក្ខណៈនៃកិច្ចដំណើរការនីតិវិធី និងជាពិសេសកំហុសទាក់ទងទៅនឹង ការប្រើប្រាស់ឆន្ទានុសិទ្ធិ [...]អង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាលើបញ្ហាថាតើ [ព្យសនកម្មលើម្ចាស់បណ្តឹងសាទុក្ខ] ដែលបណ្តាលឲ្យមានភាពមិនយុត្តិធម៌ កើតមាននៅក្នុងអំឡុងពេលនៃកិច្ចជំនុំជម្រះទាំងមូលដែរឬយ៉ាងណា។ ម្យ៉ាងវិញទៀត ពុំមែនកំហុសនៃកិច្ចដំណើរការនីតិវិធីទាំងអស់សុទ្ធតែនាំទៅរកការកែប្រែសាលក្រមនោះឡើយ លើកលែងតែកំហុសនោះបណ្តាលឲ្យ "មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ"[56]។

33. នៅក្នុងសំណុំរឿង ០០៤/២ អង្គជំនុំជម្រះនេះបានទទួលស្គាល់ដោយតុណ្ហីភាពថា កំហុសឆ្គងនីតិវិធីជាញឹកញាប់មិនមែនជារឿងស្លាប់រស់ឡើយ គឺអាចកែសម្រួលបាន។ បន្ទាប់ពីរំឭកថា នៅពេលធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ អ.ប.ជ បានសម្រេចយ៉ាងច្បាស់លាស់ថា អង្គជំនុំជម្រះមានសិទ្ធិអំណាចចេញដីកាដំណោះស្រាយថ្មី ឬដីកាដំណោះស្រាយដែលកែប្រែ ដែលនឹងធ្វើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះ អ.ជ.ត.ក បានបញ្ជាក់ថា៖

> ការយល់ឃើញច្បាស់បែបនេះ នឹងនាំអ្នកវិភាគសមហេតុផលអាចសន្និដ្ឋានបានថា អង្គបុរេជំនុំជម្រះបានដឹងអំពីសិទ្ធិអំណាចរបស់ខ្លួន ក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់ នៃស្ថានការណ៍ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងចេញដីកាដំណោះស្រាយសុពលភាពរបស់ខ្លួនថ្មីមួយបាន[57]។

34. យុត្តិសាស្ត្របានកំណត់ថា ការសម្រេចរបស់អង្គជំនុំជម្រះមួយ ចំពោះអ្វីដែលជាដំណោះស្រាយចាំបាច់ ប្រសិនបើមាន សម្រាប់កំហុសឆ្គងនីតិវិធី ដែលបានចោទប្រកាន់ ផ្អែកទាំងស្រុងទៅលើអង្គហេតុនៃរឿងក្តីនីមួយៗ។ អង្គជំនុំជម្រះត្រូវថ្លឹងថ្លែងសិទ្ធិរបស់ជនជាប់ចោទ ធៀបទៅនឹងកត្តា

---

ជំនុំជម្រះអយុត្តិធម៌ឡើយ បានសម្រេចថាវិការៈត្រូវបានកែតម្រូវ និងមិនបានធ្វើឲ្យប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ Nsengiyumva ក្នុងការរៀបចំការការពារក្តីរបស់គាត់ឡើយ)។

[56] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាសំណុំរឿង ០០២/០១") កថាខណ្ឌ ១០០។

[57] សំណុំរឿង ០០៤/២ ឯកសារ **E004/2/1/1/2** សាលដីការបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦១។

ផ្សេងទៀត រួមទាំង ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងផលប្រយោជន៍សាធារណៈ ក្នុងការនាំយកជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភធ្ងន់ធ្ងរលើច្បាប់អន្តរជាតិមកធ្វើការជំនុំជម្រះ[58]។

35. ការបញ្ចប់កិច្ចដំណើរការនីតិវិធី ជាធម្មតាត្រូវបានចាត់ទុកថាជា "ដំណោះស្រាយដ៏គំហុក" ដែលមិនសមាមាត្រទៅនឹងព្យសនកម្មដែលចោទប្រកាន់ដែលបានទទួលរងនោះឡើយ[59]។ តុលាការបាន

---

[58] *សូមមើលជាឧទាហរណ៍ រឿងក្ដី* Ibrahim *និងអ្នកដទៃទៀត ទល់នឹង ចក្រភពអង់គ្លេស* Nos 50541/08, 50571/08, 505373/08 និង 40351/09 សាលក្រម (អង្គជំនុំជម្រះតុលាការកំពូល) ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ កថាខណ្ឌ ២៥២ ("លក្ខខណ្ឌតម្រូវទូទៅនៃភាពត្រឹមត្រូវយុត្តិធម៌ អនុវត្តចំពោះគ្រប់កិច្ចដំណើរការនីតិវិធី ដោយមិនគិតអំពីប្រភេទនៃបទល្មើសដែលចោទជាបញ្ហា [...] នៅពេលធ្វើការសម្រេចថាតើកិច្ចដំណើរការនីតិវិធី ជារួមមានភាពយុត្តិធម៌ ទម្ងន់នៃផលប្រយោជន៍សាធារណៈ នៅក្នុងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះបទល្មើសជាក់លាក់ណាមួយ ដែលចោទជាបញ្ហា អាចត្រូវបានយកមកធ្វើការពិចារណាដែរឬទេ")។ *សូមមើលផងដែរ* Hudson *ទល់នឹង* *Michigan*, 547 U.S. 586, 591 (២០០៦) (តុលាការកំពូលសហរដ្ឋអាមេរិកបានកត់សម្គាល់ថា ការបដិសេធភស្តុតាងដែលបានមកដោយខុសច្បាប់ "បង្កើតឱ្យមាន "តម្លៃសង្គមដ៏ខ្ពស់"" និងធ្វើឱ្យ ""ខូចខាតយ៉ាងច្រើន"ចំពោះការស្វែងរកយុត្តិធម៌ និងគោលបំណងនៃការអនុវត្តច្បាប់"។ ហេតុដូច្នេះ មាន "ឧបសគ្គដ៏ខ្ពស់" ដែលត្រូវតែបំពេញ៖ វាគួរត្រូវបានដកចេញតែ "ក្នុងករណីដែលអត្ថប្រយោជន៍នៃការធ្វើឱ្យញញើតរបស់វាធ្ងន់ជាង "តម្លៃសង្គមដ៏ខ្ពស់របស់វា"")។ *សូមមើលបន្ថែមទៀត* យុត្តិសាស្ត្រដែលបានដកស្រង់នៅក្នុងជើងទំព័រ ១១៣ (កម្មវត្ថុ៖ ផលប្រយោជន៍សហគមន៍អន្តរជាតិ ក្នុងការកាត់សេចក្ដីជនដែលត្រូវបានចោទប្រកាន់ដោយការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ) ១១៤-១១៥ (កម្មវត្ថុ៖ តម្រូវការថ្លឹងថ្លែងសិទ្ធិរបស់ភាគី *ទាំងអស់* រួមទាំងជនរងគ្រោះ និងអយ្យការ) *យោងខាងក្រោម*។

[59] *សូមមើល ឧទាហរណ៍ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Lubanga Dyilo*, ICC-01/04-01/06 សាលដីកាលើបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញា ប្រឆាំងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង១ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០ ដែលមានចំណងជើងថា "សេចក្ដីសម្រេចលើសំណើបន្ទាន់របស់រដ្ឋអាជ្ញា សុំឱ្យមានការផ្លាស់ប្ដូរពេលវេលាកំណត់ ក្នុងការបង្ហាញអត្តសញ្ញាណអន្តរការី ១៤៣ ឬជាជម្រើសមួយទៀត គឺផ្អាកកិច្ចដំណើរការនីតិវិធី រង់ចាំការប្រឹក្សាបន្ថែម ជាមួយ VWU" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ៥៥ (ដោយបានសម្រេចថា ការផ្អាកកិច្ចដំណើរការនីតិវិធីគឺជាដំណោះស្រាយដ៏គំហុក និងពិសេស") ៦០ *រដ្ឋអាជ្ញា ទល់នឹង* *D. Nikolić*, IT-94-2-AR73, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំ ទាក់ទងនឹងនីត្យានុកូលភាពនសការចាប់ខ្លួន អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ ("សាលដីកាលើនីត្យានុកូលភាពក្នុងរឿងក្ដី *Nikolić*") កថាខណ្ឌ ៣០ (ក្រៅពីករណីលើកលែងទាំងនេះ "ដំណោះស្រាយនៃការបដិសេធយុត្តាធិការតាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល ជាធម្មតានឹងមិនសមាមាត្រនោះទេ") *អនុវត្តតាមដោយ* សំណុំរឿង ០០២ ឯកសារ **D264/2/6** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ("សាលដីកាក្នុងរឿងក្ដី អៀង ធីរិទ្ធ ចំពោះការរំលោភនីតិវិធី") ជើងទំព័រ ៥២។ *Kajelijeli* *តទល់នឹង រដ្ឋអាជ្ញា* ICTR-98-44A-A សាលក្រម អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ ("សាលដីកា *Kajelijeli*") កថាខណ្ឌ ២០៦។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង* *Karemera* *និងគូកន* ICTR-98-44-T សេចក្ដីសម្រេចលើញត្តិរបស់ Édouard Karemera ពាក់

សម្រេចថា ការបញ្ចប់ចាំបាច់ត្រូវធ្វើឡើងតែក្នុង*កាលៈទេសៈពិសេសប៉ុណ្ណោះ* ដូចជា ការរំលោភដំណើរការនីតិវិធី ដែលមានលក្ខណៈ "គួរឱ្យស្អប់ខ្ពើម" ឬ "មិនគួរឱ្យពេញចិត្ត" ចំពោះរដ្ឋបាលតុលាការ ក្នុងការអនុញ្ញាតឱ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខ ឬក្នុងករណីដែលសិទ្ធិរបស់ជនជាប់ចោទ ត្រូវបានរំលោភបំពានដល់កម្រិតមួយដែលថា ការជំនុំជម្រះប្រកបដោយយុត្តិធម៌មិនអាចធ្វើទៅបាន[60]។ ការបង្ហាញថាការរំលោភបំពានចាំបាច់ធានាឱ្យមានការបញ្ចប់នោះ តម្រូវឱ្យមានលក្ខខណ្ឌមត្រូវដ៏ខ្ពស់នៃការបញ្ជាក់ភ័ស្តុតាង៖ អ.វ.ត.ក និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត បានបញ្ជាក់ច្បាស់ថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញ*តែ*នៅពេលណាដែលជនជាប់ចោទទួលរងការធ្វើបាប*ធ្ងន់ធ្ងរ* (ដូចជា ការប្រព្រឹត្តបែបអមនុស្សធម៌ ឃោរឃៅ និងបន្ទាបបន្ថោក ឬការធ្វើទារុណកម្ម) ឬការរំលោភ*ជាក់ស្ដែង*លើសិទ្ធិរបស់គាត់[61]។

---

ព័ន្ធសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះ ដោយមិនមានការពន្យាពេលមិនសមហេតុផល អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ("សេចក្ដីសម្រេចលើការពន្យាពេលមិនត្រឹមត្រូវ ក្នុងរឿងក្ដី *Karemera*") កថាខណ្ឌ ៤, ៦។

[60] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Lubanga Dyilo*, ICC-01/04-01/06-2690-Red2 សេចក្ដីសម្រេចដោយកោសលុប ស្ដីពី "សំណើរបស់មេធាវីការពារក្ដី សុំឱ្យផ្អាកជាអចិន្ត្រៃយ៍ កិច្ចដំណើរការនីតិវិធី ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ កថាខណ្ឌ១៦៥-១៦៦, ២០៣-២០៥ (បានសន្និដ្ឋានថា ការខកខានដែលបានចោទប្រកាន់លើផ្នែកនៃអយ្យការ អាចត្រូវបានដោះស្រាយជាផ្នែកមួយនៃដំណើរការជំនុំជម្រះជាបន្តបន្ទាប់)។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Ntaganda*, ICC-01/04-02/06-1883 សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី សុំផ្អាកកិច្ចដំណើរការនីតិវិធី ដោយមានព្យសនកម្មចំពោះរដ្ឋអាជ្ញា, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ កថាខណ្ឌ ២០។ សេចក្ដីសម្រេចលើការពន្យាពេលមិនត្រឹមត្រូវ ក្នុងរឿងក្ដី *Karemera* កថាខណ្ឌ ៦។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Kenyatta*, ICC-01/09-02/11-868-Red, សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី សុំផ្អាកអចិន្ត្រៃយ៍ កិច្ចដំណើរការនីតិវិធី ដោយសារតែមានការរំលោភបំពាននីតិវិធី, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ កថាខណ្ឌ ១៤។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Kallon & Kamara,* SCSL-2004-15-AR72(E) & SCSL-2004-16-AR72(E) សេចក្ដីសម្រេចលើការជំទាស់យុត្តាធិការ៖ កិច្ចព្រមព្រៀងលើកលែងទោស Lomé អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ ៧៩។ ដូចដែលបានពន្យល់ ដោយ អ.ប.ជ នៅក្នុងសំណុំរឿង ០០២-**D264/2/6** សាលដីកាក្នុងរឿងក្ដី អៀង ធីរិទ្ធ ចំពោះការរំលោភនីតិវិធី កថាខណ្ឌ ១០ "ទ្រឹស្ដីស្ដីពីការរំលោភនីតិវិធី ដែលមានដើមកំណើតនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡ នាពេលបច្ចុប្បន្ននេះត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃច្បាប់អន្តរជាតិ និងការអនុវត្តអន្តរជាតិ ដើម្បីធានាថា *ការរំលោភបំពានធ្ងន់ធ្ងរនានាលើកិច្ច ឬលើនីតិវិធី*ដែលមិនត្រឹមត្រូវ ឬខុសច្បាប់ទាំងស្រុងនោះ មិនត្រូវបានអនុញ្ញាតឱ្យមាន ដើម្បីលុបចោលនូវសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដែលត្រូវបានផ្ដល់ឱ្យជនត្រូវចោទ ឬជនជាប់ចោទនៅចំពោះមុខតុលាការនោះទេ" (គូសបញ្ជាក់បន្ថែម)។

[61] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០២ ឯកសារ **D264/2/6** សាលដីកាក្នុងរឿងក្ដី អៀង ធីរិទ្ធ ចំពោះការរំលោភនីតិវិធី កថាខណ្ឌ ២៤, ២៧។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Šešelj,* IT-03-67-T សេចក្ដីសម្រេចលើសំណើផ្ទាល់មាត់ របស់ជនជាប់ចោទ លើការរំលោភបំពានលើនីតិវិធី ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌ ២២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *D. Nikolić,* IT-94-2-PT សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដី ជំទាស់ចំពោះការប្រើប្រាស់យុត្តាធិការ ដោយតុលាការ, អង្គជំនុំជម្រះ

## ង. "គោលជំហរស្វ័យប្រវត្តិ" ជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក

36. មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ [...] ប្រសិនបើគ្មានមតិភាគច្រើនដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត[62]។

37. វិធាន ៧២(ឃ) ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រម៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រភាគច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រមានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយ [ស.ច.ស] ណាម្នាក់ត្រូវមានសុពលភាព ឬមានន័យថា ដីកា ឬកិច្ចស៊ើបសួរ ដែលបម្រុងនឹងធ្វើដោយ [ស.ច.ស] ម្នាក់ ត្រូវតែយកមកអនុវត្ត។

38. វិធាន ៧៧(១៣) ចែងថា៖

> សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូប យ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសំឡេង

---

សាលាដំបូង ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១១៤ (កត់សម្គាល់ថា នៅលើអង្គហេតុនៃសរឿងក្តី ការប្រព្រឹត្តលើជនជាប់ចោទមិនមានលក្ខណៈជាក់ស្តែង ដែលបណ្តាលឱ្យមានឧបសគ្គដល់ការអនុវត្តយុត្តាធិការលើគាត់ឡើយ) *ត្រូវបានតម្កល់ដោយ*សេចក្តីសម្រេចលើនីត្យានុកូលភាពក្នុងក្តី *Nikolić* កថាខណ្ឌ ២, ២៨, ៣៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo,* ICC-01/ 04- 01/06-772 សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងសេចក្តីសម្រេចលើការជំទាស់របស់ មេធាវីការពារក្តី ប្រឆាំងយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣១។ សេចក្តីសម្រេច *Barayagwiza* ខែវិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧៥។

[62] *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤), ៦(៤), ច្បាប់ អ.វ.ត.ក មាត្រា ២០ថ្មី។

ភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តដូចខាងក្រោម៖

(ក) ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬកិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬកិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ។

(ខ) ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

39. វិធាន ៧៧(១៤) ចែងថា៖

សេចក្តីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផង ត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធីជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

40. វិធាន ៧៩(១) ចែងថា៖

អង្គជំនុំជម្រះសាលាដំបូង*ទទួលបណ្តឹង* ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

41. ក្នុងសំណុំរឿង ០០៤/២ អង្គជំនុំជម្រះនេះបានថ្លែងថា៖

នៅពេលដែលភាពឯកច្ឆន្ទពុំទទួលបាន នៅក្នុងដំណាក់កាលណាមួយនៃកិច្ចស៊ើបសួរ និងការចោទប្រកាន់ក្នុងដំណើរការមុនការជំនុំជម្រះ នឹងមានជំហរមិនពេញលេញដែលជួយដល់ការបន្តកិច្ចស៊ើបសួរ ឬការចោទប្រកាន់ បញ្ហាថាតើ ជារបស់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា[63]។

[63] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ អ.ជ.ត.ក កថាខណ្ឌ៦២។

## IV. ភាពអាចទទួលយកបាន

42. សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន អនុលោមតាម មាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ៣៣ថ្មី និង៣៧ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ២១(១) ដែលតម្រូវថា អ.វ.ត.ក អនុវត្តកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដោយគោរពដល់សិទ្ធិនិងផល ប្រយោជន៍ របស់ភាគី*ទាំងអស់* និងគោរពតាមដំណើរការផ្លូវច្បាប់ត្រឹមត្រូវ ព្រមទាំងអនុលោមទៅ តាមគោលការណ៍ជាសារវន្ត នៃភាពប្រាកដប្រជាផ្នែកច្បាប់ រដ្ឋបាលតុលាការដែលល្អនិងត្រឹមត្រូវ យុត្តិធម៌ និងភារកិច្ចរបស់ចៅក្រម ក្នុងការដោះស្រាយបញ្ហានៅចំពោះមុខ[64]។ ដូចដែលនឹងបង្ហាញ នៅផ្នែកខាងក្រោម កាលៈទេសៈនៃរឿងក្តីនេះ តម្រូវថាជាការចាំបាច់ ដែលត្រូវមានកិច្ចអន្តរាគមន៍ នៅដំណាក់កាលនេះ ដើម្បីជៀសវាងពីការខូចខាតដែលមិនអាចជួសជុលបាន ទាំងចំពោះភាពត្រឹម ត្រូវនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ សម្រាប់គ្រប់ភាគី[65]។

43. ដូចដែលអង្គជំនុំជម្រះនេះបានបញ្ជាក់ច្បាស់ នៅក្នុងសំណុំរឿង ០០៤/២ ថា នៅពេលធ្វើការសម្រេច លើបណ្តឹងសាទុក្ខប្រឆាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត អ.ប.ជ មានកាតព្វកិច្ច ចេញសេចក្តីសម្រេចស្ពាពរ ដែលដោះកំណត់អានុភាពនៃការសន្និដ្ឋានដែលធ្វើឡើងដោយចៅក្រម អ.ប.ជ រួមទាំងសេចក្តីសម្រេចជាឯច្ឆន្ទរបស់ខ្លួន លើសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង អានុភាពនៃគោលការណ៍ស្វ័យប្រវត្តិ[66]។ នៅក្នុងសំណុំរឿង ០០៣ ភាគីបានជំទាស់តវ៉ាយ៉ាងខ្លាំងក្លា ទៅលើសកម្មភាពដែលបានតម្រូវដោយសេចក្តីពិចារណារបស់ អ.ប.ជ មុនពេលស្នើសុំ អ.ប.ជ ចាត់វិធានការដាច់ស្រេច ដើម្បីបិទបញ្ចប់ដំណាក់កាលមុនពេលជំនុំជម្រះនៃរឿងក្តីនេះ ប៉ុន្តែ អ.ប.ជ

---

[64] *សូមមើល*ចំណុច III.ក ផ្នែកយុត្តាធិការដែលជាប់មកជាមួយ *យោងខាងលើ* សម្រាប់ព័ត៌មានលម្អិត ទាក់ទងច្បាប់ជាធរមាន ដែល*ក្នុងចំណោមរឿងផ្សេងទៀត* សម្រេចផងដែរថា វិធាន ២១ នៃវិធានផ្ទៃក្នុង បានចែងពីមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍។

[65] *សូមមើល យោងខាងលើ*។

[66] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦០-៦១, ៦៨។ ទោះជាបែបនេះក្តី ក្នុងការឆ្លើយតបចំពោះសំណើរបស់ភាគីនានា នៃសំណុំរឿង ០០៣ សុំឲ្យអង្គបុរេជំនុំជម្រះចេញសេចក្តី សម្រេចស្ពាពរបែបនេះ អ.ប.ជ បានបញ្ជាក់ថា ដោយសារតែនេះគឺជាភារកិច្ច របស់ចៅក្រមនីមួយៗក្នុងការសម្រេចតែម្នាក់ឯង និងដោយមានមនសិកាខ្ពស់ និងដោយសារតែមិនមានអត្ថបទណា តម្រូវឲ្យ អ.ប.ជ ឈានដល់ការសម្រេចជាឯកច្ឆន្ទ "ដូច្នេះតាម ផ្លូវច្បាប់ វាមិនត្រឹមត្រូវទេក្នុងការតម្រូវឲ្យមាន ការសម្រេចជាឯកច្ឆន្ទពីក្រុមប្រឹក្សាជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃ កាតព្វកិច្ចគតិយុត្តស្រមើស្រមៃមួយ ខណៈដែលកាតព្វកិច្ចនោះត្រូវធ្លាក់ទៅលើ សហចៅក្រមស៊ើបអង្កេតយ៉ាងពិតប្រាកដ"។ *សូមមើល* ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៦៨។

បានប្រកាសថាសំណើទាំងនោះមិនអាចទទួលយកបាន ហើយបានបញ្ជាក់ថាខ្លួនបានអនុវត្តភារកិច្ចរបស់ខ្លួនរួចរាល់ហើយ[67]។ អ.ប.ជ បានបញ្ជាក់បន្ថែមថា ឥឡូវនេះគឺជាការទទួលខុសត្រូវរបស់ ស.ច.ស ក្នុងការអនុវត្តតាមជាបន្ទាន់ជាមួយផ្នែកដែលដំណើរការនៃសេចក្ដីពិចារណា[68]។

44. ស.ច.ស មិនបានបញ្ជូនរឿងក្ដី ០០៣ ទៅ អ.ជ.ស.ជ ដូចដែលបានតម្រូវដោយការតម្កល់ជាឯកច្ឆន្ទរបស់ អ.ប.ជ នៃសុពលភាពរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ហើយពួកគាត់ក៏មិនបានអនុវត្តផ្នែកលើគោលជំហរស្វ័យប្រវត្តិដែលជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ដែរ[69]។

45. ដោយសារតែភាពអសកម្មរបស់ អ.ប.ជ និង ស.ច.ស ពេលនេះគឺជាការចំបាច់បំផុត ដែល អ.ជ.ត.ក ត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិដែលមានជាប់មកជាមួយរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍យុត្តិធម៌ រក្សាសុចរិតភាពកិច្ចដំណើរការនីតិវិធី និងផ្ដល់សច្ចភាពចំពោះស្ថានភាពនេះ។ មានហេតុផលជាច្រើន ដែលជាមូលដ្ឋាននៃសំណើសុំនេះ។

46. ទីមួយ អ.ប.ជ និង ស.ច.ស បានបន្ទោសគ្នាទៅវិញទៅមកជាច្រើនដងជាដដែលៗ ចំពោះការជាប់គាំងផ្នែកនីតិវិធី ដែលបានវិវឌ្ឍន៍ឡើងនៅក្នុងរឿងក្ដីនេះ ព្រមទាំងនៅក្នុងសំណុំរឿង ០០៤/២ និង ០០៤ ផងដែរ[70]។ ដោយសារតែការឆ្លើយឆ្លងបែបសងសឹកគ្នាទៅវិញទៅមកកាន់តែកើនកម្ដៅខ្លាំង

---

[67] ដូចដែលបានបង្ហាញនៅក្នុង II. ប្រវត្តិនីតិវិធី *យោងខាងលើ*។ *សូមមើលផងដែរ* ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ២៤-៥៩ (សង្ខេបពីទស្សនៈរបស់ មាស មុត និង ស.ព.អ) កថាខណ្ឌ ៧២, ៧៦-៧៨ (ពិភាក្សាអំពីសំអាងហេតុរបស់ អ.ប.ជ)។

[68] ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២។

[69] ដូចដែលបានពិភាក្សាលម្អិតនៅចំណុច V. អង្គសេចក្ដី *យោងខាងក្រោម*។

[70] នៅក្នុងសំណុំរឿង ០០៣ *សូមមើលជាឧទាហរណ៍* ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណា កថាខណ្ឌ ១០៦-១០៩ (ជាឯកច្ឆន្ទ)។ ឯកសារ **D270/7** សេចក្ដីសម្រេចបដិសេធរបស់ ស.ច.ស កថាខណ្ឌ៨-១៤ (បញ្ជាក់ថាពួកគាត់ "ជាលើកទីពីរហើយ ដែលត្រូវបានទទួលរងនូវភាសាយ៉ាងកំណាច និងការនិយាយបញ្ឆិតបញ្ឆៀង ដែលសឹងតែគ្មានការលាក់បាំងថា យើងចេញដីកាដំណោះស្រាយពីរ ក្នុងគោលបំណងធ្វើឱ្យខូចខាត ដល់ដំណើរការក្នុងសំណុំរឿង ០០៤/២ និង ០០៣" ដោយបានយោងផងដែរទៅលើក្រមសីលធម៌តុលាការជាតិ និងច្បាប់ទូទៅស្ដីពីការបរិហាកេរ្ដិ៍ ដោយបញ្ជាក់ថា ចៅក្រម អ.ប.ជ "ដោយមិនមានភស្តុតាងសូម្បីបន្តិចនោះ ក្រៅពីការបកស្រាយផ្ទាល់ខ្លួន ដោយលម្អៀងរបស់ពួកគេ ទៅលើព្រឹត្តិការណ៍" បានធ្វើការ "ចោទប្រកាន់ក្នុងវិជ្ជាជីវៈដ៏អាក្រក់បំផុត ដែលត្រូវបានធ្វើឡើងទៅលើចៅក្រម" "ចោទប្រកាន់ថាពួកយើង ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ") កថាខណ្ឌ ២៥ បញ្ជាក់ថា អ.ប.ជ ជ្រើសរើសមិនចេញផ្នែកសម្រេចសេចក្ដីស្ថាពរ "ជំនួសឱ្យការជ្រើសយកការបញ្ចេញមតិយោបល់ដ៏វែងអន្លាយជាថ្មីទៀត អំពីអសមត្ថភាពផ្លូវច្បាប់ និងលក្ខណៈសីលធម៌របស់យើង"។ ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ២២ ("អង្គបុរេជំនុំជម្រះសោកស្ដាយយ៉ាងខ្លាំង ចំពោះការដែលចៅក្រមទាំងនេះ មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយបែរជាចាត់ទុកខ្លួនឯង ថាជាជនរងគ្រោះទៅវិញ នៅពេល

ឡើងៗ ស្ថានការណ៍កាន់តែប្រែទៅជាអាក្រក់ដល់ចំណុចមួយដែលវាបង្ហាញថា ទាំង អ.ប.ជ និង ទាំង ស.ច.ស មិនមានឆន្ទៈស្តាប់អ្នកណាផ្សេង ដែលធ្វើឱ្យការជាប់គាំងនៅមានបន្តជារៀងរហូត និងគម្រាមកំហែងឱ្យមានការខូចខាតដែលមិនអាចជួសជុលបានចំពោះរដ្ឋបាលតុលាការដ៏ត្រឹមត្រូវ ក្នុងសំណុំរឿង ០០៣។

47. ការបែកបាក់គ្នាបានកើតឡើងទាំងសងខាង។ ឧទាហរណ៍ ស.ច.ស បានបញ្ជាក់យ៉ាងច្បាស់នៅក្នុង ខែឧសភា ឆ្នាំ២០២១ ថា សេចក្តីពិចារណា "មិនមានគោលដៅច្បាស់លាស់" សម្រាប់ដំណោះស្រាយត្រឹមត្រូវសម្រាប់រឿងក្តីនេះ ហើយពួកគាត់មិនប្រាកដថាតើមានផលវិបាកអ្វីកើតឡើង សម្រាប់ការសម្រេចដែលថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាពីរ គឺជារឿងខុសច្បាប់នោះ[71]។ ទោះបីជាមានសំណើសុំការណែនាំនេះក្តី បួនខែក្រោយមក នៅពេលដែល អ.ប.ជ ចេញសេចក្តីសម្រេចរបស់ខ្លួន ឆ្លើយតបទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺពី*ភាគី* អ.ប.ជ នៅរក្សាជំហរថា វាគឺជាការងាររបស់ ស.ច.ស ក្នុងការដំណើរការរឿងក្តីនេះស្របទៅតាមវិធាន ៧៧(១៣) និង(១៤) នៃវិធានផ្ទៃក្នុង ហើយជាថ្មីម្តងទៀត បានស្តីបន្ទោស ស.ច.ស ចំពោះស្ថានការណ៍បែបនេះ[72]។

---

កំហុសធ្ងន់ធ្ងររបស់ខ្លួន ត្រូវបានលាតត្រដាង") កថាខណ្ឌ ៧៤-៧៦ (បញ្ជាក់ផងដែរ *ក្នុងចំណោមរឿងផ្សេងទៀត* ថា "អង្គបុរេជំនុំជម្រះគួសបញ្ជាក់ពីភាពស្មុគស្មាញ ដែលសហចៅក្រមស៊ើបអង្កេតកំពុងជួបប្រទះ ដើម្បីដោះស្រាយផលវិបាក នៃការអនុវត្តមិនត្រឹមត្រូវរបស់ពួកគេ និងការរំលោភបំពានដោយចេតនា លើក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក" និងថាសហចៅក្រមស៊ើបអង្កេត "សម្រេចទុកជាមុនលើ "ជោគវាសនានៃសំណុំរឿងនេះ" ប្រសិនបើថែដន្យសំណុំរឿងនោះ ត្រឡប់មកនៅចំពោះមុខពួកគេឡើងវិញក៏ដោយ" នេះគឺ "ស្ថានភាពទុំជោរ ដែលសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើង ក្នុងការបដិសេធមិនអនុវត្តតាមច្បាប់ឱ្យបានតឹងរ៉ឹង" ដោយចោទជាសំណួរទៅលើសំអាងហេតុរបស់ ស.ច.ស.អ ដែល "ប្រកាសសម្រេចក្រោមមូលដ្ឋានច្បាប់ស្រមើស្រមៃ" ថាគ្មានសមត្ថភាពក្នុងការបញ្ជូនរឿងក្តី ទៅ អ.ជ.ស.ដ និងបញ្ជាក់ថា ស.ច.ស "យល់ច្រឡំ" ហើយការអនុវត្តមិនត្រឹមត្រូវរបស់ពួកគេ បានបណ្តាលឱ្យមានភាពបរាជ័យបែបនេះ ដែលនាពេលនេះហាក់ដូចជាមិនអាចជម្រះបានចំពោះ "អ្នកដែលបង្ករ")។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ **D359/24 &D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២") កថាខណ្ឌ ១២២-១២៤ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ("សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤") កថាខណ្ឌ ១១២-១១៥ (ជាឯកច្ឆន្ទ)។

[71] ឯកសារ **D270/7** សេចក្តីសម្រេចបដិសេធ របស់ ស.ច.ស កថាខណ្ឌ ១៧, ២៥។

[72] ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២។*សូមមើលផងដែរ* កថាខណ្ឌ ៦៨ (សំអាងហេតុដែលថា ជាការខុសច្បាប់ ក្នុងការទាមទារឱ្យមានសេចក្តីសម្រេច (ស្តាពរ) ជាឯកច្ឆន្ទ ពីក្រុមប្រឹក្សាជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាន "កាតព្វកិច្ចគតិយុត្តស្រមើស្រមៃមួយ" ដែលជាលក្ខណៈពិសេសចំពោះ ស.ច.ស ដែលអាចបំពេញកិច្ចជាឯកត្តោភាគី)។

48. ស.ច.ស.អ ក៏បានបង្ហាញផងដែរពីចេតនាមិនពេញចិត្តក្នុងការគោរពតាមពាក្យពេចន៍ណែនាំ ដែលចៅក្រម អ.ប.ជ បានណែនាំ - បើទោះបីជាការបដិសេធរបស់ពួកគេមិនចេញសេចក្ដីសម្រេចស្ថាពរក្ដី - នៅក្នុងពេលដែលមានការស្ដីបន្ទោសរបស់ពួកគាត់ជាសាធារណៈទៅលើ ស.ច.ស។ អ.ប.ជ បានបញ្ជាក់ថា ស.ច.ស មួយរូប អាចបំពេញកិច្ចតែម្នាក់ឯងដោយសុពលភាព ក្នុងការបិទបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ ហើយថាការដាក់ឲ្យដំណើរការឡើងវិញនៃ ស.ច.ស.អ បានអនុញ្ញាតឲ្យ ក.ស.ច.ស អាចអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការដំណើការរឿងក្ដីនេះ[73]។ សំខាន់ជាងនេះទៅទៀត អង្គជំនុំជម្រះឯកច្ឆន្ទបានចោទសួរទៅលើ សំអាងហេតុរបស់ ស.ច.ស.អ ចំពោះ "[ការ]ប្រកាសសម្រេចក្រោមមូលដ្ឋានស្របច្បាប់ *ស្រមើស្រមៃ*ថាគ្មានសមត្ថភាពក្នុងការប្ដឹងក្រុមប្រឹក្សាជំនុំជម្រះ" បន្ទាប់ពីបានបង្គាប់ឲ្យបញ្ជូនរឿងក្ដីទៅជំនុំជម្រះ[74]។ ដោយមិនមានការសម្រេចជាក់ច្បាស់ ទាំងអស់នេះបង្ហាញថា ជំហានបន្ទាប់ដែលសមស្រប គឺ ស.ច.ស.អ ត្រូវបិទបញ្ចប់កិច្ចស៊ើបសួរជាឯកតោភាគី ដោយបញ្ជូនរឿងក្ដីនេះទៅ អ.ជ.ស.ដ។

49. ទោះជាយ៉ាងនេះក្ដី ស.ច.ស.អ មិនអនុវត្តតាមជំហាននេះឡើយ។ ផ្ទុយទៅវិញ ស.ច.ស.អ បានអះអាងរួមគ្នាថា បើមិនមានការសម្រេចស្ថាពរពី អ.ប.ជ ក្នុងការផ្ដល់នូវភាពច្បាស់លាស់ទេ និងលើកលែងតែ ស.ព.អ មានបំណងប្ដឹងទៅ អ.ជ.ត.ក នោះ កិច្ចដែលនៅសល់តែមួយគត់ គឺត្រូវបញ្ចប់រឿងក្ដីនេះ[75]។ ហេតុដូច្នេះ ស.ច.ស បានធ្វើការកំណត់ទុកជាមុនលើបញ្ហានេះរួចទៅហើយ ដោយបញ្ជាក់ថា "បញ្ហាច្បាប់ពាក់ព័ន្ធទាំងអស់ត្រូវបានជជែកលម្អិតដោយភាគីរួចរាល់អស់ហើយ។ យើងពុំឃើញមានទិដ្ឋភាពថ្មីណាមួយទំនងនឹងលេចចេញនោះទេ" ហើយ "បញ្ហាតែមួយគត់" ដែលត្រូវសម្រេចគឺយុត្តាធិការរបស់ពួកគាត់ក្នុងការបញ្ចប់រឿងក្ដីនេះ[76]។

---

[73] ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៦៧, ៧២។

[74] ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧៥ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* កថាខណ្ឌ ៧៤ ដែលហាក់ដូចជាគូសបញ្ជាក់បន្ថែមថា ស.ច.ស អាចបញ្ជូនសំណុំរឿង ប៉ុន្តែពួកគេបានបដិសេធមិនគោរពដោយម៉ឺងម៉ាត់ទៅតាមច្បាប់ទេ។

[75] ស.ច.ស បានបញ្ជាក់ថា ពួកគេនឹងមិនបញ្ជូនសំណុំរឿងទាំងអស់គ្នា ឬជាបុគ្គល ទៅ អ.ជ.ស.ដ ឡើយ ប្រសិនបើបញ្ហានេះត្រូវបានបញ្ជូនត្រឡប់មកពួកគេវិញ។ *សូមមើល* ឯកសារ **D270/7** សេចក្ដីសម្រេចបដិសេធរបស់ ស.ច.ស កថាខណ្ឌ ៣៥-៣៧, ៤២-៤៣ ឯកសារ **D273** ដីកាសម្រេចរបស់ ស.ច.ស លើសំណើសុំបិទបញ្ចប់សំណុំរឿង កថាខណ្ឌ ៦-៧។

[76] ឯកសារ **D270/7** សេចក្ដីសម្រេចបដិសេធ របស់សហចៅក្រមស៊ើបអង្កេត កថាខណ្ឌ ៣៥-៣៧, ៤២-៤៣ ឯកសារ **D273** ដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត លើសំណើសុំបិទបញ្ចប់សំណុំរឿង កថាខណ្ឌ ៥-៧ EN 01676518។ សូមកត់សម្គាល់ថា អង្គបុរេជំនុំជម្រះមានទស្សនៈដូចគ្នាដែលថា សហចៅក្រមស៊ើបអង្កេត បានសម្រេចរួចទៅហើយ លើដោតវាសនានៃសំណុំរឿង។ *សូមមើល* ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៧៤ (រៀបរាប់

50. និយាយដោយខ្លី ការស្វែងរកដំណោះស្រាយពីចៅក្រម ដែលបានធ្វើការកំណត់ទុកជាមុនទៅលើបញ្ហារួចហើយ គឺជាការស្រមើស្រមៃ និងបណ្តាលឲ្យមានព្យសនកម្មមិនអាចជួសជុលបាន និងមានភាពអយុត្តិធម៌ ហើយជាការធ្វើឲ្យភាគីធ្លាក់ចូលទៅក្នុងវដ្តនៃការប្តឹងផ្តល់គ្មានទីបញ្ចប់មួយផ្សេងទៀត ព្រោះការបញ្ចប់នឹងបណ្តាលឲ្យមានបណ្តឹងឧទ្ធរណ៍ទៅ អ.ប.ជ ដែល បានលើកឡើងរួចហើយថាខ្លួន "នឹងរក្សាទស្សនៈដូចគ្នា" លើបញ្ហាដែលខ្លួនបានពិចារណារួចហើយ ហើយដែលខ្លួនមិនអាចឈានដល់សំឡេងភាគច្រើនលើសលុបតាមការតម្រូវ ក្នុងការចេញសេចក្តីសម្រេច[77]។

51. បើមិនមានការអន្តរាគមន៍ពី អ.ជ.ត.ក ទេ កិច្ចដំណើរការនីតិវិធីនឹងនៅតែស្ថិតក្នុងភាពជាប់គាំងផ្នែកតុលាការ ទោះបីជាមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព ដែលបណ្តាលឲ្យមានព្យសនកម្មមិនអាចជួសជុលបាន និងការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ភាគី *ទាំងអស់* ជាពិសេសជនរងគ្រោះរាប់ពាន់នាក់ ដែលបានរង់ចាំអស់បពេលបួនទសវត្សរ៍ ដើម្បីទទួលបានការសម្រេចចំពោះការទទួលខុសត្រូវតាមផ្លូវតុលាការ ប្រកបដោយយុត្តិធម៌ និងឥតលម្អៀង។ លទ្ធផលបែបនេះ គឺជាយុត្តិនិសេធ ដែលផ្ទុយទៅនឹងអាណត្តិរបស់តុលាការនេះ និងផ្ទុយទៅនឹងគោលការណ៍ ដែលនាំឲ្យមានបណ្តឹងសារទុក្ខនេះ។

52. ផ្អែកលើសំអាងហេតុខាងលើ ស.ព.អ សន្និដ្ឋានថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន។

## V. អង្គសេចក្តី

### ក. ដីកាដំណោះស្រាយផ្ទុយគ្នាមិនត្រូវបានចេញដោយខុសច្បាប់ឡើយ - រឿងក្តីបន្តទៅជំនុំជម្រះ

53. រឿងក្តីត្រូវតែបន្តទៅជំនុំជម្រះ ផ្អែកលើការសម្រេចរបស់ចៅក្រម អ.ប.ជ ទាំងប្រាំរូប ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ឬម្យ៉ាងវិញទៀត តាមអានុភាពនៃគោលជំហរស្វ័យ

លម្អិតពីការអនុវត្តមិនស្របគ្នា របស់សហចៅក្រមស៊ើបអង្កេត និងបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេត "សម្រេចទុកជាមុនលើ "ជោគវាសនានៃសំណុំរឿងនេះ" ប្រសិនបើជាចៃដន្យ សំណុំរឿងនោះត្រឡប់មកនៅចំពោះមុខពួកគេឡើងវិញ")។

[77] កត្តាទាំងអស់បង្កើតបានជា "កាលៈទេសៈពិសេស" ដែលជាហេតុផលសម្រាប់រួចផុតពីការប្រើប្រាស់អស់លទ្ធភាពនៃលក្ខណ្ឌតម្រូវដំណោះស្រាយ ដែលអាចមាន ដែលជាយុត្តិកម្មសម្រាប់ការចូលអន្តរាគមន៍របស់ អ.ជ.ត.ក នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ *សូមមើល* ផ្នែក III.ក. ការរួចផុតពីលក្ខខណ្ឌតម្រូវប្រើប្រាស់ដោះស្រាយអស់លទ្ធភាព *យោងខាងលើ*។ *សូមមើលផងដែរ* ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧៧។

ប្រវត្តិ ដូចបានពិភាក្សាខាងក្រោម[78]។ ការចេញដីកាដំណោះស្រាយផ្ទុយគ្នាដោយមូលហេតុនៃការមិនចុះសម្រុងគ្នាដែលមិនអាចផ្សះផ្សាបាន មិនបដិសេធលទ្ធផលនេះទេ។ ការចេញបែបនេះគឺ ពុំមានហាមឃាត់នៅក្នុងក្របខណ្ឌគតិយុត្ត អ.វ.ត.ក ឡើយ។ ការណ៍នេះត្រូវបានបង្ហាញដោយឋានៈស្មើគ្នា និងឯករាជ្យរបស់ ស.ច.ស និងចរិតលក្ខណៈដែលអនុញ្ញាតនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នាដែលបានអនុម័ត[79]។ ជាការពិតណាស់ លទ្ធផលបែបនេះត្រូវបានប្រមើលដោយតុល្លីភាពនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក ("ឯកសារមូលដ្ឋានគោល") និងវិធានផ្ទៃក្នុង។

54. ស.ច.ស ម្នាក់ៗមានសិទ្ធិស្មើគ្នា និង មានអាណត្តិបំពេញកិច្ចដោយឯករាជ្យ[80]។ ការសម្រេចរបស់ អ.ប.ជ ដែលថាគួរចេញតែដីកាដំណោះស្រាយតែមួយ[81] គឺផ្ទុយទៅនឹងឯករាជ្យភាពនេះ។ ការសម្រេចនេះ *យោងតាមសំអាងហេតុពីមុន* *(a posteriori)* តម្រូវថា ស.ច.ស មួយរូបគួរតែបានរំលោភភារកិច្ចឯករាជ្យនេះ ដោយស្រុះស្រួលជាមួយជំហរផ្ទុយទាំងស្រុងរបស់សមភាគីរបស់ខ្លួន។ ម្យ៉ាងវិញទៀត ការសម្រេចនេះយកទម្រង់ធំជាងខ្លឹមសារ ដោយតម្រូវថា ការខ្វែងយោបល់គ្នាមិនអាចផ្សះផ្សាបានដែលតម្រូវឲ្យមានឯកសារចំនួនពីរ គួរតែដាក់ក្នុងឯកសារតែមួយគត់។

55. ឯកសារមូលដ្ឋានគោល បានប្រមើលទុកជាមុននូវការខ្វែងយោបល់ ប៉ុន្តែមិនតម្រូវឲ្យមានការដោះស្រាយជាកំហិត[82]។ វិធាន៧២ ចែងយ៉ាងច្បាស់ថា យន្តការដោះស្រាយវិវាទមានលក្ខណៈអនុញ្ញាត៖ ចៅក្រមស៊ើបអង្កេតណាម្នាក់ ឬទាំងពីរ *អាច*ធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ហើយក្នុងរយៈពេល៣០ថ្ងៃ *អាច*នាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខ អ.ប.ជ[83]។ កិច្ចមុនៗរបស់ ស.ច.ស នៅក្នុងរឿងក្តីនេះមិនអាចបដិសេធដោយ

---

[78] *សូមមើល* ផ្នែក V.គ *យោងខាងលើ*។

[79] *សូមមើល* ផ្នែកទី III.គ *យោងខាងលើ*។

[80] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣ (៣), ៥ (៣)។ ច្បាប់ អ.វ.ត.ក មាត្រា១០ ថ្មី, ២៥។

[81] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៥។

[82] *សូមមើល* ផ្នែកទី III.គ *យោងខាងលើ* រៀបរាប់ពាក្យពេចន៍ដែលចែងអនុញ្ញាត (ជាជាងពាក្យពេចន៍ដែលចែងចាប់បង្ខំ) ទាក់ទងនឹងដំណោះស្រាយនៃការខ្វែងយោបល់របស់ ស.ច.ស ។ *សូមមើលផងដែរ* ឯកសារ **D262.2** ដីកាសម្រេចលើសំណើបន្ទាន់របស់អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ១៣-១៨ (សេចក្តីសម្រេចរួមចេញដោយ ស.ច.ស ជូនដំណឹងដល់ភាគីក្នុងសំណុំរឿង០០៤/២, ០០៣ និង០០៤ អំពីទស្សនៈរបស់ពួកគាត់អំពីការចេញដីកាដំណោះស្រាយដាច់ដោយឡែក)។ ឯកសារ **D266/18.2** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ KH 01652863-64 (សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ ស.ព.អ លើបញ្ហានេះ)។

[83] ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ៣២ *យោងខាងលើ*។

ការបកស្រាយផ្ទុយគ្នាថ្មីៗនេះរបស់ អ.ប.ជ ដែលធ្វើឲ្យបទប្បញ្ញត្តិជាជម្រើសមួយមានលក្ខណៈជាការកំហិតនោះទេ[84]។

56. ផ្ទុយពីការហាមឃាត់ការចេញដីកាដំណោះស្រាយចំនួនពីរ ក្នុងករណីដែលមានការមិនចុះសម្រុងគ្នាដែលមិនអាចផ្សះផ្សាបាន ឯកសារមូលដ្ឋានគោលប្រមើលឃើញដោយតុល្យភាពនូវសេណារីយោនេះ និងផ្តល់ដំណោះស្រាយ៖ គោលជំហរជាសារវន្ត និងកំណត់សម្រេចផ្តល់អាណត្តិថា ការស៊ើបអង្កេតត្រូវបន្ត[85]។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជា និង អសប បានប្រមើលមើលដោយតុល្យភាពនូវស្ថានភាពបច្ចុប្បន្ននេះ។

57. ភវនីយភាពនៃការចេញដីកាដំណោះស្រាយចំនួនពីរ ដែលមានការមិនចុះសម្រុងគ្នាមិនអាចផ្សះផ្សាបាន ដូចក្នុងរឿងក្តីនេះ ត្រូវបានអង្គជំនុំជម្រះនេះទទួលស្គាល់រួចហើយ។ នៅក្នុងសំណុំរឿង ០០៤/០២ អ.ជ.ត.ក បានសន្និដ្ឋានថា ការខ្វែងយោបល់គ្នាជាច្រើនរវាង ស.ច.ស អស់ជាងមួយទសវត្សបានធ្វើឲ្យការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា "ស្ទើរតែមិនអាចចៀសរួច"[86]។ សំណុំរឿង០០៣ ពុំមានអ្វីខុសគ្នាទេ[87]។ ការខ្វែងយោបល់គ្នារវាង ស.ច.ស គឺកាន់តែទំនងកើតឡើងនៅក្នុងរឿងក្តីនេះ ចាប់តាំងពីពេលដែល ស.ច.ស.ជ ដកខ្លួនជាធរមានចេញពីកិច្ចស៊ើបសួរក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[88]។

58. ហេតុដូចនេះ ស.ព.អ សន្និដ្ឋានថា ភាសានៅក្នុងវិធានផ្ទៃក្នុង ដែលសំដៅទៅលើដីកាដំណោះស្រាយមួយ ត្រូវតែបកស្រាយដោយពិចារណាលើឯកសារមូលដ្ឋានគោល និងវិធានផ្សេងទៀត

---

[84] *សូមមើល* ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៥។

[85] *សូមមើល* កថាខណ្ឌ ៣០-៣១ រៀបរាប់អំពីបទប្បញ្ញត្តិ និងការប្រើពាក្យពេចន៍ដែលចែងចាប់បង្ខំ "ត្រូវធ្វើបន្ត"។ សេណារីយ៉ូដដែលនេះ មានសុពលភាព ប្រសិនបើការខ្វែងយោបល់មួយ ត្រូវបានដាក់ជូន អ.ប.ជ ឲ្យដោះស្រាយ។ ក្នុងករណីបញ្ជូនរឿងទៅជំនុំជម្រះ កិច្ចស៊ើបសួរ/រឿងក្តី បន្តទៅមុខ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលុប ច្រានចោលទេ (*សូមមើល* បទប្បញ្ញត្តិដែលបានរៀបរាប់នៅក្នុងផ្នែក III ង *យោងខាងលើ* និងការពិភាក្សាបន្ថែមនៅក្នុងផ្នែក V.ឃ *យោងខាងក្រោម*)។

[86] សំណុំរឿង០០៤/២- ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ អ.ជ.ត.ក កថាខណ្ឌ ៥៩ និង*តួសបញ្ជាក់ឡើងវិញ* ក្នុងកថាខណ្ឌ ៦២។

[87] ដូចបានរៀបរាប់នៅក្នុងផ្នែកទី II. ប្រវត្តិនីតិវិធី *យោងខាងលើ*។ *សូមមើលផងដែរ* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥, ៧, ១៥, ២៧ (ការខ្វែងយោបល់ ត្រូវបានកត់ត្រាក្នុងបញ្ជីរវាង ស.ច.ស នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ដែលការកត់ត្រាក្នុងបញ្ជីចុងក្រោយពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នា)។

[88] ដូចបានរៀបរាប់ក្នុងផ្នែកទី II. ប្រវត្តិនីតិវិធី កថាខណ្ឌ ៩ និងជើងទំព័រ ១៧, ២៤ *យោងខាងលើ*។

ដូចបានពិភាក្សាខាងលើ ដែលប្រមើលទុកនូវការខ្វែងយោបល់គ្នា ដែលអាចនាំឱ្យមានការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរ។ ឧទាហរណ៍ វិធាន៦៧(១) នៃវិធានផ្ទៃក្នុង ដែលតម្រូវឱ្យ ស.ច.ស បិទបញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយមួយ ត្រូវបកស្រាយនៅក្នុងបរិបទនេះ និងផ្គួបជាមួយវិធាន១(២) នៃវិធានផ្ទៃក្នុង ដែលចែងថាការយោងដល់ ស.ច.ស រួមទាំងការបំពេញកិច្ចរួមគ្នា និង បំពេញកិច្ចដាច់តែឯង។ មានន័យដោយតុល្យភាពថា ស.ច.ស ម្នាក់ៗអាចចេញដីកាដំណោះស្រាយមួយ។

59. ការវិភាគលើប្រព័ន្ធដឹកនាំដោយចៅក្រម ទាំងនៅកម្រិតជាតិ និងកម្រិតអន្តរជាតិ រំលេចអំពីលក្ខណៈពិសេសនៃក្របខណ្ឌគតិយុត្តនៃតុលាការនេះ ដែលអនុញ្ញាតការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរ។ នៅ*កម្រិតជាតិ* ពុំមានប្រព័ន្ធដែលចៅក្រមស៊ើបសួរឯករាជពីររូប ឬច្រើនរូប ដែលមានឋានៈស្មើគ្នាធ្វើការជាមួយគ្នាលើសំណុំរឿងមួយ ដោយគ្មាននីតិវិធីធ្វើការសម្រេចចិត្តច្បាស់លាស់ដើម្បីបញ្ចៀសការទាល់ច្រកផ្នែកនីតិវិធីឡើយ។ នៅក្នុងប្រទេសអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលឡភាគច្រើនដែលប្រើចៅក្រមស៊ើបអង្កេត[89] រួមទាំងកម្ពុជាផង[90] ចៅក្រមស៊ើបសួរជាធម្មតាធ្វើការម្នាក់ឯងជាលទ្ធផល គឺច្បាប់ពុំមានចែងអំពីលទ្ធភាពនៃការចាត់តាំងចៅក្រមលើសពីមួយរូបក្នុងសំណុំរឿងមួយឡើយ[91]។ ក្នុងប្រទេសដែលមានការចាត់តាំងចៅក្រមស៊ើបសួរចំនួន២ ឬច្រើនរូប

[89] ប្រហែលពាក់កណ្តាលនៃប្រទេសប្រើប្រព័ន្ធច្បាប់ស៊ីវិលឡ មិនមានមុខងារចៅក្រមស៊ើបអង្កេតឯករាជ្យក្នុងក្របខណ្ឌគតិយុត្តរបស់ខ្លួនទេ។ ក្នុងនោះមានប្រទេសអង់ដូរ៉ា, អូទ្រីស, បូស្នី និងហឺហ្សេហ្គោវីណា, ប្រេស៊ីល, ប៊ូរុនឌី, ចិន (សាធារណរដ្ឋប្រជាមានិត), ស៊ីលី, កូឡុំប៊ី, កូស្តារីកា, ក្រូអាស៊ី, ដាណឺម៉ាក, សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, ហ្វាំងឡង់, ក្វាតេម៉ាឡា, ហុងឌូរ៉ាស, អ៊ីស្លង់, អ៊ីតាលី, ជប៉ុន, កូសូវ៉ូ, ឡេតូនី, ម៉ិកស៊ិក, នីការ៉ាហ្គា, ន័រវែស, ប៉ារ៉ាហ្គាយ, ប៉េរូ, សាធារណរដ្ឋម៉ាសេដ្វានខាងជើង, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, រ៉ូម៉ានី, ស៊ែប៊ី, ស៊ុយអែត, ស្វីស, តៃវ៉ាន់ (សាធារណរដ្ឋ), តួកគី, អ៊ុយរូហ្គាយ និងវ៉េណេស៊ុយអេឡា។

[90] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនចែងអំពីការចាត់តាំងចៅក្រៅស៊ើបអង្កេតច្រើនជាងមួយរូបក្នុងមួយសំណុំរឿងឡើយ (ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧)។ ក្នុងករណីមានទំនាស់រវាងចៅក្រមស៊ើបសួរនៃសាលាដំបូងខុសគ្នា មាត្រា ១២៣ ចែងថាប្រធានសភាស៊ើបសួរ ដោះស្រាយទំនាស់នោះ។ ទោះជាយ៉ាងនេះក្តី សំណុំរឿងមួយ អាចដកហូតពីចៅក្រមស៊ើបសួរមួយរូប ហើយប្រគល់ឱ្យចៅក្រមស៊ើបសួរម្នាក់ទៀត ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អនៃយុត្តិធម៌ (មាត្រា៥៣) ហើយចៅក្រមស៊ើបសួរមួយរូប ក៏អាចចេញដីកាចាត់ឱ្យស៊ើបជំនួសដោយអនុញ្ញាតឱ្យចៅក្រមមួយរូបទៀត ធ្វើការស៊ើបសួរជំនួសឱ្យខ្លួន។ ដីកាចាត់ឱ្យស៊ើបជំនួស បញ្ជាក់អំពីចរិតលក្ខណៈនៃកិច្ចស៊ើបសួរដែលត្រូវអនុវត្ត (មាត្រា១៧៣-១៧៤)។

[91] *សូមមើល ឧទាហរណ៍* ក្រមនីតិវិធីព្រហ្មទណ្ឌនៃ**<u>ប្រទេសអាហ្សង់ទីន</u>** ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ មាត្រា ១៨០, ១៨៨, ១៩៤, ១៩៦។ **<u>ប្រទេសបែលហ្ស៊ិក</u>** Titre préliminaire (នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩) មាត្រា ១២ ស្ទួន Livre premier (នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១) មាត្រា៥៥-៥៦, ៦១, ៦២ ស្ទួន, ១២៧ Livre II, Titre V (នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦) មាត្រា

ធ្វើការជាមួយគ្នាលើរឿងក្ដីស្មុគស្មាញមួយ ចៅក្រមមួយរូបជាអ្នកសម្របសម្រួល និងសម្រេចជាចុងក្រោយលើបញ្ហាសំខាន់ ខណៈដែលចៅក្រមដទៃទៀតជាអ្នកជួយ។ ជាជម្រើសម្យ៉ាងទៀត សេចក្ដីសម្រេចត្រូវបានធ្វើឡើងដោយមតិភាគច្រើន ឬ ចៅក្រមដែលសម្របសម្រួល/ជាប្រធាន មានសំឡេងសម្រេច។

60. ឧទាហរណ៍ នៅក្នុងតុលាការខ្លះក្នុងប្រទេសបារាំង ចៅក្រមស៊ើបសួរត្រូវបានបង្កើតជាក្រុមស៊ើបសួរ ដែលក្នុងនោះចៅក្រមស៊ើបសួរពីររូប ឬច្រើនរូបអាចទទួលរឿងក្ដីរួមគ្នា ដែលមានលក្ខណៈធ្ងន់ធ្ងរ ឬស្មុគស្មាញ (ក្នុងនោះមានដូចជាភេរវកម្ម និង ឧក្រិដ្ឋកម្មអន្តរជាតិ)។ នៅក្នុងស្ថានភាពបែបនេះ ចៅក្រមស៊ើបសួរមួយរូបត្រូវបានចាត់តាំងទទួលបន្ទុកស៊ើបសួរ សម្របសម្រួល និងធ្វើការសម្រេចតែម្នាក់ឯង ដូចជាការព្រាង និងការចេញដីកាដំណោះស្រាយ ចំណែកចៅក្រមផ្សេងទៀតគ្រាន់តែជួយគាត់[92]។ ប្រទេសអាល់ហ្សេរី, សាធារណរដ្ឋអាហ្វ្រិកកណ្ដាល, ហ្គីនេ និង ហ្គាបុង សុទ្ធតែ

---

៥៤០។ **ប្រទេសបេណាំង** ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ មាត្រា ៤៣, ៨៦, ៨៩។ ប្រទេស**បូលីវី** ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ មាត្រា ៥៤។ **ប្រទេស បួគីណាហ្វាសូ** ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ មាត្រា ២៤៣-១, ២៤៣-២៤៣-៣, ២៤៣-៤, ២៦១-២។ **ប្រទេសឆាដ** នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៤ មាត្រា ២៣១-២៣២។ **សាធារណរដ្ឋដូមីនីក** ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០២ មាត្រា៦៣, ៧៣, ៣៧៩។ **ប្រទេសអេស្តូនី** នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ មាត្រា ២១, ២៤។ **ប្រទេសអាល្លឺម៉ង់** នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ មាត្រា១៦២, ១៦៥, ១៦៩។ **ប្រទេសក្រិក** ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ មាត្រា ៣១ (២), ២៤៦-២៤៧។ **ប្រទេសហ្គីយ៉ាន** នៅខែមីនា ឆ្នាំ១៩៩៨ មាត្រា ៥១, ៦៥, ៧២។ **ប្រទេសហៃទី** ឆ្នាំ១៩៣៥ មាត្រា ៣៥, ៤៨, ៥១។ **ប្រទេសម៉ុងតេណេហ្គ្រោ** នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០១ មាត្រា ២៧៦, ២៩៣។ **ប្រទេសម៉ារុក** នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ មាត្រា ៤៤, ៥២-៥៥។ **ប្រទេសហូឡង់** នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ មាត្រា ៥៩ក, ៦៣, ១០៥, ១១០, ១៧០, ១៧២, ១៧៧, ១៨២, ២៣៨។ **ប្រទេសព័រទុយហ្គាល់** នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ មាត្រា ១៧, ១៤២, ២៦៨, ២៨៨។ **សាធារណរដ្ឋកុងហ្គោ** ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦៣ មាត្រា ៥៨១-៥៨២។ **ប្រទេសស្លូវេនី** នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ មាត្រា ២៥, ១៧១។ **ប្រទេសអេស្ប៉ាញ** នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ មាត្រា ២២-២៣, ៣០៣។ **ប្រទេសទុយនីស៊ី** នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៧ មាត្រា ៤៩។

[92] **ប្រទេសបារាំង**៖ ក្រមនីតិវិធីព្រហ្មទណ្ឌ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ (“FCCP”) មាត្រា ៥២-១ (*បកប្រែក្រៅផ្លូវការ៖* “[…] នៅក្នុងសាលាក្ដីខ្លះ ចៅក្រមស៊ើបសួរ ត្រូវបានដាក់នៅក្នុងក្រុមស៊ើបសួរ។ ចៅក្រមស៊ើបសួរ ដែលជាផ្នែកមួយនៃក្រុមស៊ើបសួរ […] មានសមត្ថភាពពេញលេញសម្រាប់កិច្ចស៊ើបសួរ ដែលត្រូវចាត់ឲ្យបំពេញជាមួយគ្នា អនុលោមតាមមាត្រា ៨៣-១ និង ៨៣-២”)។ មាត្រា ៨៣-១ (*បកប្រែក្រៅផ្លូវការ* “នៅពេលមានមូលហេតុសមស្រប ផ្អែកលើស្ថានទម្ងន់ ឬភាពស្មុគស្មាញកិច្ចស៊ើបសួរ អាចត្រូវចាត់ឲ្យបំពេញជាមួយគ្នា […]។ ប្រធានអង្គជំនុំជម្រះដែលមានក្រុមស៊ើបសួរ […] នៅពេលបើកកិច្ចស៊ើបសួរ ចាត់តាំងចៅក្រមស៊ើបសួរមួយរូប ឬច្រើនរូប ដើម្បីជួយចៅក្រមទទួលបន្ទុកកិច្ចស៊ើបសួរ”)។ មាត្រា ៨៣-២ (*បកប្រែក្រៅផ្លូវការ៖* “ក្នុងករណីបំពេញកិច្ចស៊ើបសួរជាមួយគ្នា ចៅក្រមស៊ើបសួរទទួលបន្ទុកកិច្ចស៊ើបសួរ ធ្វើការសម្របសម្រួលលើកិច្ចស៊ើបសួរ។ មានតែគាត់ម្នាក់គត់ដែលមានសិទ្ធិស្នើឲ្យ *ចៅក្រមទទួលខុសត្រូវលើការដោះលែង និងការឃុំឃាំង* ចេញដីកាដោះលែងតាមបទប្បញ្ញត្តិច្បាប់ និងចេញសេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់កិច្ចស៊ើបសួរ ដូចមានចែងក្នុងមាត្រា ១៧៥ និងដីកា

មានប្រព័ន្ធស្រដៀងគ្នានេះ[93]។ ក្នុងប្រទេសអាយវ៉ូរីខូស ដីកា - រួមមានដីកាដំណោះស្រាយផងដែរ - ត្រូវបានសម្រេចដោយសហចៅក្រមស៊ើបសួរដែលបានចាត់តាំង។ ក្នុងករណីជាប់គាំង សហចៅក្រមស៊ើបសួរដែលសម្របសម្រួលត្រូវតែមានសំឡេងកំណត់សម្រេច[94]។

---

ដំណោះស្រាយ")។ ទោះជាយ៉ាងនេះក្តី សេចក្តីជូនដំណឹងនេះ និងដីកានេះ អាចត្រូវបានចុះហត្ថលេខារួមគ្នាដោយចៅក្រមមួយរូប ឬច្រើនជាងមួយរូបដែលត្រូវបានចាត់ឲ្យបំពេញកិច្ចស៊ើបសួររួមគ្នា" (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* B. Bouloc *និង គូកន Procédure pénal* ការបោះពុម្ពផ្សាយលើកទី២៧ (២០២០) កថាខណ្ឌ ៥៩៥ (ក), ៥៩៦ (គ), L. Belfanti, "Juge d'instruction – Le statut du juge d'instruction", Répertoire de droit pénal et de procédure pénale, Dalloz, ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ៣១៦, ៧០៦, C. Guéry និង P. Chambon, *Droit et pratique de l'instruction préparatoire*, ការបោះពុម្ពផ្សាយលើកទី១០ (២០០៧) , Dalloz Action, "Chapitre 112 – Désignation du juge d'instruction", កថាខណ្ឌ១១២.២៩។

[93] **<u>អាល់ហ្សេរី</u>**៖ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា ៧០ (*ការបកប្រែក្រៅផ្លូវការ*៖ "ក្នុងករណីមានភាពធ្ងន់ធ្ងរ ឬ ភាពស្មុគស្មាញនៃរឿងក្តីតម្រូវ រដ្ឋអាជ្ញាសាធារណៈអាចតែងតាំងចៅក្រមស៊ើបសួរម្នាក់ ឬ ច្រើននាក់ដែលគាត់នឹងតែងតាំង បន្ថែមលើចៅក្រមស៊ើបអង្កេតដែលទទួលបន្ទុកការស៊ើបអង្កេត [...]។ ចៅក្រមទទួលបន្ទុកស៊ើបអង្កេតត្រូវសម្របសម្រួលវឌ្ឍនភាពនៃការស៊ើបអង្កេត និងត្រូវមាន<u>អំណាចសម្រេចលើ</u>ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន និងចេញដីកាសម្រេច"(គូសបញ្ជាក់បន្ថែម)។ **<u>សាធារណរដ្ឋអាហ្វ្រិកកណ្តាល</u>**៖ ក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ មាត្រា ៥៣ (*ការបកប្រែក្រៅផ្លូវការ*៖ "ក្នុងករណីមានភាពធ្ងន់ធ្ងរ ឬ ភាពស្មុគស្មាញនៃរឿងក្តីតម្រូវ ប្រធានតុលាការឧទ្ធរណ៍ [...] អាចតែងតាំងចៅក្រមស៊ើបសួរម្នាក់ ឬច្រើននាក់ពីដែនសមត្ថកិច្ចរបស់ខ្លួនដើម្បី<u>ជួយ</u>ចៅក្រមស៊ើបសួរ [...]។ <u>ចៅក្រមទទួលបន្ទុក</u>ស៊ើបអង្កេតត្រូវសម្របសម្រួលដំណើរការនៃការស៊ើបអង្កេត។ ទោះយ៉ាងណាក៏ដោយ វិធានការនៃការឃុំខ្លួន ការដោះលែង ការត្រួតពិនិត្យតាមផ្លូវតុលាការ និងដីកាសម្រេចត្រូវធ្វើឡើងរួមគ្នា។ ចៅក្រមសម្របសម្រួលនេះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារពាក់ព័ន្ធតែម្នាក់ឯង។" (គូសបញ្ជាក់បន្ថែម)) មាត្រា ៣៤(ខ)។ នៅ**<u>ហ្គីណេ</u>** ចំពោះរឿងក្តីស្មុគស្មាញ ច្បាប់ចែងថា ក្រុមចៅក្រមស៊ើបអង្កេតអាចត្រូវបានបង្កើតឡើង ប៉ុន្តែមានតែចៅក្រមម្នាក់ដែលទទួលខុសត្រូវលើការស៊ើបអង្កេតនីមួយៗ (ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ខែកុម្ភៈ ឆ្នាំ ២០១៦ មាត្រា ៦២, ១៥៣)។ នៅប្រទេស**<u>ហ្គាបុង</u>** លទ្ធភាពនៃការចាត់តាំងចៅក្រមស៊ើបអង្កេតពីរនាក់ ឬ ច្រើននាក់សម្រាប់រឿងក្តីស្មុគស្មាញមាន ប៉ុន្តែមិនមានបទប្បញ្ញត្តិចែងច្បាស់អំពីរបៀបដែលសេចក្តីសម្រេចត្រូវបានធ្វើឡើង (ក្រមនីតិវិធីព្រហ្មទណ្ឌថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ មាត្រា ៩២)។ នៅក្នុងស្ថានភាពជាក់ស្តែងទាំងអស់ វាគួរតែត្រូវបានបញ្ជាក់នៅក្នុងដីកាបង្គាប់ចាត់តាំងសហចៅក្រម។

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ មាត្រា ១០២ (*ការបកប្រែក្រៅផ្លូវការ*៖ "ក្នុងករណីមានចៅក្រមស៊ើបសួរជាច្រើននៅក្នុងតុលាការ ប្រធានតុលាការត្រូវចាត់តាំងចៅក្រមដែលទទួលខុសត្រូវចំពោះការស៊ើបអង្កេតនីមួយៗ។ ប្រធានតុលាការក៏អាចចាត់តាំងចៅក្រមស៊ើបអង្កេតពីរ ឬ ច្រើននាក់ ឲ្យបំពេញកិច្ចនៅក្នុងរឿងក្តីស្មុគស្មាញ ឬ ធ្ងន់ធ្ងរពាក់ព័ន្ធបទចោទច្រើន។ ក្នុងករណីនេះ ប្រធានតុលាការត្រូវតែងតាំងចៅក្រមស៊ើបសួរម្នាក់ដើម្បីសម្របសម្រួលការស៊ើបអង្កេត។ រាល់កិច្ចស៊ើបអង្កេតនីមួយៗត្រូវចុះហត្ថលេខាដោយចៅក្រមស៊ើបសួរដែលបានស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ ដីកាសម្រេចត្រូវធ្វើឡើងរួមគ្នា។ *ក្នុងករណីមានការមិនឯកភាព ចៅក្រមសម្របសម្រួលមានសិទ្ធិសម្រេច (សម្រេច)*" (គូសបញ្ជាក់បន្ថែម))។

61. នៅ*កម្រិតអន្តរជាតិ* តុលាការព្រហ្មទណ្ឌពិសេសក្នុងសាធារណរដ្ឋអាហ្វ្រិកកណ្តាល (ដែលជាសាលាក្តីកូនកាត់មួយទៀតផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលឡូ) អនុវត្តយន្តការដោះស្រាយវិវាទដែលមានអាណត្តិចែងច្បាស់លាស់ ជាការផ្ទុយស្រឡះទៅនឹងយន្តការនៅ អ.វ.ត.ក។ នៅពេលមានការខ្វែងយោបល់គ្នារវាង ស.ច.ស ជាតិ និងអន្តរជាតិ ដែលមានឋានៈស្មើគ្នាលើអង្គសេចក្តីនៃរឿងក្តី *Chambre d'Accusation Spéciale* (សភាចោទប្រកាន់ពិសេស ដូចគ្នានឹង អ.ប.ជ ដែរ) ដែលមានសមាសភាពចៅក្រមអន្តរជាតិពីររូប និង ចៅក្រមជាតិមួយរូប ទទួលដោះស្រាយវិវាទ*ដោយស្វ័យប្រវត្តិ* ដែលត្រូវបានដោះស្រាយដោយសេចក្តីសម្រេចពីមតិភាគច្រើន ដែលចេញនៅក្នុងរយៈពេល៥ថ្ងៃ។ សេចក្តីសម្រេចរបស់សភាចោទប្រកាន់ពិសេស ចងកាតព្វកិច្ចចៅក្រមស៊ើបអង្កេតទាំងពីរ[95]។ រចនាសម្ព័ន្ធនេះរារាំងមិនឱ្យមានដីកាសារធាតុផ្ទុយគ្នាណាមួយ ពីសំណាក់សហចៅក្រមស៊ើបអង្កេតឡើយ។

## ខ. ដីកាដំណោះស្រាយផ្ទុយគ្នាមិនមោឃៈ និងគ្មានសុពលភាពទេ ទោះបីជាការចេញក្នុងពេលដំណាលគ្នារបស់វាខុសច្បាប់ក៏ដោយ - រឿងក្តីត្រូវបន្តទៅជំនុំជម្រះ

62. ដីកាដំណោះស្រាយដែលផ្ទុយគ្នានេះមិនបានបញ្ឈប់រឿងក្តីនេះមិនឱ្យបន្តដំណើរការទៅជំនុំជម្រះឡើយ សូម្បីតែសន្មត *សម្រាប់គោលបំណងវែកញែក* ថាការចេញក្នុងពេលដំណាលគ្នារបស់ពួកវាខុសច្បាប់ក្តី។ ដូចបានកត់សម្គាល់ខាងលើ វាត្រូវបានកំណត់យ៉ាងត្រឹមត្រូវនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា រួមទាំង អ.វ.ត.ក ផង និងជាពិសេសនោះ អង្គជំនុំជម្រះនេះ ថាប្រសិនបើ កំហុសផ្នែកនីតិវិធីកើតមាន កំហុសនេះមិននាំឱ្យដីកាដំណោះស្រាយដែលជាលទ្ធផលទាំងនោះ ទៅជាមោឃៈ និងគ្មានសុពលភាពនោះទេ[96]។ ផ្ទុយទៅវិញ វាស្ថិតនៅក្នុងយុត្តាធិការរបស់ អ.ប.ជ ដែលជាអង្គជំនុំជម្រះឧទ្ធរណ៍នៅដំណាក់កាលមុនការជំនុំជម្រះ ក្នុងការជួសជុលវិការៈ

---

[95] ឯកសារ **D271/1.1.36** សាធារណរដ្ឋអាហ្វ្រិកកណ្តាល Loi Organique No.15.003 Portant Création Organization et Fonctionnement de la Cour PénaleSpéciale ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥ មាត្រា ១១ (*ការបកប្រែក្រៅផ្លូវការ៖* "សភាស៊ើបសួរមាន ៣ ការិយាល័យ។ ការិយាល័យនីមួយៗ មានចៅក្រមជាតិម្នាក់ និងចៅក្រមអន្តរជាតិម្នាក់")។ មាត្រា ១២ (សភាចោទប្រកាន់ពិសេស មានចៅក្រមបីរូប (ចៅក្រមអន្តរជាតិពីររូប និងចៅក្រមជាតិមួយរូប) សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលចេញដោយការិយាល័យស៊ើបអង្កេត) មាត្រា ៤១ (ចៅក្រមស៊ើបអង្កេតពីរូប ជាតិមួយរូប និងអន្តរជាតិមួយរូប ក្នុងពេលដំណាលគ្នា ចុះហត្ថលេខាលើសេចក្តីសម្រេចនីមួយៗទាក់ទងនឹងខ្លឹមសារនៃរឿងក្តី) មាត្រា ៤២ (*ការបកប្រែក្រៅផ្លូវការ៖* "ក្នុងករណីមានការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបសួរនៃការិយាល័យតែមួយ ចំណុចនៃការខ្វែងយោបល់គ្នាត្រូវកត់ត្រានៅក្នុងរបាយការណ៍ និងបញ្ជូនតាមរយៈរដ្ឋអាជ្ញាពិសេស ទៅកាន់សភាចោទប្រកាន់ពិសេស ដែលត្រូវសម្រេចក្នុងរយៈពេលប្រាំថ្ងៃ។ សេចក្តីសម្រេចរបស់សភាចោទប្រកាន់ពិសេស [...] ចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេត"។

[96] *សូមមើល* ផ្នែក III.ឃ *យោងខាងលើ*។

ណាមួយ តាមរយៈការពិនិត្យលើអង្គសេចក្តីរបស់ដីកាដំណោះស្រាយនីមួយៗ ដែលសម្រាប់សំអាងហេតុខុសគ្នា បានបញ្ជាក់សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[97]។ តាមពិត មានតែការពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយប៉ុណ្ណោះ ទើបទទួលបានដំណោះស្រាយត្រឹមត្រូវតាមច្បាប់ តាមតក្កវិជ្ជា និងយុត្តិធម៌សម្រាប់រឿងក្តីនេះ។ ហេតុដូច្នេះ កំហុសដែល អ.ប.ជ បានប្រព្រឹត្ត គឺមិនមែនក្នុងការពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយៗនោះទេ កំហុសនោះគឺការបរាជ័យមិនបានបញ្ជូនរឿងក្តីទៅជំនុំជម្រះ ដូចដែលត្រូវបានតម្រូវដោយការសន្និដ្ឋានរបស់ខ្លួនថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។

63. ប្រសិនបើអង្គជំនុំជម្រះនេះមិនឯកភាព ហើយត្រឡប់ទៅការពិចារណារបស់ខ្លួនអំពីដំណោះស្រាយសមស្របនោះ ការវាយតម្លៃនេះត្រូវតែពិចារណាលើកត្តាមួយចំនួន រួមមាន ទីមួយ និងសំខាន់បំផុតថាតើការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា នាំឲ្យមានភាពអយុត្តិធម៌ឬទេ ឬថាម្យ៉ាងវិញទៀត បានបណ្តាលឲ្យមានលទ្ធផលអយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីឬទេ[98]។ កត្តាផ្សេងៗទៀតដែលត្រូវតែពិចារណា រួមមាន ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ តម្លៃសង្គមនៃការរារាំងរឿងក្តីមិនឲ្យបន្តទៅមុខ ផលប្រយោជន៍ និងសិទ្ធិរបស់ភាគីទាំងអស់ និងភាពសមាមាត្រនៃដំណោះស្រាយណាមួយចំពោះព្យសនកម្មដែលបានចោទប្រកាន់[99]។ ដូចបានរៀបរាប់លម្អិតខាងក្រោម ការវាយតម្លៃបែបនេះអាចសន្និដ្ឋានបានតែថា សំណុំរឿង ០០៣ ត្រូវតែបន្តទៅជំនុំជម្រះ។

*កំហុសផ្នែកនីតិវិធីរបស់ ស.ច.ស មិនបណ្តាលឲ្យមានភាពអយុត្តិធម៌ទាំងស្រុង ផលប៉ះពាល់សំខាន់ ឬការរំលោភដំណើរការនីតិវិធីឡើយ*

64. វាគឺជាច្បាប់ដែលបានកំណត់ត្រឹមត្រូវដែលថា មិនមែនគ្រប់កំហុសនីតិវិធីមុនការជំនុំជម្រះទាំងអស់រារាំងរឿក្តីមិនឲ្យដំណើរការទៅមុខនោះទេ[100]។ ដូចបានកត់សម្គាល់ខាងលើ អ.ជ.ត.ក បានទទួលស្គាល់ចំណុចនេះដោយផ្ទាល់ និងដោយតុល្យភាព ដោយបានសម្រេចនៅក្នុងសាលដីកាបណ្តឹងសាទុក្ខនៃសំណុំរង ០០២/១ ថា មានតែកំហុសផ្នែកនីតិវិធី ដែលនាំឲ្យមាន "លទ្ធផលមិនយុត្តិធម៌ទាំងស្រុង

---

[97] សំណុំរឿង ០០៤/២-**D359/24 &D360/33** សេចក្តីពិចារណា អ.ប.ជ ក្នុងសំណុំរឿង ០០៤/២") កថាខណ្ឌ ៥២, ៨៩។ *សូមមើលផងដែរ* កថាណ្ឌ ៣៣-៣៤ *យោងខាងលើ*។

[98] *សូមមើល* ផ្នែក III.ឃ *យោងខាងលើ*។

[99] *សូមមើល* ផ្នែក III.ឃ *យោងខាងលើ*។

[100] *សូមមើល* ផ្នែក III.ឃ *យោងខាងលើ*។

នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ” ប៉ុណ្ណោះ តម្រូវឱ្យមានអន្តរាគមន៍ភ្លាមៗ[101] ហើយ នៅក្នុងសំណុំរឿង ០០៤/២ ថា អ.ប.ជ អាចជួសជុលការចេញខុសប្រក្រតីនៃដីកាដំណោះស្រាយទាំងពីរបាន ដោយការចេញដីកាដំណោះស្រាយមានសុពលភាពរបស់ខ្លួន ដែលអាចប្រើជាមូលដ្ឋាននៃការជំនុំជម្រះ[102]។ សំណុំរឿង ០០៣ មានលក្ខណៈខុសពីសំណុំរឿង ០០៤/២។ បន្ថែមលើគោលជំហរស្វ័យប្រវត្តិ ដែលកំណត់អាណត្តិការជំនុំជម្រះ មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចៅក្រមទាំងប្រាំរូបបានសន្និដ្ឋានថាមានសុពលភាព ដើម្បីប្រើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះ។ អ.ប.ជ បានពិនិត្យអង្គសេចក្តីនៃដីកានីមួយៗ ដូច្នេះបានចូលរួមក្នុងការវាយតម្លៃដូចគ្នាដែលខ្លួនបានធ្វើ ប្រសិនបើ ស.ច.ស បានដាក់ការខ្វែងយោបល់របស់ពួកគេមក អ.ប.ជ ដើម្បីដោះស្រាយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ការវាយតម្លៃនោះ ជាចុងក្រោយបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ទោះបីជាមានសំអាងហេតុខុសគ្នាក៏ដោយ។ ហេតុដូច្នេះ មិនមានលទ្ធផលអយុត្តិធម៌ទាំងស្រុងដែលតម្រូវឱ្យមានដំណោះស្រាយភ្លាមៗ នៃការបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ។

65. លើសពីនេះទៀត មិនមានចែងទាល់តែសោះនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ឬច្បាប់ អ.វ.ត.ក ដែលហាមឃាត់យ៉ាងដាក់លាក់មិនឱ្យចេញដីកាដំណោះស្រាយពីរខ្វែងគ្នា។[103] ដូច្នេះ បញ្ហាវិវាទសម្រាប់ការវិភាគរបស់ អ.ជ.ត.ក អាស្រ័យលើការបកស្រាយវិធានផ្ទៃក្នុង អ.វ.ត.ក។ ដូចនៅទីនេះ ក្នុងករណីដែលការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា បង្កើតបានជាការរំលោភបំពានណាមួយដែលអាចមានលើវិធានផ្ទៃក្នុងទាំងអស់នោះ[104] យុត្តិសាស្ត្រអន្តរជាតិបញ្ជាក់ច្បាស់ថា រឿងក្តីមួយត្រូវបានរារាំងមិនឱ្យរំកិលទៅមុខប្រសិនបើមានការបង្ហាញពីកំហុសដែលបណ្តាលឱ្យមានផលប៉ះពាល់សំខាន់តែប៉ុណ្ណោះ[105]។ មិនមានការបង្ហាញបែបនេះនៅទីនេះទេ។ ហើយក៏មិនអាចមានដែរ។ ការកំណត់ពីការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជា អំពើប្រល័យពូជសាសន៍ និង

---

[101] សំណុំរឿង ០០២-**F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។

[102] *សូមមើល* សំណុំរឿង ០០៤/២-**E004/2/1/1/2** 2 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ អ.ជ.ត.ក កថាខណ្ឌ ៦១ (មានចែងនៅក្នុងកថាខណ្ឌ ៣៤ *យោងខាងលើ*)។ ក្នុងសំណុំរឿង ០០៣ អ.ប.ជ បានជួសជុលកំហុសដែលមិនធ្ងន់ធ្ងរ ដោយការឯកភាពជាឯកច្ឆន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ដែលជាសេចក្តីសម្រេចក្នុងអត្ថន័យ ៧៧(១៣) នៃវិធានផ្ទៃក្នុង ដែលបញ្ជូនរឿងក្តីទៅជំនុំជម្រះ។ ឬ ជាជម្រើសម្យ៉ាងទៀត គោលជំហរស្វ័យប្រវត្តិ និងកំណត់សម្រេចបញ្ជូនរឿងក្តីទៅជំនុំជម្រះ (*សូមមើល* ផ្នែក V.ឃ *យោងខាងក្រោម*)។

[103] *សូមមើល* ផ្នែក V.ក *យោងខាងលើ*។

[104] ដូចបានពិភាក្សានៅក្នុងផ្នែក V. ក *យោងខាងលើ* ស.ព.អ សន្និដ្ឋានការចេញនេះមិនរំលោភលើវិធានទាំងនោះទេ។

[105] *សូមមើល ឧទាហរណ៍* ឯកសារសំអាងផ្លូវច្បាប់ដែលបានដកស្រង់ក្នុងជើងទំព័រ៥៤ និង៥៥ *យោងខាងលើ*។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងការជំនុំជម្រះដ៏ត្រឹមត្រូវ និងមិនលម្អៀង ដែលគោរពដល់សិទ្ធិរបស់ភាគីទាំងអស់ នឹងមិនបង្កផលប៉ះពាល់សំខាន់ដល់ មាស មុត ឡើយ។ ហើយគេក៏មិនអាចតវ៉ាថា ការដែលត្រូវបដិសេធអត្ថប្រយោជន៍ដោយចៃដន្យ នៃការគេចចេញពីការសម្រេចតាមផ្លូវតុលាការចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ បង្កើតបានជាផលប៉ះពាល់សំខាន់នោះទេ។ អំណះអំណាងបែបនេះគឺផ្ទុយទៅនឹងច្បាប់ តក្កវិជ្ជា និងយុត្តិធម៌។ តាមពិត មាស មុត បានតវ៉ាដោយផ្ទាល់ជាដដែលៗថា វាជាការបរាជ័យក្នុងការមិនមានឱកាសតទល់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបង្កើតព្យសនកម្មដល់រូបគាត់[106]។

66. កាលៈទេសៈនានានៃរឿងក្ដីនេះក៏បង្ហាញផងដែរថា ការចេញដីកាដំណោះស្រាយពីរខ្វែងគ្នារបស់ ស.ច.ស មិនបានបណ្ដាលឲ្យមានការរំលោភបំពានជាក់ស្ដែងលើសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ មាស មុត ដែលបង្កើតបានជាការរំលោភលើដំណើរការដែលចាំបាច់ត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ[107]។ ហើយក៏មិនមានមូលដ្ឋានណាផ្សេងពីនេះដើម្បីសន្និដ្ឋានពីការរំលោភបំពានណាមួយលើដំណើរការ ដែលចាំបាច់ត្រូវមានដំណោះស្រាយបែបនោះដែរ។ កិច្ចដំណើរការនីតិវិធីត្រូវបានប្រព្រឹត្តឡើងដោយមិនមានការពន្យារពេលហួសហេតុ ដោយផ្អែកទៅលើភាពស្មុកស្មាញផ្នែកអង្គហេតុ និងអង្គច្បាប់នៃរឿងក្ដី (រួមទាំង *ក្នុងចំណោមរឿងផ្សេងទៀត* ចំនួនឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃរឿងក្ដី និងបរិមាណនៃភ័ស្តុតាង)[108]។ ជាងនេះទៀត ពេលនេះ មាស មុត មិនស្ថិតនៅក្នុងការឃុំឃាំងរបស់ អ.វ.ត.ក ទេ ហើយក៏មិនធ្លាប់បានដែរ ដោយបានរស់នៅយ៉ាងមានសេរីភាពក្នុងរយៈពេលនៃការស៊ើបអង្កេតទាំងមូល ដោយមិនមានការរិតត្បិតដ៏មានអត្ថន័យលើ

---

[106] *សូមមើល ឧទាហរណ៍* **D272** សំណើរបស់ មាស មុត សុំឲ្យបញ្ចប់ កថាខណ្ឌ ៥៤, ៧១។ ឯកសារ **D267/27** សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ទំព័រ១ កថាខណ្ឌ ២៤, ៥០។ ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤, ៤២-៤៣។ ឯកសារ **D256/11** ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៩, ៦៧។ ឯកសារ **D249/2** សារណារបស់ មាស មុត ស្ដីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់លើរឿងក្ដី ០០៣ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ២៨-២៩។

[107] *សូមមើល* កថាខណ្ឌ ៣៦ *យោងខាងលើ*។

[108] សម្រាប់ការពិភាក្សាពេញលេញលើកត្តាទាំងអស់នេះ និងយុត្តិសាស្ត្រដែលកត្តាទាំងនេះផ្អែកលើ *សូមមើល* ឯកសារ **D272/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំឲ្យបញ្ចប់នីតិវិធី បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ (“ចម្លើយតបរបស់ ស.ព.អ ស្ដីពីការរំលោភនីតិវិធី”) កថាខណ្ឌ ៤-១៦។

សេរីភាពបុគ្គលរបស់គាត់ឡើយ[109]។ តាមពិតនោះ ការស្នង់មតិរបស់តុលាការអន្តរជាតិផ្សេងទៀតបង្ហាញថា កិច្ចដំណើរការនីតិវិធីតុលាការដែលមានរយៈពេលវែងស្រដៀងគ្នាទៅនឹងសំណុំរឿង ០០៣ នេះ មិនត្រូវបានរកឃើញថាត្រូវបានពន្យារពេលហួសហេតុឡើយ ទោះបីជាអង្គហេតុដែលថាជនជាប់ចោទផ្សេងទៀតស្ថិតក្នុងការឃុំខ្លួនក៏ដោយ[110]។ ជារួម មិនមានការរំលោភបំពានដែលបង្កឡើងដោយកំហុសផ្នែកនីតិវិធីរបស់ ស.ច.ស ដែលអាចបំពេញលក្ខខណ្ឌតម្រូវដ៏ខ្ពស់ដែលចាំបាច់ដើម្បីផ្តល់យុត្តិកម្មដល់ការបញ្ចប់ឡើយ[111]។

*ដំណោះស្រាយណាដែលរារាំងរឿងក្តីនេះមិនឱ្យបន្តទៅមុខបាន គឺមិនសមាមាត្រទៅនឹងព្យសនកម្មដែលបានចោទប្រកាន់*

67. ផ្អែកលើអង្គហេតុនៃរឿងក្តីនេះ ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាមិនតម្រូវឱ្យមានវិធានការដំណោះស្រាយនោះទេ។ សន្មតថា ដំណោះស្រាយចាំបាច់ត្រូវមាន ការកំណត់អំពីអ្វីដែលជាដំណោះស្រាយនោះ តម្រូវឱ្យអង្គជំនុំជម្រះពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតម្លៃសង្គមដ៏ខ្ពស់ដែលមាន ប្រសិនបើឧក្រិដ្ឋកម្មបែបទាំងនេះមិនត្រូវបានវិនិច្ឆ័យទេនោះ[112]។ អង្គជំនុំជម្រះត្រូវរក្សារផងដែរនូវ ការថ្លឹងថ្លែងដ៏ត្រឹមត្រូវរវាងសិទ្ធិរបស់ជនជាប់ចោទ និងផលប្រយោជន៍ជាសារវន្តរបស់សហគមន៍កម្ពុជា និងអន្តរជាតិ ក្នុងការកាត់សេចក្តីជនទាំងឡាយដែលត្រូវបានចោទប្រកាន់ដោយឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុត ដើម្បីជាការធានាថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះ មានសំឡេងដ៏មានអត្ថន័យ[113]។ សិទ្ធិរបស់ភាគីត្រូវតែទទួលបានការពិចារណា រួមទាំងសិទ្ធិរបស់ជនរងគ្រោះ

---

[109] ឯកសារ **D272/1** ចម្លើយតបរបស់ ស.ព.អ ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ ១៣។

[110] ឯកសារ **D272/1** ចម្លើយតបរបស់ ស.ព.អ ស្តីពីការរំលោភនីតិវិធី កថាខណ្ឌ ១៦។

[111] *សូមមើល* ផ្នែក III.ឃ *យោងខាងលើ* ជាពិសេស កថាខណ្ឌ ៣៦។

[112] *សូមមើល* ផ្នែក III.ឃ *យោងខាងលើ* ជាពិសេស កថាខណ្ឌ ៣៥។ សំណុំរឿង ០០២-**D264/2/6** សាលដីកាក្នុងរឿងក្តី អៀង ធីរិទ្ធ ចំពោះការរំលោភនីតិវិធី កថាខណ្ឌ ២៨។ *Hudson ទល់នឹង Michigan*, 547 U.S. 586, 591 (២០០៦)។

[113] សំណុំរឿង ០០២-ឯកសារ **D264/2/6** សាលដីកាស្តីពីការរំលោភបំពានដំណើរការក្នុងរឿងក្តី អៀង ធីរិទ្ធ, កថាខណ្ឌ ២៨។ ចំណុចនេះមានលក្ខណៈច្បាស់លាស់ជាពិសេស ក្នុងការអះអាងអំពីការរំលោភបំពានដំណើរការនីតិវិធី ដែលបានលើកនៅឯតុលាការ ICTY, ICTR និង ICC។ *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចស្តីពីនីត្យានុកូលភាពក្នុងរឿងក្តី *Nikolić*, កថាខណ្ឌ ២៤ (“ក្នុងករណីបទឧក្រិដ្ឋ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានទទួលស្គាល់ និងផ្តន្ទាទោសជាសកលថាជា [...] អាចនិយាយបានថា តុលាការនានាហាក់ដូចជារកឃើញពីចរិកលក្ខណៈពិសេសនៃបទល្មើសទាំងនេះ និងនៅក្នុងភាពធ្ងន់ធ្ងររបស់ពួកវា នូវមូលហេតុដ៏ល្អក្នុងការពិចារណាលើយុត្តាធិការ”) ២៥-២៦, ៣០ (“អាស្រ័យហេតុនេះ តុល្យការដែលត្រឹមត្រូវ ត្រូវតែរក្សាឱ្យបានរវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងផលប្រយោជន៍សំខាន់ៗរបស់សហគមន៍អន្តរជាតិនៅក្នុងការចោទប្រកាន់ជនត្រូវចោទចំពោះការរំលោភធ្ងន់ធ្ងរ

និងអយ្យការផង ដូចមានចែងក្នុងវិធាន ២១(១)[114]។ ផលប្រយោជន៍បែបទាំងនេះ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់បារាំង និងកម្ពុជា និងដោយតុលាការនេះ ព្រមទាំងតុលាការអន្តរជាតិផ្សេងទៀត[115]។ ការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ គឺជាការថ្លឹងថ្លែងដ៏ត្រឹមត្រូវ។ ផលប្រយោជន៍

---

លើច្បាប់មនុស្សធម៌អន្តរជាតិ")។ *រដ្ឋអាជ្ញា ទល់នឹង Karadžić*, IT-95-5/18-AR73.4, សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ Karadžić ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីកិច្ចព្រមព្រៀង Holbrooke ដែលរងការជំទាស់ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ៤៩, ៥២-៥៣ (រម្លឹកថា "គោលដៅមួយក្នុងចំណោមគោលដៅនានាជាមូលដ្ឋានរបស់តុលាការ និងសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិ គឺដើម្បីបញ្ចប់និទណ្ឌភាព និងដើម្បីធានាឲ្យប្រាកដថា ការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវបានចោទប្រកាន់ និងផ្ដន្ទាទោស" និងអង្គហេតុនានាដែលនាំឱ្យកើតមាននូវការរំពឹងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ចំពោះនិទណ្ឌភាព និងបើទោះបីជាមានភស្តុតាងបញ្ជាក់ ក៏វានឹងមិនបញ្ជេះឲ្យមានការរំលោភបំពានដំណើរការដើម្បីយកជាយុត្តិកម្មក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីនោះដែរ)។ *សាលដីកាក្នុងរឿងក្ដី Kajelijeli* កថាខណ្ឌ ២០៦។ សេចក្ដីសម្រេចស្ដីពីការពន្យារពេលមិនត្រឹមត្រូវក្នុងរឿងក្ដី *Karemera* កថាខណ្ឌ ៨, ១១។ ការអនុវត្តតាមអភិក្រមនេះ នឹងផ្ដល់នូវទម្ងន់យ៉ាងសំខាន់ទៅលើគោលបំណងធំរបស់ អ.វ.ត.ក គឺក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ប្រឆាំងនឹងប្រជាជនកម្ពុជា (*សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១ ច្បាប់ អ.វ.ត.ក មាត្រា ១, ២ថ្មី)។

[114] វិធាន ២១(១)។ *សូមមើលផងដែរ* មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្ដីប្រកាសស្ដីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាច UNGA Res 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ គោលការណ៍ទី ៤ ("ត្រូវប្រព្រឹត្តចំពោះជនរងគ្រោះដោយក្ដីមេត្តា និងគោរពចំពោះសេចក្ដីថ្លៃថ្នូររបស់ពួកគេ។ ជនរងគ្រោះមានសិទ្ធិទទួលបានយន្តការយុត្តិធម៌នានា និងដោះស្រាយទាន់ពេលវេលាចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង ដូចមានចែងនៅក្នុងនីតិប្បញ្ញត្តិជាតិ")។

[115] **<u>ប្រទេសបារាំង៖</u>** CCP, article préliminaire; Conseil Constitutionnel, No. 95-360, ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩៥ កថាខណ្ឌ ៥។ Pradel, *Manuel de Procédure Pénale* (បោះពុម្ពលើកទី១៤) ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ ១៤១។ **<u>ប្រទេសកម្ពុជា៖</u>** ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤។ **<u>អ.វ.ត.ក៖</u>** សំណុំរឿង ០០២-ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៧ ("អង្គបុរេជំនុំជម្រះបកស្រាយវិធានផ្ទៃក្នុងដោយគិតពិចារណាទៅលើលក្ខណៈ ទំហំ និងទម្រង់នៃការចូលរួម ព្រមទាំងធាតុផ្សំបង្កើតបទល្មើសដែលរងការចោទប្រកាន់ *ព្រមទាំងពីតម្រូវការរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់* ដូចបានមានចែងក្នុងលិខិតុបករណ៍ជាសារវន្តរបស់ អ.វ.ត.ក" (គូសបញ្ជាក់បន្ថែម)។ សំណុំរឿង ០០២-ឯកសារ **E50/2/1/4** សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ លើសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩ (កត់សម្គាល់ថា "សេចក្ដីណែនាំអំពីការបកស្រាយចេញនៃវិធាន ២១(១) មិនមានន័យថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យផ្ដល់អត្ថប្រយោជន៍ដល់ជនជាប់ចោទដោយស្វ័យប្រវត្តិនៅក្នុងគ្រប់ស្ថានភាពជាក់លាក់ ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុងឡើយ")។ សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣០។ សំណុំរឿង ០០២-ឯកសារ **F10/2** សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខ

បែបទាំងនេះ មិនអាចត្រូវបានលុបលើដោយកំហុសនីតិវិធីមុនការជំនុំជម្រះ ដែលមិនបានដកហូតសិទ្ធិស្របច្បាប់ណាមួយរបស់ មាស មុត នោះទេ។

68. ផ្អែកលើសំអាងហេតុទាំងអស់នេះ តាមកាលៈទេសៈនៃរឿងក្តីនេះ ការបញ្ចប់រឿងក្តីនេះ គឺមិនសមាមាត្រទៅនឹងចរិតលក្ខណៈនៃកំហុសនីតិវិធីមុនការជំនុំជម្រះដែលមិនធ្ងន់ធ្ងរនេះឡើយ។ លើសពីនេះ ប្រសិនបើតម្រូវឱ្យមានសកម្មភាពជាដំណោះស្រាយណាមួយនោះ អ.ប.ជ បានចាត់វិធានការនោះរួចហើយ តាមរយៈការពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយៗ។ ក្របខណ្ឌគតិយុត្តរបស់តុលាការនេះ ដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង តម្រូវឱ្យបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះស្របតាមការសន្និដ្ឋានជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ឬតាមជម្រើសផ្សេង គឺគោលជំហរស្វ័យប្រវត្តិជាសារវន្ត និងកំណត់សម្រេច។

---

តំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤, កថាខណ្ឌ ១២។ **<u>ICTY</u>**: *រដ្ឋអាជ្ញា ទល់នឹង Aleksovski*, IT-95-14/1, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ស្តីពីភាពអាចទទួលយកបាននៃភស្តុតាង អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ ២៥។ **<u>ICTR</u>**: *រដ្ឋអាជ្ញា ទល់នឹង Zigiranyirazo*, ICTR-2001-73-T, សេចក្តីសម្រេចលើញត្តិរួមរបស់រដ្ឋអាជ្ញា សុំឱ្យបើកសំណុំរឿងរបស់ខ្លួនឡើងវិញ និងពិចារណាលើសេចក្តីសម្រេចថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ស្តីពីការស្តាប់សវនាការសាក្សី Michel Bagaragaza តាមវីដេអូលីង អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៨។ សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Karemera* កថាខណ្ឌ ២៦។ **<u>ICC</u>**: *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ICC-01/04-135tEN សេចក្តីសម្រេចលើពាក្យសុំរបស់អយ្យការ ស្នើការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ស្តីពីពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់ VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5 និង VPRS 6, អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ កថាខណ្ឌ ៣៨។ *ស្ថានភាពនៅក្នុងអ៊ូហ្គាន់ដា,* ICC-02/04-112, សេចក្តីសម្រេចលើពាក្យសុំរបស់អយ្យការ ស្នើការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 ទៅ a/0070/06, a/0081/06 ទៅ a/0104/06 និង a/0111/06 ទៅ a/0127/06, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌ ២៧។ FCCP, article préliminaire; Conseil Constitutionnel លេខ: 95-360, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩៥ កថាខណ្ឌ ៥។ Pradel, *Manuel de Procédure Pénale* (បោះពុម្ពលើកទី១៤), ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ ១៤១, CCCP, មាត្រា ៤។

## គ. ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានសម្រេចជាឯកច្ឆន្ទថាមានសុពលភាព - រឿងក្តីត្រូវបន្តទៅជំនុំជម្រះ

69. នៅក្នុងសេចក្តីពិចារណារបស់ អ.ប.ជ ចៅក្រមទាំង ៥ រូប បានសន្និដ្ឋានថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបញ្ជូន មាស មុត ទៅជំនុំជម្រះ មានសុពលភាព[116]។ ការសម្រេចជាឯកច្ឆន្ទនេះបង្កើតបានជាសំឡេងភាគច្រើនលើសលុប នៅក្នុងអត្ថន័យនៃវិធាន ៧៧ (១៣) ដូច្នេះ ក្របខណ្ឌគតិយុត្ត អ.វ.ត.ក កំណត់អាណត្តិថា រឿងក្តីនេះត្រូវតែបន្តទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[117]។

70. ភាពជាឯកច្ឆន្ទនៃការសម្រេចនេះមិនត្រូវបានមោឃៈ ដោយសារអង្គហេតុដែលថា វាមិនត្រូវបានដាក់បញ្ចូលក្នុងផ្នែកស្តីពី "សេចក្តីសម្រេចរួម" នៃសេចក្តីពិចារណាឡើយ ហើយក៏មិនមែនដោយសារចៅក្រមបានឈានដល់ការរកឃើញជាឯកច្ឆន្ទនេះ តាមរយៈសំអាងហេតុផ្សេងគ្នានៅក្នុងមតិយោបល់ដែលបានចុះហត្ថលេខាដាច់ដោយឡែកពីគ្នានោះដែរ[118]។ តាមពិតនោះ ទោះបីជា អ.ប.ជ

[116] *សូមមើល* ផ្នែកទី II. ប្រវត្តិនីតិវិធី កថាខណ្ឌ ១៦ *យោងខាងលើ* ជាពិសេស ការសន្និដ្ឋានដកស្រង់នៅក្នុងជើងទំព័រ ២២។

[117] វិធាន ៧៧(១៣) វិធាន ៧៩(១) ដែលចែងនៅក្នុងកថាខណ្ឌ ៣៩, ៤១ *យោងខាងលើ*។

[118] ស.ព.អ ពុំយល់ស្របជាមួយសេចក្តីថ្លែងការណ៍របស់ប្រធាន អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/២ ថា៖ "[មានតែ] ផ្នែកសេចក្តីសម្រេចរួមបានសម្រេចជាឯកច្ឆន្ទ និងចុះហត្ថលេខាដោយចៅក្រមទាំង ៥រូប ទើបត្រូវមានអានុភាពអនុវត្ត" (សំណុំរឿង ០០៤/២-ឯកសារ **D359/34 & D360/43** អនុស្សរណៈរបស់ប្រធានពាក់ព័ន្ធនឹងការជូនដំណឹងអំពីសេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ EN 01640437) និងជាមួយនឹងការយល់ឃើញរបស់ ស.ច.ស លើបញ្ហានេះ (ឯកសារ **D270/7** សេចក្តីសម្រេចបដិសេធរបស់ ស.ច.ស កថាខណ្ឌ ២៣)។ អ.ប.ជ ជាធម្មតា បានធ្វើសេចក្តីសម្រេចចាប់បង្ខំ (រួមទាំង សេចក្តីសម្រេចមិនអាចរកសំឡេងភាគច្រើនលើសលុបបានយោងតាមវិធាន ៧៨) ដែលវាស្ថិតនៅក្រៅអត្ថន័យនៃការសម្រេចប្រកបជាឯកច្ឆ័ន្ទ។ សូមមើល ឧទាហរណ៍ ឯកសារ **C2/4** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ១១-១២ ផ្នែកសេចក្តីសម្រេច។ ឯកសារ **D20/4/4** សេចក្តីពិចារណាលើសំណើទាក់ទងនឹងកិច្ចស៊ើបសួរកថាខណ្ឌ ១៣-១៤ ផ្នែកសេចក្តីសម្រេច។ ឯកសារ **D11/2/4/4** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិន នឹងបណ្តឹងឧទ្ធរណ៍ស្តីពីការទទួលយក ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លោក រ៉ូប៊ីត ហាមីល (Robert Hamill) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ ១២-១៣ ផ្នែកសេចក្តីសម្រេច។ សំណុំរឿង ០០៤-ឯកសារ **D203/1/1/2** ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើរបស់គាត់សុំការបំភ្លឺ ថាគាត់អាចស៊ើបសួរដោយខ្លួនឯងបាន ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៣០-៣១ ផ្នែកសេចក្តីសម្រេច។ ជាពិសេសនៅក្នុងការពិចារណារបស់ខ្លួនទាក់ទងនឹងការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអំពីថាតើត្រូវប្តឹងសំណុំ រឿង ០០៣ និង ០០៤ ទៅ ស.ច.ស ដែរឬទេ ការសម្រេចរបស់ អ.ប.ជ ដែលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គួរតែបញ្ជូន ស.ច.ស មិនមាននៅក្នុងផ្នែសម្រេចសេចក្តីឡើយ។ *សូមមើល* ឯកសារ **D1/1.3** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹង

បានបញ្ជាក់ជាឯកច្ឆន្ទថា ខ្លួនមិនអាចឈានដល់ការសម្រេចមួយ *ដោយផ្អែកលើសំអាងហេតុរួម* ចៅក្រមទាំងអស់យល់ឃើញរួមគ្នាចំពោះការសន្និដ្ឋានចុងក្រោយថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[119]។

71. ការអនុវត្តជាអន្តរជាតិកំណត់ថា សំអាងហេតុរួមពុំមែនជាបុរេលក្ខខណ្ឌចំពោះសេចក្តីសម្រេចរួមនោះទេ និងថាសេចក្តីសម្រេច និងសាលក្រមអាចមានមតិដោយឡែក (ឯកភាព)[120]។

---

ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ("សេចក្តីពិចារណារបស់ អ.ប.ជ អនុលោមតាមវិធាន ៧១") កថាខណ្ឌ ៤៥ (ដូចបានកែតម្រូវនៅក្នុងឯកសារកែតម្រូវ **D1/1/2** ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩) ផ្នែកសេចក្តីសម្រេច EN 00620551, FR 01616997, KH 00620604។

[119] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ១១០ ផ្នែកនៃសេចក្តីសម្រេចត្រង់ទំព័រ ៥៦ (ភាសាខ្មែរ)។

[120] *សូមមើល ឧទាហរណ៍* ***អវតក***៖ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៤(២)។ ច្បាប់ អ.វ.ត.ក មាត្រា ១៤ ថ្មី(២)។ វិធាន ១០១(២) ១១១(១)។ **ICTY**៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac,* IT-97-25-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ មតិដោយឡែករបស់ចៅក្រម Schomburg ទំព័រ ១-៦ (ឯកភាពជាមួយនឹងសេចក្តីសន្និដ្ឋានសម្រេចដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ប៉ុន្តែមិនមែនជាមួយនឹងហេតុផលដែលបានផ្តល់ឲ្យនៅក្នុងសាលដីកានោះឡើយ)។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kupreškić,* IT-95-16 មតិដោយឡែកចៅក្រម David Hunt លើបណ្តឹងសាទុក្ខដោយ Dragan Papić ប្រឆាំងដីកាសម្រេចបន្តនីតិវិធីដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២ ("ខ្ញុំយល់ស្របជាមួយសេចក្តីសម្រេចថា បណ្តឹងសាទុក្ខគួរអនុញ្ញាតឲ្យប្តឹង [...] ខ្ញុំមិនអាចយល់ស្របជាមួយហេតុផលទាំងអស់ដែលបានផ្តល់ឲ្យនៅក្នុងសេចក្តីសម្រេចរួមចំពោះលទ្ធផលនោះទេ។ នាពេលនេះ ខ្ញុំផ្តល់សំអាងហេតុផ្ទាល់ខ្លួនក្រោយបញ្ហានេះត្រូវបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ"។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Tadić,* IT-94-1 មតិដោយឡែកចៅក្រម Abi-Saab ស្តីពីញត្តិរបស់មេធាវីសុំប្តឹងសាទុក្ខបន្ទាន់បង្គំលើយុត្តាធិការ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១។ **ICTR**៖ រឿងក្តី *Kanyabashi ទល់នឹង រដ្ឋអាជ្ញា* ICTR-96-15-A សាលដីកាលើញត្តិរបស់មេធាវីការពារក្តីសុំដាក់បណ្តឹងសាទុក្ខបន្ទាន់បង្គំលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងទីI អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៩ មតិស្រប និងដោយឡែករួមគ្នា របស់ចៅក្រម Wang Tieya និងចៅក្រម Rafael Nieto-Navia កថាខណ្ឌ ១។ រឿងក្តី *Ngeze & Nahimana ទល់នឹង រដ្ឋអាជ្ញា* ICTR-99-52-A សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ មតិដោយឡែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ១ ("ខ្ញុំយល់ស្របជាមួយសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ប៉ុន្តែស្នើលើកឡើងត្រង់ចំណុចមួយដែលមានភាពខុសគ្នានៃយោបល់។ ភាពខុសគ្នានេះពុំប៉ះពាល់លទ្ធផលនៃរឿងក្តីនោះទេ")។ **SCSL**៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* SCSL-2004-16-AR73 មតិស្រប និងដោយឡែក រួមគ្នារបស់ចៅក្រម Robertson ស្តីពីសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី Brima-Kamara ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមភាគច្រើននៃអង្គជំនុំជម្រះសាលាដំបូងទី II លើសំណើសុំរួមគ្នាសំខាន់បន្ទាន់បំផុតសុំតែងតាំងសាជាថ្មីចៅក្រម Kevin Metzger និង Wilbert Harris ជាមេធាវីនាំមុខសម្រាប់ Alex Tamba និង Brima Bazzy Kamara អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ ១។ សូមមើលផងដែរ *ប្រភពបន្ថែមនៅក្នុង*ឯកសារ **D271/1** សំណើសុំ អ.ប.ជ បញ្ចប់សំណុំរឿង ជើងទំព័រ ៥៦ (ទាក់ទងនឹងបទប្បញ្ញត្តិនៃលក្ខន្តិកៈសាលាក្តីផ្សេងទៀតស្តីពីយោបល់ដោយឡែក ដែលត្រូវដាក់ភ្ជាប់នឹងសាលក្រមរបស់អង្គជំនុំជម្រះ។

វានឹងផ្ទុយនឹងច្បាប់ តក្កវិជ្ជា និងយុត្តិធម៌ ក្នុងការមិនអើពើនឹងការសន្និដ្ឋានយ៉ាងច្បាស់របស់ចៅក្រម ទាំង ៥រូប ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។ យោងតាមក្របខណ្ឌគតិយុត្ត អ.វ.ត.ក ប្រសិនបើសំឡេងភាគច្រើនលើសលុបតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រឿងក្តីត្រូវតែបញ្ជូនទៅជំនុំជម្រះ[121]។

72. ការសម្រេចជាឯកច្ឆន្ទនេះ គឺផ្ទុយស្រឡះទៅនឹងការសម្រេចរបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/២ ដែលក្នុងសំណុំរឿងនោះ ចៅក្រមជាតិបានមោឃៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ[122]។ ដោយបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០៣ មានសុពលភាព ចៅក្រមជាតិមានកាតព្វកិច្ចអនុវត្តតាមក្របខណ្ឌគតិយុត្ត អ.វ.ត.ក ដូចមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៧៧(១៣) ហើយត្រូវរួមគ្នាជាមួយចៅក្រមអន្តរជាតិ ដើម្បីបញ្ជូនរឿងក្តីនេះទៅ អ.ជ.ស.ដ ដើម្បីជំនុំជម្រះ។ ការខកខានរបស់ពួកគាត់ក្នុងការធ្វើដូច្នេះ គឺជាកំហុសអង្គច្បាប់។

73. សំអាងហេតុដែលផ្តល់ដោយចៅក្រមជាតិចំពោះការមិនធ្វើដូច្នេះគឺផ្ទុយស្រឡះ និងមិនគួរឱ្យជឿជាក់។ ផ្ទុយពីសំអាងហេតុរបស់ខ្លួន[123] ការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះនឹងមិនធ្វើឱ្យអន្តរាយដល់ឋានៈស្មើគ្នានៃ ស.ច.ស នោះឡើយ។ កិច្ចបែបនេះគ្រាន់តែជាការទទួលស្គាល់តាមផ្លូវច្បាប់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានវិសមតិភាពជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ហើយវាជាកត្តាកំណត់ចុងក្រោយស្របតាមក្របខណ្ឌគតិយុត្ត អ.វ.ត.ក ដោយផ្អែកលើមូលដ្ឋានដែលថា ដីកាដំណោះស្រាយតែមួយគត់ ដែលត្រូវបានតម្កល់ដោយយ៉ាងហោចណាស់សំឡេងភាគច្រើនលើសលុប (និង*កាន់តែច្បាស់ទៀតនេះ* ដោយភាពជាឯកច្ឆន្ទ) គឺជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ[124]។

---

[121] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

[122] *សូមមើល* សំណុំរឿង ០០៤-២-ឯកសារ **D359/24 & D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា អ.ប.ជ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, នៃ ធុល និង ហួត វុទ្ធី កថាខណ្ឌ ១៧០-៣០២ ជាពិសេស កថាខណ្ឌ ៣០២(x) និងផ្នែកសម្រេចសេចក្តី ("ដីកាដំណោះស្រាយចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះ ដែលសម្រេចសេចក្តីមកនេះ ធ្វើឡើងពុំត្រឹមត្រូវតាមកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ឡើយ ត្រូវទុកជាមោឃៈ។ ហេតុដូច្នេះសម្រេចតម្កល់ដីកាដំណោះស្រាយលើកលែងចោទប្រកាន់ អោ អាន ទុកជាបានការ។ ទុកជាមោឃៈដីកាដំណោះស្រាយចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះ។")។

[123] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ១១៦។

[124] *សូមមើល* ផ្នែកទី II. ប្រវត្តិនីតិវិធី កថាខណ្ឌ ១៦ *យោងខាងលើ*។ *សូមមើលផងដែរ* ការពិភាក្សានៅក្នុងផ្នែក V.ឃ *យោងខាងក្រោម*។

74. ដូចបានបង្ហាញហេតុផល[125] ការបញ្ជូនរឿងក្តីទៅជំនុំជម្រះមិនធ្វើឱ្យប៉ះពាល់សច្ចធារណ៍និរទោសរបស់ មាស មុត នោះទេ។ គាត់នឹងទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងតម្លាភាព ដែលការទទួលខុសត្រូវរបស់គាត់នឹងត្រូវកំណត់ដោយក្រុមប្រឹក្សាជំនុំជម្រះមិនលំអៀង និងឯករាជ្យ ដែលផ្អែកតែទៅលើអង្គហេតុ និងច្បាប់ប៉ុណ្ណោះ។ សច្ចធារណ៍និរទោសរបស់គាត់ នឹងត្រូវបានធានា និងការពារក្នុងអំឡុងពេលជំនុំជម្រះ។

75. ផ្អែកលើសំអាងហេតុដូចបានលើកឡើងក្នុងបណ្តឹងនេះ កិច្ចដាច់ស្រេចដែលតម្រូវនោះគឺត្រូវបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះដោយមិនបង្អង់។ នេះគឺជាលទ្ធផលតែមួយគត់ ដែលស្របតាមក្របខណ្ឌគតិយុត្ត អ.វ.ត.ក និងការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។

## ឃ. ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុប - រឿងក្តីត្រូវបន្តទៅជំនុំជម្រះ

76. សម្រាប់គោលបំណងវែកញែក បើទោះបីជាផ្ទុយទៅនឹងច្បាប់ និងតក្កវិជ្ជាក្តី និងបើទោះបីជាអង្គជំនុំជម្រះនេះយល់ឃើញថា មិនមានការសម្រេចជាឯកច្ឆន្ទ*តាមព្រឹត្តន័យ* ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពក្តី ទោះជាយ៉ាងណាក៏ អ.ប.ជ មានកាតព្វកិច្ចបញ្ជូនរឿងក្តីនេះទៅ អ.ជ.ស.ដ ដើម្បីធ្វើការជំនុំជម្រះ ដោយហេតុថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ហើយមិនមានសំឡេងភាគច្រើនលើសលុបតម្កល់សុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ទេ។

77. ដូចដែលបានបង្ហាញខាងលើ មាត្រា ៥(៤) និង ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ៧៧(១៣)(ខ) និង ៧៩(១)[126] នៃវិធានផ្ទៃក្នុង តម្រូវឲ្យ អ.ប.ជ បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅ អ.ជ.ស.ដ ដោយគោរពទៅតាមអ្វីដែល អ.ប.ជ បានសម្រេចជាឯកច្ឆន្ទថា ជាគោលជំហរស្វ័យប្រវត្តិ "ជាសារវន្ត និងកំណត់សម្រេច" ដែលថាការស៊ើបអង្កេត

---

[125] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ១១៦។

[126] *សូមមើល* ផ្នែកច្បាប់ជាធរមាន កថាខណ្ឌ ៣០, ៣៧, ៣៩ និង ៤១ *យោងខាងលើ* (កថាខណ្ឌ ៣០៖ កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ៥(៤) កថាខណ្ឌ ៣៧៖ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤), ច្បាប់ អ.វ.ត.ក មាត្រា ២៣ ថ្មី កថាខណ្ឌ ៣៩៖ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៤១៖ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង)។

ត្រូវតែបន្ត[127]។ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានរៀបរាប់ដោយត្រឹមត្រូវអំពីគោលការណ៍ស្នូលនេះថាជា "គោលការណ៍បន្តកិច្ចស៊ើបសួរ និងការជំនុំជម្រះ"[128] ដែលលុបបំបាត់នូវភាពមិនប្រាកដប្រជានានា នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធ[129]។ គោលជំហរស្វ័យប្រវត្តិនេះ ត្រូវបានទទួលយកដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ[130] ហើយត្រូវ

---

[127] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៤, ៩៧, ៩៨ (ជាឯកច្ឆន្ទ)។ សូមមើលផងដែរ សំណុំរឿង ០០៤/២-ឯកសារ **D359/24 &D360/33** សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ១០៦-១០៧, ១១១, ១១៧ (ជាឯកច្ឆន្ទ)។ សេចក្តីប្រកាសរបស់ អ.ជ.ត.ក ក្នុងកថាខណ្ឌ ៤២ *យោងខាងលើ*។

[128] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២៥៦, ២៦១។ សំណុំរឿង ០០៤/២-ឯកសារ **D359/24 &D360/33** សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២ យោបល់របស់ចៅក្រមBaik និង Beauvallet កថាខណ្ឌ ៣២០។ សំណុំរឿង ០០៤-ឯកសារ **D381/45 & D382/43** សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤ យោបល់របស់ចៅក្រម Kang Jin Baik និងចៅក្រម Olivier Beauvallet ("យោបល់របស់ចៅក្រមអន្តរជាតិ") កថាខណ្ឌ ១៦៩, ១៧៤, ៥៣៣, ៥៣៨។

[129] សំណុំរឿង ០០៤-ឯកសារ **D381/45 & D382/43** សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៧៤ ("ទទ្បីករណ៍អំពី*ចន្លោះប្រហោង*ដែលអាចមាននៅក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងផលវិបាកគតិយុត្តនៃការចេញដីកាដំណោះស្រាយផ្ទុយគ្នា គឺមិនអាចអនុវត្តបានឡើយក្នុងសំណុំរឿងបច្ចុប្បន្ន [...] ភាពមិនជាក់លាក់ដែលចោទឡើង ត្រូវបានលុបបំបាត់ចោលតាមរយៈការបកស្រាយដោយសមស្របទៅលើអត្ថបទគតិយុត្តពាក់ព័ន្ធ [...] ដែលតម្កល់គោលការណ៍បន្តកិច្ចស៊ើសួរ និងការជំនុំជម្រះ។ ចៅក្រមអន្តរជាតិសូមបញ្ជាក់ថា យោងតាមវិធាន ៧៧(១៣)(១)(ខ) នៃវិធានផ្ទៃក្នុង នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានច្រានចោលទេនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវមានសុពលភាព កិច្ចដំណើរការនីតិវិធីចាំបាច់ត្រូវបន្ត ហើយសំណុំរឿងចាំបាច់ត្រូវបញ្ជូនទៅជំនុំជម្រះ")។

[130]នៅក្នុងថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជាជាលើកដំបូងនូវពាក្យពេចន៍មាត្រា ៧(៤) Hans Corell អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងទីប្រឹក្សាច្បាប់របស់ អ.ស.ប បានថតកិច្ចសន្ទនាមួយជាមួយឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានក្រុមអ្នកចរចារបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបានបដិសេធការស្នើសុំរបស់គាត់ឱ្យមានលក្ខខណ្ឌសំឡេងភាគច្រើនលើសលុប ដើម្បីសម្រេចទៅលើការបន្តកិច្ចស៊ើបសួរ ឬការចោទប្រកាន់។ Hans Corell បានពន្យល់ថា យន្តការខ្វែងយោបល់គ្នាដែលបានពង្រាងរួចហើយនោះ មានន័យថា "លោកចាំបាច់ត្រូវមានសំឡេងភាគច្រើនលើសលុប ដើម្បីបញ្ឈប់កិច្ចស៊ើបសួរ ឬការចោទប្រកាន់" (*សូមមើល* ឯកសារ **D181/2.30** លិខិតពីអគ្គលេខាធិការ អ.ស.ប ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ភ្ជាប់ជាឧបសម្ព័ន្ធនូវកំណត់សម្គាល់ពី Hans Corell ផ្ញើជូនអគ្គលេខាធិការ កម្មវត្ថុ៖ ការស្នើសុំបន្ទាន់ពីកម្ពុជា — ជម្រើសនានាក្នុងការដោះស្រាយការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបសួរ/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០ EN 01326090)។ Hans Corell បានបញ្ជាក់ជំហរនេះកាលពីខែមីនា ឆ្នាំ២០០៣ បន្ទាប់ពីមានកិច្ចព្រមព្រៀង អ.វ.ត.ក ដែលមានខ្លឹមសារថា ឯកភាពទៅលើពាក្យពេចន៍ដដែលនេះ (**D181/2.36** សេចក្តីថ្លែងការណ៍របស់អគ្គលេខាធិការរង Hans Corell នៅពេលចាកចេញពីរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ERN (ភាសាអង់គ្លេស) 01326112)។ *សូមមើល ផងដែរ* David Scheffer in M. Cherif Bassiouni (ed), "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បោះពុម្ពលើកទីបី វ៉ុល III ឆ្នាំ២០០៨ ទំព័រ ២៣១,

បានអនុវត្តជាប្រចាំដោយអង្គជំនុំជម្រះនានានៃ អ.វ.ត.ក រួមទាំងចៅក្រមជាតិ នៃ អ.ប.ជ ផងដែរ[131]។ ចំណុចនេះចាំបាច់ត្រូវបកស្រាយផងដែរដោយផ្អែកលើគោលដៅ និងគោលបំណងនៃសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា "ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[132]។

78. ក្នុងបរិបទនេះ ច្បាស់ណាស់ថា "ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត" ដែលមានន័យសាមញ្ញថា "រឿងក្តីត្រូវតែបន្ត" ដោយរួមបញ្ចូលទាំងដំណាក់កាលនៃការ

---

២៤៦ (ដែលបញ្ជាក់ថា អនុលោមតាមវិធានសំឡេងភាគច្រើនលើសលុប "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬកិច្ចស៊ើបសួរអាចបញ្ឈប់បាន លុះត្រាតែ [អ.ប.ជ] សម្រេចដោយសំឡេងភាគច្រើនលើសលុបថា ការចោទប្រកាន់ ឬកិច្ចស៊ើបសួរនោះគួរតែបញ្ចប់")។

[131] *សូមមើល ឧទាហរណ៍* **អ.ជ.ត.ក**៖ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥ ("ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលុបទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"។ *សូមមើលបន្ថែមទៀត* ការវិភាគលើសាលដីកានេះ នៅក្នុងឯកសារ **D267/10** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍រស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ៣៤-៣៥។ **អ.ប.ជ**៖ ឯកសារ **D1/1.3** សេចក្តីពិចារណារបស់ អ.ប.ជ យោងតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ១៦, ១៧, ២៦, ៤៥ (ជាឯកច្ឆន្ទ) យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៨-១៩ (ដែលចៅក្រមជាតិនៃ អ.ប.ជ មិនយល់ស្របជាមួយវិធីដែលការស៊ើបអង្កេតបឋមត្រូវបានចាប់ផ្តើម និងអនុវត្តដោយ ស.ព.អ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ប៉ុន្តែ ចៅក្រមជាតិ ជាមួយនឹងចៅក្រមអន្តរជាតិ បានយល់ស្របជាឯកច្ឆន្ទលើឧត្តមភាពនៃគោលការណ៍បន្តកិច្ចស៊ើបសួរ និងការជំនុំជម្រះ)។ ឯកសារ **D1/1.1** ឧបសម្ព័ន្ធ **II**៖ សេចក្តីដកស្រង់នៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ សេចក្តីសន្និដ្ឋាន។ សំណុំរឿង ០០៤/១-ឯកសារ **A122/6.1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រី ឲ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។ ឯកសារ **D117/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៦។

[132] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១ ដូចមានបញ្ជាក់នៅក្នុងច្បាប់ អ.វ.ត.ក មាត្រា ១។

បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅ អ.ជ.ស.ដ[133]។ តាមពិតទៅ គោលជំហរស្វ័យប្រវត្តិ ត្រូវតែទទួលបានការគោរព នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក រួមទាំងក្រោយពេលបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខ អ.ប.ជ ទោះជាចាត់ទុកថា ការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងទៅ អ.ជ.ស.ដ ជាផ្នែកនៃការស៊ើបអង្កេត ឬជាផ្នែកនៃការចោទប្រកាន់ ឬយ៉ាងណា[134]។ ការបង្កើតប្រព័ន្ធមួយ ដែលការខ្វែងយោបល់គ្នាដំបូងៗត្រូវបានដោះស្រាយដើម្បីជាប្រយោជន៍ដល់កិច្ចដំណើរការនីតិវិធី ប៉ុន្តែការខ្វែងយោបល់គ្នានាពេលក្រោយៗលើបញ្ហាតែមួយ ត្រូវបានដោះស្រាយដើម្បីជាប្រយោជន៍នៃការបញ្ចប់កិច្ចដំណើរការនីតិវិធី គឺជារឿងឥតប្រយោជន៍ ចំណាយថវិកាច្រើន និងចំណាយពេលវេលាយូរ ដោយសឹងតែគ្មានសង្ឃឹមថានឹងទៅដល់ដំណាក់កាលជំនុំជម្រះ។

79. គោលជំហរស្វ័យប្រវត្តិដែលចែងក្នុង វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធជាពិសេសជាមួយដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានអានុភាពជាច្បាប់ពិសេស លើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក) ពាក់ព័ន្ធដីកាទូទៅ មិនមែនដីកាបញ្ជូនរឿងទៅជំនុំជម្រះ[135]។ ប្រសិនអ្នកតាក់តែង

---

[133] នៅក្នុងសំណុំរឿង ០០២ អ.ប.ជ បានសម្រេចជាឯកច្ឆន្ទនៅក្នុងសេចក្តីសម្រេចមួយដែលចុះកាលបរិច្ឆេទមុនការសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០១ ថា ឃ្លា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" រួមបញ្ចូលដំណាក់កាល នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង។ *សូមមើល* សំណុំរឿង ០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤ ("[ស.ច.ស] មិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់ [អ.ប.ជ] ទេ នៅពេលខ្លួនមិនព្រមព្រៀងគ្នាលើបញ្ហាណាមួយដែលនៅចំពោះមុខ ហើយក្នុងករណីនេះ សេចក្តីសម្រេចនោះគឺថា "ការស៊ើបអង្កេតត្រូវតែបន្ត" ស្របទៅនឹងវិធីសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតបានយកមកអនុវត្តនៅក្នុងករណីបច្ចុប្បន្ននេះ")។

[134] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៨ (ជាឯកច្ឆន្ទ) ("គោលការណ៍ដែលមានលក្ខណៈសារវន្តនិងកំណត់សម្រេចដូចជា គោលជំហរស្វ័យប្រវត្តិនេះ គឺមិនលុបចោល ឬដកចេញនូវស្ថានទម្ងន់ និងអានុភាពពេញលេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយសាំញ៉ាំ")។ សំណុំរឿង ០០៤/២-ឯកសារ **D359/24 &D360/33** សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ១១២ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* ឯកសារ **D266/18.2** ប្រតិចារឹកសវនាការបណ្តឹងឧទ្ធរណ៍ ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ KH 01652879 (ដែល អ.ប.ជ បានសួរទៅ ស.ព.អ ថាតើ ក្នុងន័យសាមញ្ញ ការផ្ទេរការចោទប្រកាន់ និងសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ជាផ្នែកនៃការស៊ើបអង្កេត ឬជាផ្នែកនៃការជំនុំជម្រះ ឬយ៉ាងណា)។

[135] ឃ្លាឡាតាំង *ច្បាប់ពិសេស* (*lex specialis*) សំដៅទៅលើទ្រឹស្តីមួយទាក់ទិនទៅនឹងការបកស្រាយច្បាប់ ដែលយោងតាមទ្រឹស្តីនេះ ច្បាប់មួយដែលបញ្ញត្តិអំពីកម្មវត្ថុនៃបណ្តឹងជាក់លាក់មួយ (ច្បាប់ពិសេស) មានអធិកភាពលើច្បាប់មួយដែលគ្រាន់តែបញ្ញត្តិអំពីបញ្ហាទូទៅ (ច្បាប់ទូទៅ (*lex generalis*))។ វាជាយន្តការនៃការបកស្រាយដែលគេទទួលស្គាល់យ៉ាងទូលំទូលាយ ដែលត្រូវបានប្រើប្រាស់ជាលក្ខណៈអន្តរជាតិ រួមទាំងនៅ អ.វ.ត.ក ផងដែរ។ *សូមមើល ឧទាហរណ៍* សំណុំរឿង ០០១-**F28**

វិធានផ្ទៃក្នុងមានចេតនាថា ដីកាសម្រេចលើកលែងចោទប្រកាន់ និងបញ្ចប់សំណុំរឿង ដោយមិនមានសំឡេងភាគច្រើនលើសលុប ដើម្បីបដិសេធវាទេនោះ អ្នកតាក់តែងវិធាននេះនឹងបញ្ជាក់ច្បាស់ៗបែបនេះ នៅក្នុងវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ គោលការណ៍នៃការបន្តរឿងក្តីតម្រូវថា អ.ជ.ស.ដ ត្រូវទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយរឿងក្តីត្រូវតែជំនុំជម្រះ[136]។

80. ការមិនគោរពតាមគោលការណ៍នៃការបន្ត គឺបង្កើតបានជាកំហុសអង្គច្បាប់ ដោយចៅក្រមនៃ អ.ប.ជ ដែលបណ្តាលឱ្យមាន "លទ្ធផលគតិយុត្តដែលមិនមានសំអាងហេតុទាល់តែសោះ ហើយនាំឱ្យមានការរំលោភបំពាន ទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា"[137] រួមទាំងគោលការណ៍គ្របដណ្តប់ដែលថា កិច្ចដំណើរការនីតិវិធីចាំបាច់ត្រូវអនុលោមតាមនិត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាព។

81. ទោះបីជា អ.ប.ជ បានវាយតម្លៃជាឯកច្ឆន្ទ នូវតម្លៃនៃគោលជំហរស្វ័យប្រវត្តិ ដើម្បីផ្តល់នូវមធ្យោបាយប្រកបដោយប្រសិទ្ធភាព គេចចេញពីការជាប់គាំងផ្នែកនីតិវិធីដែលអាចមានណាមួយបណ្តាលមកពីការខ្វែងយោបល់គ្នា[138]ក៏ដោយ ក៏ អ.ប.ជ មិនបានអនុវត្តគោលជំហរនេះចំពោះសំណុំរឿង ០០៣

---

សាលដីកា រឿងក្តី *ឌុច* កថាខណ្ឌ ២៩៨, ៣៤៨។ *សូមមើល ផងដែរ* មហាសន្និបាតអង្គការសហប្រជាជាតិ របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ សម័យប្រជុំលើកទី ៥៨ ឆ្នាំ២០០៦ កថាខណ្ឌ ៦១។ មហាសន្និបាត អ.ស.ប របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ សម័យប្រជុំលើកទី ៥៦ ឆ្នាំ២០០៤ កថាខណ្ឌ ៣០៥។ *Beagle Channel Arbitration (រឿងក្តីប្រទេសអាហ្សង់ទីន តទល់នឹង ប្រទេសឈីលី)* របាយការណ៍ និងសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តកម្ម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ កថាខណ្ឌ ៣៦, ៣៨-៣៩។ រឿងក្តី *Brannigan និង McBride តទល់នឹងចក្រភពអង់គ្លេស* លេខ ១៤៥៥៣/៨៩ និង ១៤៥៥៤/៨៩ សាលក្រម ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ កថាខណ្ឌ ៧៦។ រឿងក្តី *Nikolova តទល់ប្រទេសប៊ុលហ្គារី* លេខ ៣១១៩៥/៩៦ សាលក្រម ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៩។ C-96/00 Rudolf Gabriel សាលក្រម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២ លេខ 2002 ECR-I-06367 ទំព័រ ៦៣៩៨-៦៣៩៩ កថាខណ្ឌ ៣៥-៣៦ និងទំព័រ ៦៤០៥ កថាខណ្ឌ ៥៩។

[136] *សូមមើល* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥ *ដកស្រង់* ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី,* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤), វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។ ទោះបីជាការសម្រេចនេះកើតឡើងចេញពីការពិភាក្សាអំពីសេណារីយ៉ូដែល ស.ច.ស មួយរូប ឬទាំងពីររូបបានបញ្ជូនបញ្ហានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ដែលផ្ទុយគ្នា ទៅ អ.ប.ជ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏លទ្ធផលដ៏សំខាន់អាចយកមកអនុវត្តបានស្មើគ្នាចំពោះស្ថានភាពបច្ចុប្បន្ន ដែល អ.ប.ជ ទទួលបានបណ្តឹងឧទ្ធរណ៍ពីភាគីនានា ដោយសារតែលក្ខណៈដែល អ.ប.ជ ទទួលយកបញ្ហាដូចគ្នានេះមកពិនិត្យ គឺមិនពាក់ព័ន្ធឡើយ ទោះបីជាចៅក្រមរូបណាមានកំហុសក្នុងការចេញដីកាលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ។

[137] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៨ (ជាឯកច្ឆន្ទ)។

[138] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៤, ៩៧, ៩៨ (ជាឯកច្ឆន្ទ)។

ដោយបញ្ជូនរឿងក្ដីនេះទៅ អ.ជ.ស.ដ ឡើយ។ ជាពិសេស ដោយផ្ទុយទៅនឹងតក្កវិជ្ជា និងសង្គតភាពទាំងអស់ ចៅក្រមជាតិមិនបានទទួលស្គាល់ ទាំងថាដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានតម្កល់ជាឯកច្ឆន្ទ (ហើយ *កាន់តែច្បាស់ទៀតនេះ* មិនត្រូវបានបដិសេធចោលដោយសំឡេងភាគច្រើនលើសលុប) ប៉ុណ្ណោះទេ ថែមទាំងមិនទទួលស្គាល់ទៀតថា ដីកាសម្រេចលើកលែងចោទប្រកាន់មិនត្រូវបានតម្កល់ដោយសំឡេងភាគច្រើនលើសលុប ហើយដូច្នេះ គោលជំហរស្វ័យប្រវត្តិតម្រូវឱ្យរឿងក្ដីបន្តទៅមុខ[139]។ បើទោះជាក្នុងស្ថានភាពដែលកម្រកើតមាន ដែលដីកាសម្រេចលើកលែងចោទប្រកាន់ មានអានុភាពស្របគ្នាជាមួយដីកាបញ្ជូនរឿងទៅជំនុំជម្រះក្ដី ក៏រឿងក្ដីត្រូវតែបន្តទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ព្រោះនេះគឺច្បាស់ណាស់ថាជាអ្វីដែលភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក បានគ្រោងទុកជាមួយគោលជំហរស្វ័យប្រវត្តិនេះ៖ កិច្ចដំណើរការនីតិវិធីអាចត្រូវបានផ្អាកដោយសំឡេងភាគច្រើនលើសលុបប៉ុណ្ណោះ[140]។

82. ជាចុងក្រោយ នៅក្នុងកិច្ចដំណើរការនីតិវិធីកម្ពុជា មូលហេតុនៃការរលត់បណ្ដឹងអាជ្ញា ក្រៅពីការលើកលែងចោទប្រកាន់ ផ្អែកលើអង្គសេចក្ដី ដែលកម្រិតកំណត់យ៉ាងច្បាស់ដោយមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺមរណភាពរបស់ជនជាប់ចោទ ការផុតអាជ្ញាយុកាល ការផ្ដល់ការលើកលែងទោស និរាករណ៍នៃច្បាប់ និង*អាជ្ញាអស់ជំនុំ*[141]។ គ្មានមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងអស់នេះអាចអនុវត្តបានចំពោះសំណុំរឿង ០០៣ ឡើយ ហើយ អ.ជ.ត.ក និង អ.ជ.ស.ដ សុទ្ធតែបានសម្រេចថា អ.វ.ត.ក មិនមានសិទ្ធិអំណាចបង្គាប់ឱ្យរលត់បណ្ដឹងអាជ្ញាដោយមូលហេតុផ្សេងពីនេះបានទេ[142]។

---

[139] ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណា យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ១១៥-១១៨។

[140] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ តាមរយៈពាក្យពេចន៍នៃបទប្បញ្ញត្តិនេះ បទប្បញ្ញត្តិនេះពាក់ព័ន្ធជាមួយនឹងយន្តការដោះស្រាយជម្លោះផ្លូវការ ដែលមានចែងនៅក្នុងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក និង វិធាន ៧២ នៃវិធានផ្ទៃក្នុង ដូច្នេះហើយ វាមិនដោះស្រាយចំពោះស្ថានភាពនីតិវិធីជាក់លាក់ឡើយ ប៉ុន្តែវា*ពិតជា*ដោះស្រាយចំពោះស្ថានភាពនេះ *ជាសារធាតុ*៖ ស.ច.ស ពីររូបមិនយល់ស្របគ្នាចំពោះថាតើ កិច្ចដំណើរការនីតិវិធីគួរតែបន្តទៅមុខ ឬយ៉ាងណា។

[141] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៧។

[142] សំណុំរឿង ០០២-E138/1/10/1/5/7 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-ឯកសារ **E116** សេចក្ដីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3 E82 E88 និង E92) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-២៧ (យល់ឃើញថាកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក អាចត្រូវបានបញ្ចប់យោងតាមវិធាន ៨៩(១)(ខ) ដោយផ្អែកលើមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានមានកម្រិតដែលមានបញ្ជាក់នៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាតែប៉ុណ្ណោះ)។

## VI. សេចក្តីសន្និដ្ឋាន

83. ចៅក្រម អ.ប.ជ ទាំងអស់ ទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ បានសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត មានសុពលភាពយ៉ាងត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះគឺជាការសន្និដ្ឋានដែលមានជាប់មកជាមួយថាមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការនាំខ្លួន មាស មុត ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។ ច្បាប់ អ.វ.ត.ក កំណត់អាណត្តិថា សំណុំរឿង ០០៣ ត្រូវតែបញ្ជូនទៅជំនុំជម្រះផ្អែកលើមូលដ្ឋាននៃការសម្រេចជាឯកច្ឆន្ទនេះ ក៏ដូចជាផ្អែកលើមូលដ្ឋាននៃគោលជំហរស្វ័យប្រវត្តិ ដែលត្រូវចាប់ផ្តើមឡើងនៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយយ៉ាងហោចណាស់សំឡេងភាគច្រើនលើសលុប។ ការបរាជ័យរបស់ អ.ប.ជ ក្នុងការចាត់វិធានការចុងក្រោយដើម្បីបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះឱ្យបានត្រឹមត្រូវ ដោយការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ បង្កើតបានជាកំហុសអង្គច្បាប់ ដែលតម្រូវឱ្យមានអន្តរាគមន៍ពី អ.ជ.ត.ក។

84. ការសន្និដ្ឋានរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់ មិនបានរារាំងរឿងក្តីមិនឱ្យបន្តទៅជំនុំជម្រះឡើយ។ ការសន្និដ្ឋាននេះផ្ទាល់ មើលរំលងមិនត្រឹមត្រូវនូវក្របខណ្ឌគតិយុត្តដ៏ពិសេសតែមួយគត់របស់ អ.វ.ត.ក ដែលមិនត្រឹមតែអនុញ្ញាតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគ្រោងទុកជាមុនអំពីការចេញដីកាដំណោះស្រាយពីរ ក្នុងករណីដែលមានការខ្វែងយោបល់គ្នាមិនអាចផ្សះផ្សាបាន រវាង ស.ច.ស ដែលមានឋានៈស្មើគ្នា។ ទោះបីជា ការសន្និដ្ឋានរបស់ អ.ប.ជ ត្រូវបានទទួលយក ការចេញដោយខុសច្បាប់របស់ ស.ច.ស បង្កើតបានជាកំហុសផ្នែកនីតិវិធីដែល អ.ប.ជ បានជួសជុល និងដែលមិនបានបណ្តាលឱ្យមានភាពអយុត្តិធម៌ទាំងស្រុង មិនមានផលប៉ះពាល់សំខាន់ និងមិនមានការរំលោភលើដំណើរការនីតិវិធី ដែលតម្រូវឱ្យមានការបញ្ចប់សំណុំរឿង ០០៣ ដោយ អ.ជ.ត.ក នោះឡើយ។ ដំណោះស្រាយបែបនេះពិតជាមិនសមាមាត្រទាល់តែសោះទៅនឹងកំហុសដែលបានចោទ និងបដិសេធសិទ្ធិរបស់ជនរងគ្រោះ និងសហគមន៍សកលលោកទាំងមូល ក្នុងការទទួលបានការវិនិច្ឆ័យជាសាធារណៈចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ នៅចំពោះមុខអ្នកសម្រេចអង្គហេតុដ៏យុត្តិធម៌ និងមិនលម្អៀង។

## VII. ដំណោះស្រាយដែលស្នើសុំ

85. ផ្អែកលើសំអាងហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា សំណុំរឿង ០០៣ ត្រូវបញ្ជូនទៅ អ.ជ.ស.ដ ដើម្បីធ្វើការជំនុំជម្រះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |